ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
និយ័តករគណនេយ្យនិងសវនកម្ម

# សេចក្តីព្រាងយុទ្ធសាស្ត្រ
# ស្តីពី
# ការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរ នៅកម្ពុជា
# ឆ្នាំ២០២១-២០៣១

# មាតិកានុក្រម


**អក្សរកាត់**.................................................................................................................... ៣
**ជំពូកទី១÷ សេចក្តីផ្តើម**.................................................................................................... ៥
**ជំពូកទី២÷ គោលបំណង គោលដៅ និង ទិសាលភាព**.................................................................. ៧
២.១. គោលបំណង.......................................................................................................... ៧
២.២. គោលដៅ............................................................................................................. ៧
២.៣. វិសាលភាព........................................................................................................... ៧
**ជំពូកទី៣÷ វឌ្ឍនភាពនៃការកែទម្រង់រហូតមកដល់ពេលបច្ចុប្បន្ន**........................................................ ៨
៣.១. សារតារនៃកំណែទម្រង់............................................................................................ ៨
៣.២. ការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានសាច់ប្រាក់.................................. ៩
៣.៣. កំណែទម្រង់ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ................................................................ ១០
៣.៤. ការដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........... ១១
**ជំពូកទី៤÷ ទិសដៅកំណែទម្រង់**.................................................................................... ១៣
៤.១. ការអភិវឌ្ឍស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរ ................................................. ១៣
៤.២. ការកសាងសមត្ថភាព ការគ្រប់គ្រងការផ្លាស់ប្តូរ និងការទំនាក់ទំនងសម្រាប់អនុវត្តស្តង់ដា
គណនេយ្យ មូលដ្ឋានបង្គរ......................................................................................... ១៣
៤.៣. ការរៀបចំសមតុល្យដើមគ្រានៃទ្រព្យសកម្មរយៈពេលវែង សម្រាប់ការអនុវត្តស្តង់ដាគណនេយ្យ
មូលដ្ឋានបង្គរ......................................................................................................... ១៤
៤.៣.១ ទ្រព្យសកម្មរយៈពេលវែង........................................................................... ១៥
៤.៣.២ កម្ចី..................................................................................................... ១៦
៤.៤. ដំណាក់កាលនៃការអនុវត្តស្តង់ដាគណនេយ្យសាធារណៈ................................................. ១៧
៤.៤.១. ដំណាក់កាលទី១÷ គណនេយ្យមូលដ្ឋានសាច់ប្រាក់........................................... ១៨
៤.៤.២. ដំណាក់កាលទី២÷ គណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល................................ ១៩
៤.៤.៣. ដំណាក់កាលទី៣÷ គណនេយ្យមូលដ្ឋានបង្គរកែសម្រួល...................................... ២០
៤.៤.៤. ដំណាក់កាលទី៤÷ គណនេយ្យមូលដ្ឋានបង្គរ.................................................. ២០

**ជំពូកទី៥÷ លក្ខខណ្ឌចាំបាច់ឆ្ពោះទៅការអនុវត្តគណនេយ្យមូលដ្ឋានបង្គរ**............................ ២២
៥.១. លក្ខខណ្ឌចាំបាច់ផ្នែករដ្ឋបាល............................................................................ ២២
៥.១.១. ការគាំទ្រផ្នែកនយោបាយ និងរដ្ឋបាល.................................................... ២២
៥.១.២. ប្រព័ន្ធច្បាប់ និងបទប្បញ្ញត្តិដែលគាំទ្រដល់គណនេយ្យមូលដ្ឋានបង្គរ................ ២២
៥.១.៣. គណនេយ្យករជំនាញ និងអ្នកកាន់បញ្ជីគណនេយ្យ ........................................ ២៣
៥.១.៤. សមត្ថភាពគ្រប់គ្រងគម្រោង.................................................................. ២៤
៥.២. លក្ខខណ្ឌចាំបាច់ផ្នែកបច្ចេកទេស......................................................................... ២៤
៥.២.១. ប្រព័ន្ធ FMIS ដែលមានមុខងារពេញលេញមួយ........................................... ២៤
៥.២.២. របាយការណ៍ហិរញ្ញវត្ថុមូលដ្ឋានសាច់ប្រាក់ដែលមានគុណភាព......................... ២៥
៥.២.៣. ប្លង់គណនេយ្យដែលអំណោយផលដល់គណនេយ្យមូលដ្ឋានបង្គរ........................ ២៥
៥.៣. លក្ខខណ្ឌចាំបាច់ផ្នែកគណនេយ្យ.......................................................................... ២៦
**ជំពូកទី៦÷ ការគ្រប់គ្រងគម្រោង**............................................................................... ២៧
៦.១. រចនាសម្ព័ន្ធនៃការគ្រប់គ្រងគម្រោង.......................................................................... ២៧
៦.២. ធាតុចំណាយនៃកំណែទម្រង់.................................................................................. ៣២
**ជំពូកទី៧÷ សកម្មភាពសង្ខេប**................................................................................... ៣៤
**ឧបសម្ព័ន្ធទី១÷ ការពិពិណនាអំពីស្តង់ដាគណនេយ្យអន្តរជាតិ**
**សម្រាប់វិស័យសាធារណៈមូលដ្ឋានបង្គរ** ....................................................... ៣៧
**ឧបសម្ព័ន្ធទី២÷ ឯកសារយោងនានាដែលបានបោះផ្សាយ**.................................................... ៥៥

# អក្សរកាត់

| | | |
|---|---|---|
| ACAR | Accounting and Auditing Regulator | និយ័តករគណនេយ្យនិងសវនកម្ម |
| AFD | Agence Française de Développment | ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ |
| CAP | Consolidated Action Plan | ផែនការសកម្មភាពរួម |
| CoFoG | Classifications of the Functions of Government | ចំណាត់ថ្នាក់មុខងាររបស់រដ្ឋាភិបាល |
| CPSAS | Cambodian Public Sector Accounting Standards | ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា |
| DMFAS | Debt Management and Financial Analysis System | ប្រព័ន្ធវិភាគហិរញ្ញវត្ថុ និងគ្រប់គ្រងបំណុល |
| EFI | Economic and Finance Institute | វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| EU | European Union | សហភាពអឺរ៉ុប |
| FMIS | Financial Management Information System | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| FS | Financial Statements | របាយការណ៍ហិរញ្ញវត្ថុ |
| FY | Financial Year | ឆ្នាំហិរញ្ញវត្ថុ |
| GDB | General Department of Budget | អគ្គនាយកដ្ឋានថវិកា |
| GDNT | General Department of National Treasury | អគ្គនាយកដ្ឋានរតនាគារជាតិ |
| GFS | Government Finance Statistics | ប្រព័ន្ធស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល |
| GPFS | General Purpose Financial Statements | របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ |
| IMF | International Monetary Fund | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| ICT | Information & Communication Technology | បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ |

| | | |
|---|---|---|
| IFRS | International Financial Reporting Standards | ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ |
| IPSAS | International Public Sector Accounting Standards | ស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ |
| LGU | Local Government Unit | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| LM | Line Ministries | ក្រសួង-ស្ថាប័ន |
| KICPAA | Kampuchea Institute of Certified Public Accountants and Auditors | វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា |
| MDA | Ministries, Departments and Agencies | ក្រសួង-ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| NAA | National Audit Authority | អាជ្ញាធរសវនកម្មជាតិ |
| NAC | National Accounting Council | ក្រុមប្រឹក្សាជាតិគណនេយ្យ |
| PEFA | Public Expenditure and Financial Accountability | ចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ |
| PFM | Public Financial Management | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PFMRP | Public Financial Management Reform Programme | កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| RGoC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| SARMIS | State Asset Regulatory and Management Information System | ប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ |
| WB | World Bank | ធនាគារពិភពលោក |

# ជំពូកទី១
# សេចក្តីផ្តើម

នៅក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ កំណើនសេដ្ឋកិច្ចកម្ពុជានៅតែរក្សាបានភាពរឹងមាំ ហើយនៅក្នុងឆ្នាំ២០១៥ ធនាគារពិភពលោកបានដំឡើងចំណាត់ថ្នាក់របស់កម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ រហូតមកដល់ពេលនេះ ទោះបីជាពិភពលោកជួបប្រទះនូវភាពមិនច្បាស់លាស់ផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏ដោយ ក៏សេដ្ឋកិច្ចកម្ពុជានៅតែរក្សាបាននូវភាពរឹងមាំ ហើយនឹងអាចក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចរីកលូតលាស់លឿនជាងគេនៅក្នុងតំបន់អាស៊ី សម្រាប់អនាគតដ៏ខ្លីខាងមុខ។

នៅក្នុងខែកញ្ញា ឆ្នាំ២០១៩ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រកាសដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យមូលដ្ឋានសាច់ប្រាក់ ដើម្បីប្រើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅសម្រាប់ក្រសួង-ស្ថាប័នសាធារណៈ និងមន្ទីរជំនាញរាជធានី-ខេត្ត ដែលជាជំហានចាប់ផ្តើមដើម្បីឆ្ពោះទៅការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនាពេលអនាគត។

រដ្ឋាភិបាលនៃបណ្តាប្រទេសនានាទូទាំងសកលលោក រួមទាំងកម្ពុជាផង បាននិងកំពុងផ្តោតការយកចិត្តទុកដាក់ខ្ពស់លើគណនេយ្យភាពនិងតម្លាភាពហិរញ្ញវត្ថុ ក្នុងការចែករំលែកទិន្នន័យដល់ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធនានា ព្រមទាំងយកចិត្តទុកដាក់លើប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការប្រើប្រាស់ធនធានរបស់ប្រទេសក្នុងការផ្តល់សេវាសាធារណៈ។ ស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានសាច់ប្រាក់ ត្រូវបានគេដឹងថាមានចំណុចខ្សោយមួយចំនួនពាក់ព័ន្ធនឹងតម្រូវការព័ត៌មានហិរញ្ញវត្ថុចាំបាច់នានា ដោយហេតុថា ប្រតិបត្តិការគណនេយ្យមូលដ្ឋានសាច់ប្រាក់ ត្រូវបានទទួលស្គាល់តែនៅពេលដែលស្ថាប័នបានទទួលសាច់ប្រាក់ ឬ បានទូទាត់សាច់ប្រាក់ប៉ុណ្ណោះ ដោយមិនបានគិតអំពីពេលវេលានៃប្រតិបត្តិការសេដ្ឋកិច្ចដែលបានកើតឡើង ឬ អត្ថប្រយោជន៍សេដ្ឋកិច្ចនៃប្រតិបត្តិការទាំងនោះទេ។ ភាពខ្វះចន្លោះនៃគណនេយ្យមូលដ្ឋានសាច់ប្រាក់ មិនអាចបង្ហាញឱ្យឃើញច្បាស់លាស់អំពីស្ថានភាពហិរញ្ញវត្ថុពិតរបស់រដ្ឋាភិបាលបានទេ ហើយក្នុងប្រទេសមួយចំនួន កង្វះខាតព័ត៌មានហិរញ្ញវត្ថុដែលបានបង្ហាញដោយប្រើគណនេយ្យមូលដ្ឋានសាច់ប្រាក់អាចធ្វើឱ្យប៉ះពាល់ដល់ការវិភាគ និងការធ្វើសេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ និងវិនិយោគិន។

រហូតមកដល់ពេលនេះ ការប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើគណនេយ្យមូលដ្ឋានសាច់ប្រាក់នៅក្នុងវិស័យសាធារណៈត្រូវបានមើលឃើញថាមានការកើនឡើងជាទូទៅ ខណៈពេលដែលការ

ប្រើគណនេយ្យមូលដ្ឋានសាច់ប្រាក់ នៅមិនអាចផ្តល់ព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយពីស្ថានភាពហិរញ្ញវត្ថុក្នុងវិស័យសាធារណៈនៅឡើយទេ ជាពិសេស បន្ទាប់ពីមានកលយុគ្គនិងវិបត្តិហិរញ្ញវត្ថុសកលនារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលបាននិងកំពុងបន្តជះឥទ្ធិពលដល់បណ្តាប្រទេសជាច្រើននៅក្នុងសកលលោក។ បច្ចុប្បន្នតាមរយៈការណែនាំឱ្យប្រើស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ (IPSAS) និងការគាំទ្រដល់ដំណើរផ្លាស់ប្តូរទៅប្រើគណនេយ្យមូលដ្ឋានបង្គរដែលជាស្តង់ដាគណនេយ្យសម្រាប់វិស័យឯកជនអស់រយៈពេលច្រើនឆ្នាំមក រាជរដ្ឋាភិបាលបាននិងកំពុងធ្វើការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងបន្តជំរុញការកសាងសមត្ថភាពមន្ត្រីជំនាញគណនេយ្យរបស់រាជរដ្ឋាភិបាលឱ្យបានកាន់តែប្រសើរឡើងដើម្បីឈានដល់ការផ្លាស់ប្តូរទៅប្រើគណនេយ្យមូលដ្ឋានបង្គរ ផ្អែកតាមស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ។ វឌ្ឍនភាពទាំងនេះបានចូលរួមចំណែកដល់រាជរដ្ឋាភិបាលក្នុងការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព ហើយជាលទ្ធផលគុណភាពនិងភាពស៊ីជម្រៅនៃទិន្នន័យព្រមទាំងព័ត៌មានហិរញ្ញវត្ថុ ដែលរាជរដ្ឋាភិបាលកំពុងមាននាពេលបច្ចុប្បន្ន បានធ្វើឱ្យគុណភាពនៃរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ពាក់ព័ន្ធផ្សេងៗកាន់តែមានភាពល្អប្រសើរឡើងសម្រាប់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ។

**បុគ្គលិកលក្ខណៈនៃគណនេយ្យមូលដ្ឋានសាច់ប្រាក់ និងគណនេយ្យមូលដ្ឋានបង្គរ**

គណនេយ្យមូលដ្ឋានបង្គរ ត្រូវបានផ្អែកលើគោលការណ៍ថា ចំណូល, ចំណាយ និងគណនេយ្យសម្រាប់ទ្រព្យសកម្មនិងបំណុលពាក់ព័ន្ធ ឆ្លុះបញ្ចាំងពីប្រតិបត្តិការ ឬ ព្រឹត្តិការណ៍សេដ្ឋកិច្ចសំខាន់ៗ ជាជាងប្រតិបត្តិការឬព្រឹត្តិការណ៍ដែលត្រូវបានកត់ត្រា នៅពេលដែលស្ថាប័នបានទទួលសាច់ប្រាក់ឬបានទូទាត់សាច់-ប្រាក់។ ការផ្លាស់ប្តូរពីគណនេយ្យមូលដ្ឋានសាច់ប្រាក់ ទៅកាន់គណនេយ្យមូលដ្ឋានបង្គរ ជាប់ពាក់ព័ន្ធនឹង÷

- គណនេយ្យកម្មសម្រាប់ចំណូលនិងចំណាយ នៅពេលដែលចំណូលចំណាយនោះកើតឡើង ជាជាងនៅពេលដែលចំណូលត្រូវបានទទួល និងចំណាយត្រូវបានទូទាត់។
- ការប្រើប្រាស់និងការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុសំខាន់ៗទាំង ០៣ រួមមាន÷ របាយការណ៍លទ្ធផលហិរញ្ញវត្ថុ, របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងរបាយការណ៍លំហូរសាច់ប្រាក់។ នៅក្នុងគណនេយ្យមូលដ្ឋានសាច់ប្រាក់ របាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ គឺជារបាយការណ៍សំខាន់តែមួយគត់ដែលត្រូវបានដាក់បង្ហាញ។
- ការបង្កើតសមតុល្យ ដែលជាផ្នែកមួយនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដើមគ្រា។
- ការធ្វើប្រតិបត្តិការតាមមធ្យោបាយផ្សេងគ្នា និងនៅពេលវេលាខុសគ្នា។

## ជំពូកទី២
## គោលបំណង គោលដៅ និង វិសាលភាព

### ២.១. គោលបំណង

យុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរ មានគោលបំណងធានាបាននូវប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការអនុវត្តក្របខ័ណ្ឌរាយការណ៍ហិរញ្ញវត្ថុ និងស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរ នៅកម្ពុជា។

### ២.២. គោលដៅ

ឯកសារយុទ្ធសាស្ត្រនេះមានគោលដៅរៀបចំ អនុម័ត និងដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គររបស់រាជរដ្ឋាភិបាលកម្ពុជា ផ្អែកតាមស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ និងបរិបទជាក់ស្តែងរបស់កម្ពុជា ត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០៣១។

### ២.៣. វិសាលភាព

យុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរ មានវិសាលភាពគ្របដណ្តប់លើក្រសួង-ស្ថាប័នរដ្ឋបាលថ្នាក់ជាតិ និងអង្គភាពសាធារណៈប្រហាក់ប្រហែល។

យុទ្ធសាស្ត្រនេះ មិនមានវិសាលភាពគ្របដណ្តប់លើរដ្ឋបាលថ្នាក់ក្រោមជាតិ, គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ នោះទេ។

# ជំពូកទី៣
# វឌ្ឍនភាពនៃការកែទម្រង់រហូតមកដល់ពេលបច្ចុប្បន្ន

## ៣.១. សាវតារនៃកំណែទម្រង់

រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ក្នុងឆ្នាំ២០០៤ ក្នុងគោលដៅប្រែក្លាយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជាជាជំហានៗ ឱ្យទៅជាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយ ស្របតាមបទដ្ឋាន និងឧត្តមានុវត្តន៍ជាអន្តរជាតិ។ កម្មវិធីនេះត្រូវបានរៀបចំតាក់តែងឡើងជាការកែទម្រង់ក្នុងរយៈពេលវែង និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយកំណត់ជា ៤ ជំហាន និង ៤ ដំណាក់កាលបន្តបន្ទាប់។ ដំណាក់កាលទី១ (២០០៥-២០០៨) ផ្ដោតជាសំខាន់លើជំហានទី១ នៃកម្មវិធីកែទម្រង់ គឺការបង្កើនភាពជឿទុកចិត្តនៃថវិកា។ ដំណាក់កាលទី២ (២០០៩-២០១៥) ផ្ដោតលើជំហានទី២ គឺការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ស្របពេលនឹងការពង្រឹងបន្ថែមសមិទ្ធផលនៃជំហានទី១ និងការកសាងមូលដ្ឋានគ្រឹះសម្រាប់ជំហានទី៣។ ដំណាក់កាលទី៣ (២០១៦ -២០២០) ផ្ដោតលើជំហានទី៣ គឺការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ទន្ទឹមនឹងការពង្រឹងសមិទ្ធផលនៃជំហានពីរដំបូង និងការត្រួសត្រាយផ្លូវសម្រាប់ត្រៀមអនុវត្តជំហានទី៤។ ដំណាក់កាលទី៤ (២០២១-២០២៥)គឺផ្ដោតជាសំខាន់លើជំហានទី៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺការបង្កើនគណនេយ្យភាពសមិទ្ធកម្ម ទន្ទឹមនឹងការបន្តពង្រឹងសមិទ្ធផលដែលសម្រេចបានក្នុងជំហានទាំង៣ ខាងដើម។

រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលដឹកនាំដោយ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីទទួលខុសត្រូវលើការរៀបចំ ការអនុវត្ត និងការតាមដានការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ គណៈកម្មាធិការនេះមានអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានភារកិច្ចសម្របសម្រួលការអនុវត្តកម្មវិធីកែទម្រង់ទាំងមូល ហើយក្រសួង-ស្ថាប័នពាក់ព័ន្ធនីមួយៗ មានក្រុមការងារកែទម្រង់ ដែលដឹកនាំដោយថ្នាក់ដឹកនាំជា រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ ដើម្បីទទួលខុសត្រូវលើការងារកែទម្រង់ទៅតាមដែនសមត្ថកិច្ចរបស់ខ្លួន។ ការអនុវត្តសកម្មភាពកែទម្រង់ត្រូវបានចង្អុលបង្ហាញដោយផែនការសកម្មភាពរួម (CAP) សម្រាប់ដំណាក់កាលនីមួយៗ។ ការពិនិត្យឡើងវិញលើផែនការសកម្មភាពរួម ត្រូវបានធ្វើឡើងជាទៀងរាល់ឆ្នាំ ដោយអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងត្រូវបានដាក់ឆ្លងកិច្ចពិភាក្សានិងពិគ្រោះយោបល់ជាមួយ

ក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់។ ផែនការសកម្មភាពរួម ដំណាក់កាលទី១ (CAP 1) និងផែនការសកម្មភាពរួម ដំណាក់កាលទី២ (CAP 2) នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានបញ្ចប់ដោយជោគជ័យ។ ការវាយតម្លៃអំពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយផ្អែកលើក្របខ័ណ្ឌវង្វាស់សមិទ្ធកម្ម "ចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ" (PEFA) ត្រូវបានអនុវត្តនៅក្នុងឆ្នាំ២០១៥ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការចូលរួមផ្តល់យោបល់ពីទីប្រឹក្សាទទួលបន្ទុកការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំតំបន់នៃមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ព្រមទាំងជំនាញការមកពីក្រៅប្រទេសផ្សេងទៀតផងដែរ។ លទ្ធផលនៃការវាយតម្លៃនេះបានក្លាយជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការរៀបចំផែនការសកម្មភាពរួម ដំណាក់កាលទី៣ (CAP 3) ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការកាលពីដើមឆ្នាំ២០១៦ ហើយផែនការសកម្មភាពរួម ដំណាក់កាលទី៤ (CAP 4) បច្ចុប្បន្នកំពុងត្រូវបានរៀបចំ។ ការវាយតម្លៃអំពីចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុដែលត្រូវបានធ្វើបច្ចុប្បន្នភាពឡើងវិញ ក៏កំពុងត្រូវបានរៀបចំ ហើយគ្រោងនឹងបញ្ចប់រួចរាល់ត្រឹមខែមិថុនា ឆ្នាំ២០២០ ផងដែរ។

## ៣.២. ការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានសាច់ប្រាក់

ប្រកាសលេខ ៥៤៥ សហវ-ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាលពីថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៩។ ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ (Cash Basis CPSAS) ត្រូវបានអនុម័តទាំងស្រុងពីស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈមូលដ្ឋានសាច់ប្រាក់ (Cash Basis IPSAS)។ មុនការប្រកាសដាក់ឱ្យអនុវត្តនេះ អគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសិក្សានិងរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយប្រើស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈមូលដ្ឋានសាច់ប្រាក់ ចាប់តាំងពីឆ្នាំ២០១៦ រួចមកហើយ។ របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំនេះត្រូវបានឆ្លងកាត់ការត្រួតពិនិត្យ និងផ្តល់យោបល់ពីក្រុមអ្នកជំនាញ-ការនៃធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិផងដែរ។ ជាទូទៅ របាយការណ៍ហិរញ្ញវត្ថុរំពឹងថានឹងត្រូវបានចេញផ្សាយនៅក្នុងអំឡុងរយៈពេល ០៦ ខែ ស្របតាមស្តង់ដា។ ភាគច្រើននៃដំណាក់កាលនៃការអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ អាស្រ័យលើលក្ខខណ្ឌដាច់ដោយឡែកចំនួនពីរ គឺ÷

១. ភាពរួចរាល់នៃទិន្នន័យ ដែលមានភាពត្រឹមត្រូវ និងអាចជឿទុកចិត្តបាន និង

២. ភាពរួចរាល់នៃទិន្នន័យហិរញ្ញវត្ថុរបស់ជាតិ ក្រោមវិសាលភាពនៃកំណែទម្រង់។

ចាប់តាំងពីឆ្នាំ២០១៦, របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅរបស់រាជរដ្ឋាភិបាលកម្ពុជា មាន របាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ ដូចបានតម្រូវដោយស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់។ របាយការណ៍នេះបង្ហាញពីចំណូលសាច់ប្រាក់និងចំណាយសាច់ប្រាក់ជាក់ស្តែងនៃប្រតិបត្តិការរបស់រាជរដ្ឋាភិបាលកម្ពុជា និងឆ្លុះបញ្ចាំងពីចំណាត់ថ្នាក់សេដ្ឋកិច្ចដែលស្រដៀងគ្នាទៅនឹងផែនការថវិកាជាតិដែរ។ បន្ថែមពីនេះ របាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ ក៏បានដាក់បង្ហាញអំពី÷

- របាយការណ៍លំហូរសាច់ប្រាក់ សម្រាប់រដ្ឋបាលថ្នាក់ជាតិ និង
- របាយការណ៍ប្រៀបធៀបរវាងតួលេខថវិកា និងតួលេខអនុវត្តជាក់ស្តែង សម្រាប់ចំណូលថវិកា និងចំណាយថវិកា។

ដោយមានការគាំទ្រពីអ្នកជំនាញការ របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំដោយគណនេយ្យករសាធារណៈ មានភាពល្អប្រសើរឡើងជារៀងរាល់ឆ្នាំ ទាក់ទងនឹងការលាតត្រដាងនិងការដាក់បង្ហាញព័ត៌មានហិរញ្ញវត្ថុ ស្របតាមស្តង់ដាអន្តរជាតិ។ ជាខ្លឹមសារបច្ចេកទេស, ស្តង់ដា Cash Basis CPSAS ដូចគ្នាទាំងស្រុងទៅនឹងស្តង់ដា Cash Basis IPSAS ។ ទោះជាយ៉ាងណាក៏ដោយ គណនេយ្យករសាធារណៈពុំទាន់អាចរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អនុលោមតាមរាល់លក្ខខណ្ឌតម្រូវចាំបាច់នានាដែលមានចែងក្នុងស្តង់ដាគណនេយ្យសាធារណៈនៅឡើយ ដោយសារកត្តាច្បាប់, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, និងធនធានមនុស្ស។

ការបណ្តុះបណ្តាលស្តីពីស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់ ត្រូវបានរៀបចំសម្រាប់មន្ត្រីជំនាញរបស់អគ្គនាយកដ្ឋានរតនាគារជាតិ ដោយក្រុមគ្រូបង្គោលរបស់និយ័តករគណនេយ្យនិងសវនកម្ម ជាបន្តបន្ទាប់តាមផែនការដែលបានកំណត់ រហូតមន្ត្រីជំនាញពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាលទទួលបានការបណ្តុះបណ្តាលលើស្តង់ដាគណនេយ្យនេះ។

## ៣.៣ កំណែទម្រង់ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ

ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងប្រទេសកម្ពុជា កំពុងស្ថិតក្រោមការពិនិត្យឡើងវិញ។ បច្ចុប្បន្ន ច្បាប់គាំទ្រដល់ការអនុវត្តស្តង់ដាគណនេយ្យមូលដ្ឋានសាច់ប្រាក់។ នៅពេលការផ្លាស់ប្តូរទៅកាន់ស្តង់ដាគណនេយ្យមូលដ្ឋានបង្គរត្រូវបានដាក់ឱ្យអនុវត្ត, ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ចាំបាច់ត្រូវបានកែសម្រួលដើម្បីគាំទ្រដល់ការអនុវត្តស្តង់ដាគណនេយ្យមូលដ្ឋានបង្គរ ដោយត្រូវមានការិយបរិច្ឆេទអន្តរកាលជាក់លាក់ ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់និងចាំបាច់ក្នុងការអនុវត្តស្តង់ដាគណនេយ្យបង្គរថ្មីៗទាំងនេះ។

សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី ត្រូវបានរំពឹងថានឹងរៀបចំរួចរាល់សម្រាប់ដាក់ឱ្យរដ្ឋសភាពិនិត្យ និងអនុម័តត្រឹមខែធ្នូ ឆ្នាំ២០២១។

## ៣.៤ ការដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ការដាក់ឱ្យអនុវត្តប្រព័ន្ធ Oracle Peoplesoft FMIS ថ្មី កំពុងដំណើរការបានយ៉ាងល្អ និងអាចជួយដោះស្រាយបញ្ហាប្រឈមជាច្រើនដែលកំពុងតែជួបប្រទះ។

បច្ចុប្បន្ន ក្រសួង-ស្ថាប័ន, រតនាគាររាជធានី-ខេត្ត ក៏ដូចជាមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ភាគច្រើនបាននិងកំពុងប្រើប្រាស់ប្រព័ន្ធ FMIS។ ក្រសួង-ស្ថាប័នដែលនៅសេសសល់ផ្សេងទៀត រំពឹងថានឹងអាចប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការនៅក្នុងឆ្នាំ២០២១។

បច្ចុប្បន្ន រតនាគាររាជធានី-ខេត្ត បញ្ចូលប្រតិបត្តិការសម្រាប់ឃុំ/សង្កាត់ និងគ្រប់គ្រងគណនីប្រាក់បញ្ញើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (ទទួលខុសត្រូវលើការកត់ត្រាចំណូលថ្នាក់ក្រោមជាតិ, ការផ្ទៀងផ្ទាត់ធនាគារ និងចំណាយថ្នាក់ក្រោមជាតិទាំងអស់)។ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បញ្ចូលប្រតិបត្តិការសម្រាប់មន្ទីរជំនាញនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ សាលារាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ។

បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលមានគម្រោងរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់តែរដ្ឋបាលថ្នាក់ជាតិប៉ុណ្ណោះ។ ដោយឡែក ក្រសួង-ស្ថាប័ននឹងមិនរៀបចំរបាយការណ៍ហិរញ្ញវត្ថុផ្ទាល់ខ្លួនសម្រាប់អនាគតដ៏ខ្លីខាងមុខឡើយ ដោយសារអគ្គនាយកដ្ឋានរតនាគារជាតិគឺជាគណនេយ្យករសាធារណៈតែមួយគត់របស់រដ្ឋ។ ដូច្នេះ ពុំទាន់មានបទដ្ឋានគតិយុត្តផ្សេងៗដែលតម្រូវឱ្យក្រសួង-ស្ថាប័នរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយខ្លួនឯងទេ។ អគ្គនាយកដ្ឋានរតនាគារជាតិ នឹងបន្តពង្រីកវិសាលភាព និងសុក្រឹតភាពនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ទៅតាមលក្ខខណ្ឌតម្រូវនៃច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន។

ប្រព័ន្ធ FMIS ត្រូវបានរៀបចំរចនាសម្ព័ន្ធសម្រាប់អនុវត្តគណនេយ្យមូលដ្ឋានបង្គរ ហើយនីតិវិធីការងារដែលរាជរដ្ឋាភិបាលកំពុងមាននាពេលបច្ចុប្បន្ននេះ មិនទាន់អាចគាំទ្រដល់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុមូលដ្ឋានបង្គរ នៅឡើយទេ។ ទោះបីជាយ៉ាងនេះក្តី ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានចាប់ផ្តើមរៀបចំរចនាសម្ព័ន្ធដើម្បីផលិតរបាយការណ៍ចំណូលនិងចំណាយសាច់ប្រាក់ រួចមកហើយ។

ការងារកែទម្រង់មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ប៉ុន្តែគណនីទោលរតនាគារនៅមិនទាន់អាចបំពេញមុខងារបានពេញលេញនៅឡើយទេ។ ការផ្ទេរសាច់ប្រាក់ (បុរេប្រទាន) បន្តត្រូវបានធ្វើឡើងទៅកាន់

គណនីធនាគារដែលគ្រប់គ្រងដោយក្រសួង និងរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយចំណាយត្រូវបានទូទាត់ដោយផ្ទាល់ទៅកាន់អ្នកផ្គត់ផ្គង់តាមរយៈម្ចាស់គណនីធនាគារ ហើយការចុះបញ្ជីគណនេយ្យពាក់ព័ន្ធត្រូវបានធ្វើឡើងក្រោយហេតុការណ៍បានកើតឡើង ដោយអគ្គនាយកដ្ឋានរតនាគារជាតិ។ ការកត់ត្រារបៀបនេះគឺត្រូវបានអនុវត្តលើប្រតិបត្តិការភាគច្រើនដោយអគ្គនាយកដ្ឋានរតនាគារជាតិផងដែរ។ ដំណើរការនៃការរៀបចំមុខងារគ្រប់គ្រងផែនការថវិកានៅក្នុងប្រព័ន្ធ FMIS កំពុងស្ថិតក្រោមការអភិវឌ្ឍនៅឡើយ។

ការរៀបចំផែនការថវិកា និងដំណោះស្រាយលទ្ធកម្មពេញលេញ នឹងត្រូវបានរៀបចំក្នុងឆ្នាំ២០២១ ហើយរំពឹងថានឹងអាចរាយការណ៍ចាប់ពីខែមករា ឆ្នាំ២០២២ តទៅ។ ត្រឹមឆ្នាំ២០២៣ ប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ដែលបានបង្កើតឡើងដោយអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ រំពឹងថានឹងដាក់ឱ្យដំណើរការផ្សារភ្ជាប់ជាមួយនឹងប្រព័ន្ធ FMIS។ បច្ចុប្បន្នកម្មវិធីនេះត្រូវបានប្រើក្នុងគោលបំណងគ្រប់គ្រងបញ្ជីសារពើភណ្ឌនៃទ្រព្យសកម្មរយៈពេលវែងហើយរំពឹងថានឹងត្រូវបានអភិវឌ្ឍជាមួយមុខងារគ្រប់គ្រងទ្រព្យសកម្មឱ្យបានពេញលេញ ត្រឹមឆ្នាំ២០២៤។

ប្លង់គណនេយ្យ រួមមាន ០៧ ចំណាត់ថ្នាក់÷ ចំណាត់ថ្នាក់អង្គភាពប្រតិបត្តិនិងរដ្ឋបាល, ចំណាត់ថ្នាក់ភូមិសាស្ត្រ, ចំណាត់ថ្នាក់សេដ្ឋកិច្ច, ចំណាត់ថ្នាក់កម្មវិធី, ចំណាត់ថ្នាក់មុខងារ, ចំណាត់ថ្នាក់គម្រោង និងចំណាត់ថ្នាក់មូលនិធិ។ ចំណាត់ថ្នាក់ទាំងនេះ ជាទូទៅ ត្រូវបានរៀបចំយ៉ាងល្អ ប៉ុន្តែនៅមានការងារមួយចំនួនដែលត្រូវធ្វើ ជាពិសេស ការកែសម្រួលលេខកូដសេដ្ឋកិច្ច និងផ្នែកនៃកម្មវិធី ដើម្បីឱ្យមានភាពងាយស្រួលក្នុងការកត់ចំណាំ និងអនុវត្ត។

ក្នុងបរិបទនៃការអនុវត្តប្រព័ន្ធ FMIS, ការយកចិត្តទុកដាក់ជាពិសេសលើការគ្រប់គ្រងការផ្លាស់ប្តូរដើម្បីកំណត់ពីអន្តរាគមន៍ពាក់ព័ន្ធផ្សេងៗ ដែលរាជរដ្ឋាភិបាលត្រូវធ្វើតាមដំណាក់កាលផ្សេងៗនៃការអនុវត្តប្រព័ន្ធ FMIS គឺជារឿងចាំបាច់ដែលត្រូវធ្វើ។ ការសិក្សាដែលធ្វើឡើងដោយភ្នាក់ងារពហុភាគីបានបង្ហាញថាភាគច្រើននៃបញ្ហាប្រឈមដែលកើតឡើងទូទៅចំពោះកម្មវិធីផ្លាស់ប្តូរបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ទ្រង់ទ្រាយធំ គឺពាក់ព័ន្ធនឹងកត្តាមនុស្ស ជាពិសេស ភាពជាអ្នកដឹកនាំ, វប្បធម៌របស់ស្ថាប័ននិងបញ្ហាទាក់ទងនឹងអ្នកប្រើប្រាស់។ ដើម្បីធ្វើឱ្យការអនុវត្តកម្មវិធីផ្លាស់ប្តូរមួយទទួលបានជោគជ័យ ស្ថាប័នចាំបាច់ត្រូវដោះស្រាយបញ្ហាទាំងនេះជាមុនសិនក្នុងដំណាក់កាលដំបូងៗនៃការបង្កើតកម្មវិធីទាំងមូល។ សកម្មភាពដែលត្រូវអនុវត្តរួមមាន÷ ការទំនាក់ទំនង, ការចូលរួមរបស់ភាគីពាក់ព័ន្ធ, ការគ្រប់គ្រងការផ្លាស់ប្តូរ និងការបណ្តុះបណ្តាលក៏ដូចជាការវាយតម្លៃពីការត្រៀមលក្ខណៈសម្រាប់ការផ្លាស់ប្តូរ និងការទទួលយកការផ្លាស់ប្តូរ។

## ជំពូកទី៤
## ទិសដៅកំណែទម្រង់

### ៤.១. ការអភិវឌ្ឍស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរ

និយ័តករគណនេយ្យនិងសវនកម្ម នឹងពិនិត្យ សិក្សា និងរៀបចំស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរ ដោយផ្អែកលើស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈជាគោល និងអាចប្រើស្តង់ដាគណនេយ្យរបស់ប្រទេសដទៃទៀតសម្រាប់ធ្វើជាមូលដ្ឋាននៃការប្រៀបធៀប។

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ មានស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈចំនួន ៣៥ ស្តង់ដា ដែលចាំបាច់ត្រូវអនុម័តដាក់ឱ្យប្រើ ឬ កែសម្រួល និងបកប្រែមកជាខេមរភាសាសម្រាប់ស្តង់ដាគណនេយ្យជាតិរបស់កម្ពុជា។ ការអភិវឌ្ឍស្តង់ដាគណនេយ្យដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ (IPSASB) គឺជាកិច្ចដំណើរការមានលក្ខណៈជាប្រចាំដែលជំរុញដោយតម្រូវការរបស់សាធារណជនទូទៅ ដូច្នេះក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈអាចនឹងចេញផ្សាយស្តង់ដាបន្ថែមទៀត ក្រោយពេលដែលយុទ្ធសាស្ត្រនេះត្រូវបានដាក់ឱ្យអនុវត្ត។ ដូចនេះ និយ័តករគណនេយ្យនិងសវនកម្ម នឹងតាមដានការអភិវឌ្ឍទាំងនេះជាប្រចាំដើម្បីធានាថា ស្តង់ដាថ្មីៗនឹងត្រូវបានយកមកពិចារណាសម្រាប់ការដាក់ឱ្យអនុវត្ត តាមស្ថានភាពជាក់ស្តែងរបស់កម្ពុជា។

ការអភិវឌ្ឍស្តង់ដា ត្រូវការជាចាំបាច់នូវការចូលរួមពិភាក្សានិងការវិភាគដោយស្ថាប័នពាក់ព័ន្ធនៅក្នុងរាជរដ្ឋាភិបាលកម្ពុជា (ដូចជា និយ័តករគណនេយ្យនិងសវនកម្ម, អគ្គនាយកដ្ឋានរតនាគារជាតិ, អាជ្ញាធរសវនកម្មជាតិ, ក្រសួង-ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល– សូមមើលជំពូកទី៦÷ ការគ្រប់គ្រងគម្រោង)។ ការងារនេះត្រូវបានព្យាករណ៍ថានឹងអាចស្វែងរកការប្រឹក្សាយោបល់និងជំនួយបច្ចេកទេសពីបណ្តាដៃគូអភិវឌ្ឍន៍នានា ដូចជា សហភាពអឺរ៉ុប និងមូលនិធិរូបិយវត្ថុអន្តរជាតិ ជាដើម។

### ៤.២. ការកសាងសមត្ថភាព ការគ្រប់គ្រងការផ្លាស់ប្តូរ និងការទំនាក់ទំនងសម្រាប់អនុវត្តស្តង់ដាគណនេយ្យ មូលដ្ឋានបង្គរ

វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា (KICPAA) គឺជាស្ថាប័នវិជ្ជាជីវៈគណនេយ្យនិងសវនកម្មរបស់ជាតិតែមួយគត់នៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងការពារផលប្រយោជន៍សាធារណៈ និងតម្លៃវិជ្ជាជីវៈជំនាញ, គ្រប់គ្រងសមាជិករបស់ខ្លួនតាមរយៈការអភិវឌ្ឍសមត្ថភាព

វិជ្ជាជីវៈ និងការពង្រឹងអនុលោមភាពទៅតាមស្តង់ដាបច្ចេកទេស, ក្រមសីលធម៌វិជ្ជាជីវៈ, វិធាន និងបទប្បញ្ញត្តិនានា។ វិទ្យាស្ថានមានភារកិច្ចទទួលខុសត្រូវលើការចុះឈ្មោះសមាជិក និងគ្រប់គ្រងសមាជិក ខណៈដែលនិយ័តករគណនេយ្យនិងសវនកម្ម គឺជានិយ័តករគ្រប់គ្រងលើវិស័យគណនេយ្យនិងសវនកម្មតែមួយគត់នៅក្នុងប្រទេសកម្ពុជា ដែលមានភារកិច្ចកំណត់ស្តង់ដាគណនេយ្យនិងស្តង់ដាសវនកម្ម ក៏ដូចជាផ្តល់អាជ្ញាបណ្ណដល់សមាជិកនៃវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជាទាំងឡាយណា ដែលមានបំណងប្រកបវិជ្ជាជីវៈគណនេយ្យ និង/ឬ សវនកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្ន វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា កំពុងផ្តោតលើការអភិវឌ្ឍជំនាញគណនេយ្យនិងសវនកម្មនៅក្នុងវិស័យឯកជនតាមរយៈកម្មវិធីអប់រំគណនេយ្យជំនាញ។ ដោយឡែក និយ័តករគណនេយ្យនិងសវនកម្មបាននិងកំពុងយកចិត្តទុកដាក់លើសកម្មភាពបណ្តុះបណ្តាលរបស់ខ្លួន ស្តីពីស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ជូនដល់មន្ត្រីនៃស្ថាប័នសាធារណៈ ជាពិសេស មន្ត្រីអគ្គនាយកដ្ឋានរតនាគារជាតិ។ កិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័នទាំងពីរ នឹងធ្វើឡើងជាបន្តបន្ទាប់ដើម្បីធានាថានឹងមិនមានការរំខាន ឬ គម្លាតណាមួយក្នុងសកម្មភាពបណ្តុះបណ្តាល ឬ ការទទួលបានចំណេះដឹងឡើយ។

កង្វះខាតជំនាញគណនេយ្យគឺជាបញ្ហាប្រឈមចម្បងមួយសម្រាប់រាជរដ្ឋាភិបាលកម្ពុជា។ សព្វថ្ងៃនេះរាជរដ្ឋាភិបាលមានគណនេយ្យករជំនាញតិចតួចកំពុងបម្រើការងារនៅក្នុងវិស័យសាធារណៈ ហើយនីតិវិធីការងារដែលបានកំពុងអនុវត្ត ក៏មិនទាន់អាចគាំទ្រដល់ភាពស្មុគស្មាញនៃគណនេយ្យរបស់រាជរដ្ឋាភិបាលនៅឡើយដែរ។ ការដាក់ឱ្យប្រើប្រព័ន្ធ FMIS ដោយមិនមានការគាំទ្រពីផ្នែកគណនេយ្យត្រឹមត្រូវអាចប្រឈមនឹងហានិភ័យយ៉ាងច្រើនសម្រាប់ភាពត្រឹមត្រូវ និងសង្គតិភាពនៃរបាយការណ៍ហិរញ្ញវត្ថុ។ រាជរដ្ឋាភិបាលនឹងប្រកាន់យកវិធីសាស្ត្រម៉ឺងម៉ាត់និងគត់មត់ ដើម្បីទទួលបានជំនាញចាំបាច់ទាំងនេះ ដែលជាបញ្ហាបន្ទាន់ដែលរាជរដ្ឋាភិបាលត្រូវធ្វើ។

បន្ថែមពីនេះទៀត ឯកសារយោងគួរត្រូវបានភ្ជាប់ជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពនៅក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ដំណាក់កាលទី៣) ដែលបានរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នាខែធ្នូ ឆ្នាំ២០១៧ ដែលបានចាត់ទុកការអភិវឌ្ឍជំនាញគណនេយ្យនិងជំនាញគ្រប់គ្រងហិរញ្ញវត្ថុជាគោលបំណងគន្លឹះមួយក្នុងចំណោមគោលបំណងគន្លឹះសំខាន់ៗជាច្រើនទៀត។

### ៤.៣. ការរៀបចំសមតុល្យដើមគ្រានៃទ្រព្យសកម្មរយៈពេលវែង សម្រាប់ការអនុវត្តស្តង់ដាគណនេយ្យមូលដ្ឋានបង្គរ

### ៤.៣.១. ទ្រព្យសកម្មរយៈពេលវែង

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ មានភារកិច្ចទទួលខុសត្រូវលើការគ្រប់គ្រងបញ្ជីសារពើភណ្ឌនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុទាំងអស់របស់រដ្ឋ។ សម្រាប់គោលបំណងនៃការកត់ត្រា អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ បានធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ជា ៤ ប្រភេទ ដូចខាងក្រោម÷

១. ដី និងអគារ

២. ម៉ាស៊ីន និងបរិក្ខារ (រួមបញ្ចូលទាំងបរិក្ខារព័ត៌មានវិទ្យា)

៣. គ្រឿងសង្ហារឹម

៤. យានយន្ត។

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ នឹងរៀបចំកម្មវិធីសិក្ខាសាលាជាច្រើនដែលនឹងគ្របដណ្តប់គ្រប់ក្រសួងនិងភ្នាក់ងាររាជរដ្ឋាភិបាលទាំងអស់ ដែលជាស្ថាប័នប្រមូលផ្តុំទិន្នន័យអំពីទ្រព្យសកម្មចម្បងទាំងអស់របស់រដ្ឋ។ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ បានរៀបចំទម្រង់ ដើម្បីកត់ត្រាទិន្នន័យពាក់ព័ន្ធទាំងអស់សម្រាប់ទ្រព្យសកម្មនីមួយៗ និងប្រភេទនៃទ្រព្យសកម្ម។ ទិន្នន័យទាំងនេះនឹងរួមបញ្ចូលថ្លៃដើមប្រវត្តិសាស្ត្រ (ដោយវិក្កយបត្រ ឬ ដោយភស្តុតាងផ្សេងទៀត), ការវាយ-តម្លៃការប្រើប្រាស់បច្ចុប្បន្ន (ផ្តល់ដោយការវាយតម្លៃវិជ្ជាជីវៈ) ឬ ថ្លៃដើមជំនួស (ដោយទីផ្សារ)។ ទិន្នន័យផ្សេងទៀត រួមបញ្ចូលនូវការប្រើប្រាស់បច្ចុប្បន្ន, ទីតាំងបច្ចុប្បន្ន និងទិន្នន័យពាក់ព័ន្ធផ្សេងទៀតសម្រាប់គោល-បំណងគណនេយ្យ និងការកត់ត្រា។

ផ្តើមចេញពីសិក្ខាសាលា អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នឹងបញ្ចូលទិន្នន័យដោយដៃចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងរៀបចំសេចក្តីព្រាងបញ្ជីសារពើភណ្ឌដំបូងនៃទ្រព្យសកម្មរយៈពេលវែង។ បញ្ជីសារពើភណ្ឌនេះនឹងត្រូវបានធ្វើបច្ចុប្បន្នភាពឡើងវិញដោយដៃសម្រាប់ការបន្ថែម ឬ ការលក់ និងការផ្លាស់ប្តូរការវាយតម្លៃ ឬ ទីតាំងផ្សេងៗរហូតដល់ឆ្នាំ២០២២ ឬ ឆ្នាំ២០២៣ នៅពេលដែលប្រព័ន្ធត្រូវបានដាក់ឱ្យដំណើរការ និងផ្សារភ្ជាប់ជាមួយនឹងប្រព័ន្ធ FMIS។

ផែនការដើម្បីធានាឱ្យបាននូវភាពពេញលេញ, ភាពត្រឹមត្រូវ និងគុណភាពនៃទិន្នន័យទ្រព្យសកម្មរយៈពេលវែងដែលផ្តល់ដោយក្រសួង-ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែលទៅកាន់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មិនទាន់មាននៅឡើយទេ។ ផែនការនេះនឹងត្រូវចូលរួមសហការ

រៀបចំជាមួយអង្គភាពសវនកម្មផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ក៏ដូចជាអាជ្ញាធរសវនកម្មជាតិ មុនពេលដែលទិន្នន័យត្រូវបានប្រើប្រាស់ដើម្បីបង្កើតជាផ្នែកមួយនៃសមតុល្យដើមគ្រាមូលដ្ឋានបង្គរ។ ដោយមានការចូលរួមគាំទ្រពីអគ្គនាយកដ្ឋានរតនាគារជាតិ កិច្ចខិតខំប្រឹងប្រែងនេះនឹងត្រូវបានធ្វើឡើងដើម្បីផ្ទៀងផ្ទាត់ និងធ្វើឱ្យមានសុពលភាពនូវទិន្នន័យដែលទទួលបានពីកំណត់ត្រាគណនេយ្យដែលមានស្រាប់ និងជាមួយនឹងអង្គភាពរាជរដ្ឋាភិបាលផ្សេងទៀត (ឧទាហរណ៍ ការចុះបញ្ជីយានយន្ត និងនាយកដ្ឋានចុះបញ្ជីដីធ្លី ជាដើម)។

បន្ថែមពីនេះ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ក៏បានស្នើសុំឱ្យមានអ្នកជំនាញការផ្នែកគ្រប់គ្រងទ្រព្យសកម្មរយៈពេលវែងដើម្បីចូលរួមជួយគាំទ្រសម្រាប់ការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យសម្រាប់ទ្រព្យសកម្មរយៈពេលវែងទាំងអស់នាពេលអនាគត។ សកម្មភាពទាំងអស់នេះ និងសកម្មភាពផ្សេងទៀតពាក់ព័ន្ធនឹងការអភិវឌ្ឍស្តង់ដាគណនេយ្យសាធារណៈ មូលដ្ឋានបង្គរគួរត្រូវបានពិចារណាដើម្បីដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី៤ (CAP 4)។

### ៤.៣.២. កម្ចី

បច្ចុប្បន្ន ដូចគ្នានឹងរដ្ឋបាលថ្នាក់ជាតិដែរ អង្គភាពដែលទទួលបានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍រៀបចំរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានសាច់ប្រាក់ រួចបញ្ជូនមកអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (GDICDM) និងអគ្គនាយកដ្ឋានរតនាគារជាតិ។ ទោះបីជាយ៉ាងណា ប្រព័ន្ធ DMFAS ជំនាន់ទី៦ របស់អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល អាចគាំទ្របានពេញលេញសម្រាប់គណនេយ្យមូលដ្ឋានបង្គរ ហើយរបាយការណ៍ស្រដៀងគ្នានេះដែលផ្អែកតាមគណនេយ្យមូលដ្ឋានបង្គរ គឺត្រូវបានរៀបចំរួចរាល់និងរាយការណ៍ជាទៀងទាត់ជូនថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរាជរដ្ឋាភិបាល។ ប្រព័ន្ធ DMFAS ក៏អាចផ្សារភ្ជាប់ជាមួយនឹងប្រព័ន្ធ FMIS បានផងដែរ ដែលនឹងធ្វើឱ្យដំណើរឆ្លោះទៅកាន់គណនេយ្យមូលដ្ឋានបង្គរ និងការចាប់ផ្តើមតុល្យការដំបូងកាន់តែមានភាពងាយស្រួល។

## ៤.៤. ដំណាក់កាលនៃការអនុវត្តស្តង់ដាគណនេយ្យសាធារណៈ




គ្រប់ដំណាក់កាលទាំងអស់ គណនេយ្យករសាធារណៈត្រូវធានាថា ខ្លួនអាចសម្រេចបាននូវលក្ខខណ្ឌចាំបាច់ជាអប្បបរមា មុនពេលបន្តទៅកាន់ដំណាក់កាលបន្ទាប់។ ឧទាហរណ៍ មុនពេលបន្តទៅកាន់ដំណាក់កាលទី២÷មូលដ្ឋានសាច់ប្រាក់កែសម្រួល គណនេយ្យករសាធារណៈត្រូវបញ្ជាក់ថា ៩០ ភាគរយ នៃស្ថាប័នរាជរដ្ឋាភិបាលដែលបានចូលរួមទាំងអស់ ផ្អែកតាមវិភាជន៍ថវិកានិងតួលេខ បានអនុលោមពេញលេញទៅតាមស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានសាច់ប្រាក់ និងការអនុវត្តប្រព័ន្ធ FMIS។

បន្ថែមពីនេះ រាជរដ្ឋាភិបាលដឹងថាការអនុវត្តការលើកលែងក្នុងពេលអន្តរកាលដូចបានកំណត់ក្នុងស្តង់ដាគណនេយ្យ IPSAS ៣៣ នឹងជះឥទ្ធិពលដល់កម្រិតអនុលោមភាពនៃរបាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដា IPSAS ដូចនេះ រាជរដ្ឋាភិបាលនឹងធ្វើការសម្រេចចិត្តដោយប្រុងប្រយ័ត្ននិងហ្មត់ចត់ ដោយផ្អែកលើស្ថានភាពជាក់ស្តែង និងភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានដែលអាចប្រមូលបានក្នុងការដាក់ឱ្យអនុវត្តការលើកលែងក្នុងពេលអន្តរកាល នៃដំណើរឆ្ពោះទៅកាន់ការអនុវត្តគណនេយ្យមូលដ្ឋានបង្គរ។

តារាងខាងក្រោមបង្ហាញអំពីបន្ទាត់ពេលវេលាសម្រាប់ដំណាក់កាលនីមួយៗ និងស្តង់ដាដែលនឹងត្រូវអនុវត្ត ដោយផ្អែកលើស្តង់ដា IPSAS ដែលអនុវត្តជាលើកដំបូង។

### ៤.៤.១. ដំណាក់កាលទី១÷ គណនេយ្យមូលដ្ឋានសាច់ប្រាក់

ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ នាខែកញ្ញា ឆ្នាំ២០១៩ ហើយអគ្គនាយកដ្ឋានរតនាគារជាតិបានប្រើស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ មូលដ្ឋានសាច់ប្រាក់ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ចាប់ពីឆ្នាំ២០១៦ មក។

| ២០១៩-២០២០ | ២០២១ | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|---|
| អនុវត្តលក្ខខណ្ឌចាំបាច់ទាំងអស់នៃស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់<br><br>បញ្ចប់ការរៀបចំគោលនយោបាយគណនេយ្យ | ធានាថារបាយការណ៍ហិរញ្ញវត្ថុរបស់ក្រសួង-ស្ថាប័នរដ្ឋបាលថ្នាក់ជាតិ និងអង្គភាពសាធារណៈប្រហាក់-ប្រហែល ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ | រៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលអនុលោមពេញលេញតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ | រៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលអនុលោមពេញលេញតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ | រៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលអនុលោមពេញលេញតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ |
| **ស្តង់ដាដែលត្រូវអនុវត្ត÷**<br>- ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ | **ស្តង់ដាដែលត្រូវអនុវត្ត÷**<br>- ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់<br>**ស្តង់ដាដែលត្រូវស្នើសុំ÷**<br>- ផលរបរពីប្រតិបត្តិការដោះដូរ | **ស្តង់ដាដែលត្រូវអនុវត្ត÷**<br>- ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់<br><br>**ស្តង់ដាដែលត្រូវចេញផ្សាយ÷**<br>- ផលរបរពីប្រតិបត្តិការដោះដូរ | | |

| | | | | |
|---|---|---|---|---|
| | - ផលរបរពីប្រតិបត្តិការមិនមែនដោះដូរ (ពន្ធ និងការផ្ទេរ)<br>- ចំណាយមិនមែនដោះដូរ។ | - ផលរបរពីប្រតិបត្តិការមិនមែនដោះដូរ (ពន្ធ និងការផ្ទេរ)<br>- ចំណាយមិនមែនដោះដូរ។ | | |

### ៤.៤.២. ដំណាក់កាលទី២÷ គណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល

បច្ចុប្បន្ន ការអនុវត្តប្រព័ន្ធ FMIS និងសកម្មភាពបណ្តុះបណ្តាលចាំបាច់នានាសម្រាប់គណនេយ្យករ និងអ្នកកាន់បញ្ជីគណនេយ្យ អាចនឹងមិនត្រូវបានបញ្ចប់រួចរាល់ត្រឹមចុងឆ្នាំ២០២១ ដែលជាកាលបរិច្ឆេទគ្រោងទុកក្នុងការអនុវត្តស្តង់ដាមូលដ្ឋានសាច់ប្រាក់ពេញលេញនោះទេ។ ការអនុវត្តស្តង់ដាមូលដ្ឋានបង្គរ មិនទាន់អាចចាប់ផ្តើមបាននៅឡើយទេ លុះត្រាតែការអនុវត្តប្រព័ន្ធ FMIS និងសកម្មភាពបណ្តុះបណ្តាលចាំបាច់នានាសម្រាប់គណនេយ្យករ និងអ្នកកាន់បញ្ជីគណនេយ្យ ត្រូវបានបំពេញរួចរាល់ជាមុនសិន។ ឆ្នាំទី១ (ឆ្នាំ២០២៥) អាចនឹងចាប់ផ្តើម នៅពេលដែលយើងអាចបំពេញបាននូវលក្ខខណ្ឌចាំបាច់អប្បបរមា ទាំងសម្រាប់ប្រព័ន្ធ FMIS និងសមត្ថភាពផ្នែកគណនេយ្យ។

| ឆ្នាំ ២០២៥ | ឆ្នាំ ២០២៦ | ឆ្នាំ ២០២៧ |
|---|---|---|
| -មូលដ្ឋានសាច់ប្រាក់<br>-គណនីត្រូវទទួល<br>-គណនីត្រូវសង | -មូលដ្ឋានសាច់ប្រាក់<br>-គណនីត្រូវទទួល<br>-គណនីត្រូវសង | -មូលដ្ឋានសាច់ប្រាក់<br>-គណនីត្រូវទទួល<br>-គណនីត្រូវសង |
| **ស្តង់ដាដែលត្រូវអនុវត្តនៅក្នុងការិយបរិច្ឆេទនេះ÷**<br>- ផលរបរពីប្រតិបត្តិការដោះដូរ<br>- ផលរបរពីប្រតិបត្តិការមិនមែនដោះដូរ (ពន្ធ និងការផ្ទេរ)<br>- ចំណាយមិនមែនដោះដូរ<br>- ព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍<br>- ការលាតត្រដាងអំពីភាគីពាក់ព័ន្ធ។ | | |

### ៤.៤.៣. ដំណាក់កាលទី៣÷ គណនេយ្យមូលដ្ឋានបង្គរកែសម្រួល

| ឆ្នាំ ២០២៨ | ឆ្នាំ ២០២៩ | ឆ្នាំ ២០៣០ |
|---|---|---|
| -មូលដ្ឋានសាច់ប្រាក់<br>-គណនីត្រូវទទួល<br>-គណនីត្រូវសង<br>-ទ្រព្យសកម្មហិរញ្ញវត្ថុ<br>-បំណុលហិរញ្ញវត្ថុ | -មូលដ្ឋានសាច់ប្រាក់<br>-គណនីត្រូវទទួល<br>-គណនីត្រូវសង<br>-ទ្រព្យសកម្មហិរញ្ញវត្ថុ<br>-បំណុលហិរញ្ញវត្ថុ | -មូលដ្ឋានសាច់ប្រាក់<br>-គណនីត្រូវទទួល<br>-គណនីត្រូវសង<br>-ទ្រព្យសកម្មហិរញ្ញវត្ថុ<br>-បំណុលហិរញ្ញវត្ថុ |
| **ស្តង់ដាដែលត្រូវអនុវត្តនៅក្នុងការិយបរិច្ឆេទនេះ÷**<br>- ឧបករណ៍ហិរញ្ញវត្ថុ- ការដាក់បង្ហាញ<br>- ឧបករណ៍ហិរញ្ញវត្ថុ- ការលាតត្រដាង<br>- ការវិនិយោគនៅក្នុងញាតិសម្ព័ន្ធ និងក្រុមហ៊ុនរួមទុន<br>- កិច្ចព្រមព្រៀងរួម<br>- ការលាតត្រដាងអំពីអត្ថប្រយោជន៍នៅក្នុងស្ថាប័នផ្សេងទៀត<br>- អត្ថប្រយោជន៍និយោជិត<br>- ឧបករណ៍ហិរញ្ញវត្ថុ<br>- អត្ថប្រយោជន៍សង្គម។ | | |

### ៤.៤.៤. ដំណាក់កាលទី៤÷ គណនេយ្យមូលដ្ឋានបង្គរ

| ឆ្នាំ ២០៣១ | ឆ្នាំ ២០៣២ | ឆ្នាំ ២០៣៣ តទៅ |
|---|---|---|
| -មូលដ្ឋានសាច់ប្រាក់<br>-គណនីត្រូវទទួល<br>-គណនីត្រូវសង<br>-ទ្រព្យសកម្មហិរញ្ញវត្ថុ<br>-បំណុលហិរញ្ញវត្ថុ<br>-ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ | -មូលដ្ឋានសាច់ប្រាក់<br>-គណនីត្រូវទទួល<br>-គណនីត្រូវសង<br>-ទ្រព្យសកម្មហិរញ្ញវត្ថុ<br>-បំណុលហិរញ្ញវត្ថុ<br>-ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ | -មូលដ្ឋានសាច់ប្រាក់<br>-គណនីត្រូវទទួល<br>-គណនីត្រូវសង<br>-ទ្រព្យសកម្មហិរញ្ញវត្ថុ<br>-បំណុលហិរញ្ញវត្ថុ<br>-ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ |

| | | |
|---|---|---|
| -សំវិធានធន, ទ្រព្យសកម្ម និង បំណុលយថាហេតុ<br>-គណនីបម្រុង និងការវាយតម្លៃឡើងវិញ | -សំវិធានធន, ទ្រព្យសកម្ម និង បំណុលយថាហេតុ<br>-គណនីបម្រុង និងការវាយតម្លៃឡើងវិញ | -សំវិធានធន, ទ្រព្យសកម្ម និង បំណុលយថាហេតុ<br>-គណនីបម្រុង និងការវាយតម្លៃឡើងវិញ |

**ស្តង់ដាដែលត្រូវអនុវត្តនៅក្នុងការិយបរិច្ឆេទនេះ÷**

- ការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ
- របាយការណ៍លំហូរសាច់ប្រាក់
- គោលនយោបាយគណនេយ្យ, ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង
- ឥទ្ធិពលនៃការផ្លាស់ប្តូរអត្រាប្តូរប្រាក់បរទេស
- បន្ទុកលើប្រាក់កម្ចី
- សន្និធិ
- ភតិសន្យា
- ទ្រព្យវិនិយោគ
- ទ្រព្យ រោងចក្រ និងបរិក្ខារ
- ការរាយការណ៍តាមផ្នែក
- សំវិធានធន, បំណុលយថាហេតុ, ទ្រព្យសកម្មយថាហេតុ
- ការធ្លាក់ចុះតម្លៃទ្រព្យសកម្មដែលមិនបង្កើតសាច់ប្រាក់
- ការលាតត្រដាងអំពីព័ត៌មានហិរញ្ញវត្ថុ - វិស័យរដ្ឋាភិបាលទូទៅ
- ការដាក់បង្ហាញព័ត៌មានថវិកានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- ការធ្លាក់ចុះតម្លៃទ្រព្យសកម្មដែលបង្កើតសាច់ប្រាក់
- កសិកម្ម
- ទ្រព្យសកម្មអរូបី
- កិច្ចព្រមព្រៀងសម្បទានសេវា-អ្នកផ្តល់ជំនួយ
- របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក
- របាយការណ៍ហិរញ្ញវត្ថុរួម
- ការរួមបញ្ចូលវិស័យសាធារណៈ។

## ជំពូកទី៥

## លក្ខខណ្ឌចាំបាច់ឆ្ពោះទៅការអនុវត្តគណនេយ្យមូលដ្ឋានបង្គរ

ដូចបានរៀបរាប់ពីខាងលើ មានលក្ខខណ្ឌចាំបាច់និងជាក់លាក់មួយចំនួនដែលត្រូវដោះស្រាយដើម្បីគាំទ្រដល់ការអនុវត្តស្តង់ដាគណនេយ្យមូលដ្ឋានបង្គរ ឱ្យទទួលបានជោគជ័យ។

ការយល់ដឹងអំពីកិច្ចប្រតិបត្តិការ និងប្រភេទប្រតិបត្តិការរបស់រាជរដ្ឋាភិបាល ដែលឆ្លងកាត់ស្ថាប័ននីមួយៗ គឺជាចំណុចគន្លឹះក្នុងការយល់ដឹងអំពីឥទ្ធិពលដែលអាចកើតមានឡើងនៃគណនេយ្យបង្គរ។ តាមរយៈការកំណត់ពីប្រភេទប្រតិបត្តិការជាមួយនឹងលំហូរទិន្នន័យពាក់ព័ន្ធដែលមាននៅក្នុងរាជរដ្ឋាភិបាល, គោលនយោបាយនិងដំណើរការដើម្បីកត់ត្រាប្រតិបត្តិការទាំងនោះតាមគណនេយ្យមូលដ្ឋានបង្គរ អាចត្រូវបានចងក្រង និងធ្វើសមាហរណកម្មទៅក្នុងនីតិវិធីនៃការរាយការណ៍ និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ស្ថាប័នរាជរដ្ឋាភិបាល។ ព័ត៌មាននេះក៏បង្ហាញពីផ្នែកមួយចំនួនដែលតម្រូវឱ្យមានការផ្លាស់ប្តូរជាសារវ័ន្ត និងផ្តល់សញ្ញាណនៃផលប៉ះពាល់ដែលកើតមានពីការផ្លាស់ប្តូរនោះផងដែរ។ ផ្អែកលើព័ត៌មាននេះ រាជរដ្ឋាភិបាលអាចធ្វើការវាយតម្លៃពីផលប៉ះពាល់នៃការផ្លាស់ប្តូរទៅកាន់គណនេយ្យមូលដ្ឋានបង្គរ ហើយសម្រេចចិត្តថាតើមុខងារណាមួយដែលត្រូវផ្លាស់ប្តូរនិងនៅពេលណាដែលការផ្លាស់ប្តូរនេះអាចនឹងកើតមានឡើង។

### ៥.១. លក្ខខណ្ឌចាំបាច់ផ្នែករដ្ឋបាល

#### ៥.១.១. ការគាំទ្រផ្នែកនយោបាយ និងរដ្ឋបាល

កំណែទម្រង់នេះត្រូវបានព្យាករណ៍ថា នឹងមានការគាំទ្រផ្នែកនយោបាយ និងរដ្ឋបាលគ្រប់គ្រាន់។ ការគាំទ្រនេះ ត្រូវបានបង្ហាញតាមរយៈការដាក់ឱ្យអនុវត្តផ្នែកផ្សេងៗនៃផែនការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការចេញប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ ដែលជាជំហានដំបូងមួយ ហើយការគាំទ្រនេះនឹងបន្តរីកចម្រើន និងអភិវឌ្ឍបន្ថែមទៀត។

#### ៥.១.២. ប្រព័ន្ធច្បាប់ និងបទប្បញ្ញត្តិដែលគាំទ្រដល់គណនេយ្យ មូលដ្ឋានបង្គរ

សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មីមួយកំពុងត្រូវបានរៀបចំដោយទទួលបានជំនួយបច្ចេកទេសពីទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD)។ សេចក្តីព្រាងច្បាប់ថ្មីនេះ ត្រូវបានរំពឹងថានឹងប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការដោយរដ្ឋសភា នាខែធ្នូ ឆ្នាំ២០២១។ សេចក្តីព្រាងច្បាប់ថ្មីនេះ នឹងក្លាយទៅជា

មូលដ្ឋានគ្រឹះដើម្បីធានាថា ដំណើរផ្លាស់ប្ដូរទៅកាន់គណនេយ្យមូលដ្ឋានបង្គរត្រូវបានជួយសម្របសម្រួលពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

ទន្ទឹមនឹងការអនុម័តសេចក្ដីព្រាងច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មីនេះ សៀវភៅណែនាំមួយដើម្បីគាំទ្រដល់ការអនុវត្តគណនេយ្យ និងការកាន់បញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ និងស្របតាមបទប្បញ្ញត្តិនានា នឹងត្រូវបានរៀបចំ ឬ ធ្វើបច្ចុប្បន្នភាពឡើងវិញ។ សៀវភៅណែនាំនេះក៏នឹងជួយគាំទ្រដល់ការអនុវត្តប្រព័ន្ធ FMIS ផងដែរ។

### ៥.១.៣. គណនេយ្យករជំនាញ និងអ្នកកាន់បញ្ជីគណនេយ្យ

បច្ចុប្បន្ន កង្វះខាតគណនេយ្យករជំនាញនិងអ្នកកាន់បញ្ជីគណនេយ្យដែលមានគុណវុឌ្ឍិ ជាឧបសគ្គចម្បងមួយរបស់រាជរដ្ឋាភិបាល។ ការគ្រប់គ្រងនិងការថែទាំប្រព័ន្ធ FMIS និងប្លង់គណនេយ្យ ទាមទារឱ្យគណនេយ្យករនិងអ្នកកាន់បញ្ជីគណនេយ្យមានជំនាញនិងបទពិសោធន៍ច្បាស់លាស់ មិនថាប្រព័ន្ធគណនេយ្យបែបមជ្ឈការរបស់អគ្គនាយកដ្ឋានរតនាគារជាតិបច្ចុប្បន្ន ឬ ការធ្វើវិមជ្ឈការមុខងារគណនេយ្យហិរញ្ញវត្ថុទៅកាន់ក្រសួង-ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែលនោះទេ។ រាជរដ្ឋាភិបាលអាចមានជម្រើសនៃការរៀបចំឱ្យមានកម្មវិធីបណ្ដុះបណ្ដាលទ្រង់ទ្រាយធំ សម្រាប់គណនេយ្យករនិងអ្នកកាន់បញ្ជីគណនេយ្យឱ្យបានលឿនតាមការដែលអាចធ្វើបាន ឬ រាជរដ្ឋាភិបាលអាចទទួលបាននូវជំនាញទាំងនេះ តាមរយៈការចុះកិច្ចព្រមព្រៀងផ្ដល់សេវាជាមួយគណនេយ្យករជំនាញក្នុងវិស័យឯកជន។ កម្មវិធីបណ្ដុះបណ្ដាលនេះក៏រំពឹងថានឹងអាចទទួលបានជំនួយពីម្ចាស់ជំនួយ (កិច្ចខិតខំប្រឹងប្រែងនេះក៏នឹងក្លាយជាផ្នែកមួយនៃក្របខ័ណ្ឌសមត្ថភាពដែលបានបង្កើតឡើងដោយរាជរដ្ឋាភិបាល សម្រាប់អ្នកវិជ្ជាជីវៈលើការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាទូទៅផងដែរ។ ការងារខាងលើអាចទទួលបានការគាំទ្របន្ថែមតាមរយៈការបង្កើតភាពជាដៃគូជាមួយស្ថាប័នអប់រំ និងស្ថាប័នគណនេយ្យអន្តរជាតិ ដូចជាវិទ្យាស្ថានអ្នកបច្ចេកទេសគណនេយ្យ (IAT), សមាគមគណនេយ្យករជំនាញ (ACCA) ឬ វិទ្យាស្ថានគណនេយ្យករសាធារណៈ (CIPFA)។

ដូចបានបញ្ជាក់ពីខាងដើម ឯកសារយោងគួរត្រូវបានភ្ជាប់ជាមួយនឹងផែនការអភិវឌ្ឍន៍សមត្ថភាពជាយុទ្ធសាស្ត្រនៅក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ដំណាក់កាលទី៣) ដែលបានរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នាខែធ្នូ ឆ្នាំ២០១៧ ដែលបានចាត់ទុកការអភិវឌ្ឍជំនាញគណនេយ្យនិងជំនាញគ្រប់គ្រងហិរញ្ញវត្ថុ ជាគោលបំណងគន្លឹះមួយក្នុងចំណោមគោលបំណងគន្លឹះសំខាន់ៗជាច្រើនទៀត។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា បាននិងកំពុងរៀបចំក្របខ័ណ្ឌនិងយុទ្ធសាស្ត្រដើម្បីផលិតគណនេយ្យករជំនាញក្នុងរបៀបមួយដែលមានល្បឿនលឿន ហើយរក្សាបាននូវគុណភាពផងដែរ។

#### ៥.១.៤. សមត្ថភាពគ្រប់គ្រងគម្រោង

អ្នកគ្រប់គ្រងគម្រោងល្អ ទាមទារនូវជំនាញចាំបាច់មួយចំនួនដូចជា÷ ភាពជាអ្នកដឹកនាំ, បច្ចេកទេស, ការទំនាក់ទំនង, ការចរចារ, ការគ្រប់គ្រងហានិភ័យ, ការរៀបចំផែនការ និងការគ្រប់គ្រងពេលវេលា។ បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាកំពុងអនុវត្តការងារកែទម្រង់ជាច្រើន ដែលក្នុងនោះមានការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផងដែរ។ កន្លងមក លទ្ធផលដែលសម្រេចបានក្នុងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ ទទួលបានការសាទរ និងការវាយតម្លៃខ្ពស់ជាបន្តបន្ទាប់ពីដៃគូអភិវឌ្ឍន៍និងមជ្ឈដ្ឋានទូទៅផងដែរ ទោះបីជាមានភាពរអាក់រអួលខ្លះក្នុងដំណាក់កាលនៃការអនុវត្តក៏ដោយ។ ការផ្លាស់ប្តូរទៅអនុវត្តប្រព័ន្ធគណនេយ្យបង្គរ ដោយឆ្លងកាត់ ៤ ដំណាក់កាលនេះ គឺជាផ្នែកមួយនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដូចនេះ ការគ្រប់គ្រងគម្រោងឱ្យទទួលបានជោគជ័យនឹងមិនមានឧបសគ្គនោះទេ។ ទោះជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលយល់ច្បាស់ពីភាពចាំបាច់នៃតម្រូវការបណ្តុះបណ្តាលចំណេះជំនាញសម្រាប់តួអង្គជាអ្នកអនុវត្តគម្រោង, ភាពចាំបាច់នៃការតម្រង់ទិស និងការគាំទ្រកម្រិតគោល-នយោបាយ និងយុទ្ធសាស្ត្រពីរាជរដ្ឋាភិបាល។

### ៥.២. លក្ខខណ្ឌចាំបាច់ផ្នែកបច្ចេកទេស

#### ៥.២.១. ប្រព័ន្ធ FMIS ដែលមានមុខងារពេញលេញមួយ

ប្រព័ន្ធ FMIS ដែលអាចបំពេញមុខងារពេញលេញ ជាមួយនឹងនីតិវិធីការងារគាំទ្រ គឺជាលក្ខខណ្ឌចាំបាច់មួយសម្រាប់ការអនុវត្តស្តង់ដាគណនេយ្យមូលដ្ឋានបង្គរ។ ឆ្លើយតបនឹងកង្វះខាតគណនេយ្យករជំនាញការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យមូលដ្ឋានបង្គរ ដោយមិនមានប្រព័ន្ធ FMIS ដែលអាចបំពេញមុខងារបានល្អមួយ នឹងនាំទៅរកភាពបរាជ័យ។

បន្ថែមពីនេះ កិច្ចប្រតិបត្តិការ និងការគ្រប់គ្រងប្រព័ន្ធ FMIS ត្រូវតែគាំទ្រដល់ការរៀបចំទិន្នន័យឱ្យបានត្រឹមត្រូវ, អាចជឿទុកចិត្តបាន, ទាន់ពេលវេលា និងពេញលេញ។ នីតិវិធីការងារដែលរៀបចំបានល្អ និងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព នឹងផ្តល់ការធានាថា ប្រព័ន្ធFMIS អាចផលិតបានទិន្នន័យនិងព័ត៌មានហិរញ្ញវត្ថុដែលអនុលោមតាមស្តង់ដាគណនេយ្យ ពោលគឺមានន័យថា វាជាព័ត៌មានដែលអាចយល់បាន,

មានភាពទាក់ទិន និងជាការបង្ហាញដ៏ស្មោះត្រង់ (Faithful Representation) នៃប្រតិបត្តិការហិរញ្ញវត្ថុរបស់ស្ថាប័ន និងព័ត៌មានផ្សេងទៀតដែលបានលាតត្រដាងក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ សៀវភៅណែនាំដើម្បីគាំទ្រដល់កិច្ចប្រតិបត្តិការនៃប្រព័ន្ធ FMIS នឹងត្រូវបានផ្តល់ជូនដោយគម្រោងប្រព័ន្ធ FMIS ដែលមានមុខងារពេញលេញ និងគួរត្រូវបានធ្វើបច្ចុប្បន្នភាពឡើងវិញ និងរក្សាទុកឱ្យបានជាប្រចាំ។

### ៥.២.២. របាយការណ៍ហិរញ្ញវត្ថុមូលដ្ឋានសាច់ប្រាក់ដែលមានគុណភាព

ស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានសាច់ប្រាក់ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការដោយរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងខែមិថុនា ឆ្នាំ២០១៩ ខណៈដែលអគ្គនាយកដ្ឋានរតនាគារជាតិ បាននិងកំពុងអនុវត្តស្តង់ដានេះក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា ចាប់ពីឆ្នាំ២០១៦ មក។ ក្នុងអំឡុងពេលនៃការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានសាច់ប្រាក់ របាយការណ៍ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលគួរត្រូវបានបញ្ចូលការលាតត្រដាងនានាដែលមិនមែនជាលក្ខខណ្ឌតម្រូវដោយស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានសាច់ប្រាក់ តាមរយៈកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ។ ជាមួយគ្នានេះ ប្រព័ន្ធ FMIS នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយសម្រួលដល់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួមពេញលេញ និងការទូទាត់សងចុងឆ្នាំដែលពាក់ព័ន្ធនឹងអ្នកផ្គត់ផ្គង់ និងភាគីទីបី សម្រាប់ត្រៀមខ្លួនឆ្ពោះទៅកាន់ដំណាក់កាលទី២÷ គណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល។

### ៥.២.៣. ប្លង់គណនេយ្យដែលអំណោយផលដល់គណនេយ្យមូលដ្ឋានបង្គរ

ប្លង់គណនេយ្យដែលត្រូវបានប្រើប្រាស់ដោយរាជរដ្ឋាភិបាល អាចត្រូវបានពិពណ៌នាថាជាប្រព័ន្ធលេខកូដដែលអនុញ្ញាតឱ្យប្រតិបត្តិការទាំងអស់អាចត្រូវបានធ្វើចំណាត់ថ្នាក់ កត់ត្រា និងតាមដាន នៅពេលដែលប្រតិបត្តិការទាំងនោះឆ្លងកាត់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងផែនការថវិកា រាប់ចាប់ពីការរៀបចំថវិកា, ការវិភាជន៍, ការបែងចែក, ការធានាចំណាយ (commitment), ការអនុវត្ត, ការទូទាត់, គណនេយ្យកម្មរហូតដល់ការធ្វើសវនកម្ម។ ប្លង់គណនេយ្យឆ្លុះបញ្ចាំងពីភាពស្មុគស្មាញនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុនិងរៀបចំថវិការបស់រាជរដ្ឋាភិបាល ហើយមានសារៈសំខាន់ចំពោះការសម្រេចបាននូវគោលបំណងនៃការរាយការណ៍ និងគណនេយ្យថវិការបស់ខ្លួន ក៏ដូចជាការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ និងការរាយ-ការណ៍ស្ថិតិឱ្យស្របទៅតាមស្តង់ដា។ ជាមួយប្រព័ន្ធ FMIS ដែលត្រូវបានរៀបចំរចនាសម្ព័ន្ធសម្រាប់គណនេយ្យមូលដ្ឋានបង្គរ ប្លង់គណនេយ្យដែលរាជរដ្ឋាភិបាលប្រើបច្ចុប្បន្នមានអំណោយផលដល់ការរៀបចំរបាយការណ៍

ហិរញ្ញវត្ថុមូលដ្ឋានបង្គរ ប្រសិនបើប្លង់គណនេយ្យនោះត្រូវបានប្រើប្រាស់យ៉ាងត្រឹមត្រូវដោយគណនេយ្យករជំនាញ និងអ្នកកាន់បញ្ជីគណនេយ្យដែលទទួលបានការបណ្តុះបណ្តាលច្បាស់លាស់។

### ៥.៣. លក្ខខណ្ឌចាំបាច់ផ្នែកគណនេយ្យ

គណនីនីមួយៗនៃតារាងតុល្យការ ចាំបាច់ត្រូវមានសមតុល្យដើមគ្រាមួយដើម្បីបញ្ចូលទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំដំបូង។ តួលេខនេះត្រូវមានភាពត្រឹមត្រូវ ដោយមានភស្តុតាងច្បាស់លាស់ហើយស្តង់ដា IPSAS ៣៣÷ ការអនុវត្តស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈមូលដ្ឋានបង្គរជាលើកដំបូង បានផ្តល់សិទ្ធិមួយចំនួនក្នុងការកែសម្រួលសមតុល្យទាំងនេះនៅពេលមានព័ត៌មានត្រឹមត្រូវបន្ថែម។ សមតុល្យធនាគារ និងសមតុល្យសាច់ប្រាក់ នឹងអាចទទួលបានពីរបាយការណ៍ហិរញ្ញវត្ថុមូលដ្ឋានសាច់ប្រាក់ ដូច្នេះប្រភេទគណនីបន្ថែមដែលរួមមាន សមតុល្យដើមគ្រា និងការវាយតម្លៃ ត្រូវបានគណនា និងធ្វើគណនេយ្យកម្មរួមមាន÷

| **ទ្រព្យសកម្ម** | **បំណុល** |
|---|---|
| ឥណាយិករយៈពេលខ្លី និងការទូទាត់មុន | ឥណទាយក និងគណនីបង្គរ |
| ទ្រព្យ រោងចក្រ និងបរិក្ខារ | បំណុលសាធារណៈ |
| ការងារកំពុងដំណើរការលើកិច្ចសន្យាសាងសង់ | ភតិសន្យាហិរញ្ញវត្ថុ |
| សន្និធិ | បំណុលយថាហេតុ |
| ការវិនិយោគមូលធន | អត្ថប្រយោជន៍ និងកាតព្វកិច្ចនិយោជិត |
| ទ្រព្យសកម្មអរូបី | អត្ថប្រយោជន៍ និងកាតព្វកិច្ចសុខុមាលភាពសង្គម |

# ជំពូកទី៦
# ការគ្រប់គ្រងគម្រោង

ធាតុចំនួន ០៤ ពាក់ព័ន្ធនឹងធនធានមនុស្ស និងអភិបាលកិច្ចដែលត្រូវការជាចាំបាច់ក្នុងការគាំទ្រដល់ការអភិវឌ្ឍនិងការអនុវត្តគម្រោងស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរ ឱ្យទទួលបានជោគជ័យ រួមមាន÷

១. ភាពជាអ្នកដឹកនាំជាន់ខ្ពស់ និងការត្រួតពិនិត្យគម្រោង
២. ការចាត់ចែងការទទួលខុសត្រូវលើការគ្រប់គ្រងគម្រោង ទៅកាន់អង្គភាពត្រឹមត្រូវ
៣. ការអនុវត្តការសិក្សានិងបទពិសោធន៍ដែលទទួលបានពីដៃគូអភិវឌ្ឍន៍និងដៃគូខាងក្រៅផ្សេងទៀត និង
៤. ការផ្តល់ការលើកទឹកចិត្ត ដើម្បីជំរុញការអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានបង្គរ។

សម្រាប់ការរៀបចំ និងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា មូលដ្ឋានសាច់ប្រាក់ និយ័តករគណនេយ្យនិងសវនកម្ម គឺជាស្ថាប័នដឹកនាំដែលទទួលបានការជួយគាំទ្រពីអគ្គនាយកដ្ឋានរតនាគារជាតិ។ មតិយោបល់និងកិច្ចសហប្រតិបត្តិការពីម្ចាស់ជំនួយ គឺជាធាតុដ៏សំខាន់មិនអាចខ្វះបានក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍នានា ជាពិសេសសម្រាប់គម្រោងស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានបង្គរ ផ្ទាល់តែម្តង។ ការជៀសវាងការខិតខំប្រឹងប្រែង និងធាតុចូលជាន់គ្នា ក៏ដូចជាការធានានូវលំដាប់លំដោយត្រឹមត្រូវនៃសកម្មភាពការងារ បានចូលរួមចំណែកយ៉ាងច្រើនដល់ភាពជោគជ័យ។ កិច្ចសហការនិងការទំនាក់ទំនងរវាងម្ចាស់ជំនួយសំខាន់ៗក្នុងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងប្រទេសកម្ពុជាដូចជា សហភាពអឺរ៉ុប, ធនាគារពិភពលោក, មូលនិធិរូបិយវត្ថុអន្តរជាតិ និងទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ ត្រូវបានរៀបចំផែនការយ៉ាងល្អ និងទទួលបានការសាទរយ៉ាងខ្លាំងពីរាជរដ្ឋាភិបាលកម្ពុជា។ នេះគឺជាយន្តការដ៏មានសារៈសំខាន់មួយដើម្បីគ្រប់គ្រងការពន្យារពេលយូរពេកណាមួយ ឬ ឧបសគ្គស្ថាប័នចំពោះការរៀបចំគម្រោង និងការអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា។

## ៦.១. រចនាសម្ព័ន្ធនៃការគ្រប់គ្រងគម្រោង

ខាងក្រោមនេះបង្ហាញពីរចនាសម្ព័ន្ធគ្រប់គ្រងគម្រោង÷




**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងផ្តល់នូវទិសដៅជាយុទ្ធសាស្ត្រលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសពាក់ព័ន្ធនឹងការងារកែទម្រង់គណនេយ្យសាធារណៈ។ ពាក់ព័ន្ធនឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងរាជរដ្ឋាភិបាលកម្ពុជា ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងមានភារកិច្ចទទួលខុសត្រូវក្នុងការអនុម័តសម្រេចដាក់ឱ្យប្រើស្តង់ដាគណនេយ្យមូលដ្ឋានបង្គរ តាមសំណើរបស់និយ័តករគណនេយ្យនិងសវនកម្ម បន្ទាប់ពីក្រុមការងារបច្ចេកទេសស្តង់ដាបានផ្តល់ការយល់ព្រម។

**ក្រុមការងារបច្ចេកទេសស្តង់ដាគណនេយ្យសម្រាប់វិស័យសាធារណៈ**

ប្រកាសស្តីពីការបង្កើតនិងការតែងតាំងសមាសភាពក្រុមការងារបច្ចេកទេសស្តង់ដាគណនេយ្យសម្រាប់វិស័យសាធារណៈ ត្រូវបានចុះហត្ថលេខាជាផ្លូវការ នាថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៧។ ក្រុមការងារនេះដឹកនាំដោយរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ (បច្ចុប្បន្ននិយ័តករគណនេយ្យនិងសវនកម្ម) ដែលមានសមាសភាពតំណាងមកពី និយ័តករគណនេយ្យនិងសវនកម្ម, អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ, អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានថវិកា ហើយក្រុមការងារនេះនឹងមានតួនាទីភារកិច្ចលើការអភិវឌ្ឍ និងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជាទាំងមូល រាប់ចាប់ពី

ការរៀបចំផែនការសកម្មភាពលម្អិតសម្រាប់ការអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជា និងការតាមដានការអនុវត្តផែនការសកម្មភាពលម្អិតដែលបានកំណត់ រហូតដល់ការពិនិត្យឡើងវិញនូវឯកសារផែនទីបង្ហាញផ្លូវដែលមានស្រាប់សម្រាប់ការអនុវត្តស្តង់ដាគណនេយ្យសាធារណៈនៅកម្ពុជា។ ក្រុមការងារបច្ចេកទេសនេះជាកម្មវត្ថុនៃការកែសម្រួល ដើម្បីឱ្យស្របតាមភាពជាក់ស្តែងនៃការប្រែប្រួលក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។ ការទទួលខុសត្រូវបន្ថែមរបស់ក្រុមការងារបច្ចេកទេសនេះអាចត្រូវបានកំណត់ដោយ ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្រុមការងារនេះនឹងរួមមាន÷

### ក្រុមការងារកំណត់ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា

ក្រុមការងារកំណត់ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា គឺជានាយកដ្ឋានបច្ចេកទេសនៃនិយ័តករគណនេយ្យនិងសវនកម្ម ដែលដំណើរការសម្រាប់ការកំណត់ស្តង់ដានឹងយកលំនាំតាម *ដំណើរការកំណត់ស្តង់ដានិងនីតិវិធីការងាររបស់ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈ (មិថុនា ២០១៦)*។ នីតិវិធីការងារនេះអាចត្រូវបានកែសម្រួលដើម្បីធានាភាពទាក់ទិននឹងលក្ខខណ្ឌតម្រូវនិងលក្ខខណ្ឌរបស់រាជរដ្ឋាភិបាលកម្ពុជា។ ការងារកំណត់ស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរ នឹងទទួលបានជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានាផងដែរ។

ដំណើរការនៃការអភិវឌ្ឍស្តង់ដាគណនេយ្យនឹងត្រូវអនុវត្តតាមដំណាក់កាលដូចខាងក្រោម÷

**១**
- កំណត់តម្រូវការរបស់អ្នកប្រើប្រាស់របាយការណ៍ និងគោលបំណងនៃការរាយការណ៍ហិរញ្ញវត្ថុ តាមរយៈដំណើរការពិគ្រោះយោបល់
- បញ្ជាក់គោលបំណងនៃកំណែទម្រង់ និងស្តង់ដាដែលបានតម្រូវ

**២**
- រៀបចំយុទ្ធសាស្ត្រជាក់លាក់មួយ ដើម្បីអភិវឌ្ឍស្តង់ដានីមួយៗ ដូចបានកំណត់នៅក្នុងដំណាក់កាលទី១
- យុទ្ធសាស្ត្រនឹងស្នើឡើងនូវលំដាប់លំដោយសម្រាប់ការអភិវឌ្ឍ និងការណែនាំនូវស្តង់ដា

**៣**
- កំណត់ក្រុមការងារគម្រោងសម្រាប់ស្តង់ដានីមួយៗ ដែលនឹងតំណាងឱ្យភាគីពាក់ព័ន្ធទាំងអស់ ជាមួយនឹងធនធានចាំបាច់
- ក្រុមការងារគម្រោងនឹងរៀបចំឯកសារពិគ្រោះយោបល់ និងការវិភាគចំណុចខ្វះខាត ដើម្បីដាក់ជូនភាគីពាក់ព័ន្ធទាំងអស់ពិនិត្យ

**៤**
- ធ្វើការវិភាគលើចំណាយនិងអត្ថប្រយោជន៍ ដើម្បីកំណត់លក្ខខណ្ឌចាំបាច់និងថ្លៃចំណាយនៃលក្ខខណ្ឌចាំបាច់ទាំងនោះក្នុងការអនុវត្តស្តង់ដាដែលបានជ្រើសរើសនីមួយៗ ដោយធៀបនឹងចំណូលដែលរំពឹងទុកពីការអនុវត្ត ទាំងផ្នែកហិរញ្ញវត្ថុ និងគុណភាព

**៥**
- ធ្វើតេស្តលើសំណើនៅក្នុងឯកសារពិគ្រោះយោបល់ ចំពោះភាពពេញលេញ ភាពត្រឹមត្រូវ សុពលភាព ភាពដែលអាចដំណើរការបាន និងភាពដែលអាចប្រើប្រាស់បាន ជាដើម
- កែសម្រួលឯកសារពិគ្រោះយោបល់ ផ្អែកលើលទ្ធផលនៃការធ្វើតេស្ត – រៀបចំសេចក្តីព្រាងស្តង់ដា

**៦**
- ដាក់បង្ហាញសេចក្តីព្រាងស្តង់ដាជូន ក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ទទួលយក ឬ បដិសេធសេចក្តីព្រាងស្តង់ដា (ត្រូវកែសម្រួលបន្ថែម ប្រសិនបើសេចក្តីព្រាងស្តង់ដានោះត្រូវបានបដិសេធ រហូតក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ មានការពេញចិត្ត)

**៧**
- រៀបចំការបណ្តុះបណ្តាលសម្រាប់បុគ្គលិក និងអនុវត្តផែនការគ្រប់គ្រងការផ្លាស់ប្តូរ ដើម្បីដាក់ឱ្យអនុវត្តស្តង់ដា
- បោះផ្សាយសេចក្តីព្រាងស្តង់ដា។

ដើម្បីធានាថា ដំណើរការនៃការអភិវឌ្ឍស្តង់ដាតាមដំណាក់កាលនីមួយៗខាងលើទទួលបានជោគជ័យ និយ័តករគណនេយ្យនិងសវនកម្មអាចមានភាពចាំបាច់ក្នុងការស្វែងរកជំនួយពីអ្នកជំនាញផ្នែកគណនេយ្យក្នុងស្រុក ឬ បរទេស បន្ថែមពីលើមន្ត្រីបច្ចេកទេសរបស់ខ្លួនដែលមានស្រាប់។

### ក្រុមការងារបណ្តុះបណ្តាលស្តង់ដាគណនេយ្យសាធារណៈកម្ពុជា

ក្រុមការងារបណ្តុះបណ្តាលនិងការិយាល័យជំនាញនៃនិយ័តករគណនេយ្យនិងសវនកម្ម នឹងមានភារកិច្ចទទួលខុសត្រូវលើការរៀបចំការបណ្តុះបណ្តាល, ការកសាងសមត្ថភាព និងការគ្រប់គ្រង

ការផ្លាស់ប្តូរ។ ដើម្បីធានាបានប្រសិទ្ធភាពនៃការងារបណ្តុះបណ្តាល និងការកសាងសមត្ថភាពរបស់គណនេយ្យករជំនាញនិងអ្នកកាន់បញ្ជីគណនេយ្យរបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរ ការចូលរួមសហការយ៉ាងជិតស្និទ្ធពីអគ្គនាយកដ្ឋានរតនាគារជាតិនិងស្ថាប័នពាក់ព័ន្ធនានា ពិតជាមានភាពចាំបាច់។

ផែនការគ្រប់គ្រងការផ្លាស់ប្តូរ អាចនឹងត្រូវបានរៀបចំឡើងដោយនិយ័តករគណនេយ្យនិងសវនកម្ម និងអគ្គនាយកដ្ឋានរតនាគារជាតិ ក្រោមកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យមូលដ្ឋានបង្គរ នឹងនាំឱ្យមានការផ្លាស់ប្តូរជាសារវ័ន្តចំពោះការរាយការណ៍អំពីចំណូលនិងចំណាយ គណនេយ្យ និងការរាយការណ៍សវនកម្ម។ ការផ្លាស់ប្តូរទៅលើរបៀបដែលគណនេយ្យបំពេញមុខងារ និងរបៀបដែលនីតិវិធីការងារកំពុងត្រូវបានគ្រប់គ្រងដោយភាគីពាក់ព័ន្ធនាពេលបច្ចុប្បន្ន នឹងកើតមានឡើងជាលទ្ធផលនៃការអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានបង្គរ ទាំងក្នុងនិងក្រៅរាជរដ្ឋាភិបាល។ គំនិតផ្តួចផ្តើមទាំងនេះនឹងបង្កើតឱ្យមានជាគោលនយោបាយ, រចនាសម្ព័ន្ធ, នីតិវិធីការងារ និងប្រព័ន្ធព័ត៌មានវិទ្យាថ្មី សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈ នឹងទាមទារឱ្យមាននូវកម្មវិធីសម្រាប់ការគ្រប់គ្រងការផ្លាស់ប្តូរ, ការកសាងសមត្ថភាព និងការទំនាក់ទំនងសម្រាប់បុគ្គលិកផ្នែកគណនេយ្យនិងបុគ្គលិកផ្នែកកាន់បញ្ជីគណនេយ្យនៅក្នុងរាជរដ្ឋាភិបាល ក៏ដូចជាក្រុមហ៊ុនភ្ជាប់ប្រព័ន្ធ និងវិទ្យាស្ថានណាមួយ។ ការសម្របសម្រួលនិងការគ្រប់គ្រងកម្មវិធីទាំងនេះតម្រូវឱ្យបុគ្គលិកមានការតាំងចិត្ត និងការខិតខំប្រឹងប្រែងខ្ពស់ដើម្បីបំពេញការងារពេញម៉ោងក្នុងអំឡុងពេលនៃដំណាក់កាល អនុវត្ត និងចាប់ផ្តើមដំណើរការ។ រាជរដ្ឋាភិបាលនឹងកៀរគរនូវធនធានអ្នកជំនាញមកពីវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីជួយគាំទ្រដល់ការរៀបចំផែនការនិងការរៀបចំកម្មវិធីកសាងសមត្ថភាព និងការគ្រប់គ្រងការផ្លាស់ប្តូរដែលត្រូវបានអភិវឌ្ឍជាពិសេសសម្រាប់ស្តង់ដាគណនេយ្យសាធារណៈកម្ពុជា។ កិច្ចខិតខំប្រឹងប្រែងលើការងារគ្រប់គ្រងការផ្លាស់ប្តូរ នឹងរួមបញ្ចូលនូវតុជំនួយ (Help Desk) សម្រាប់ក្រសួង-ស្ថាប័ននិងអង្គភាពសាធារណៈប្រហាក់ប្រហែល ដែលនឹងត្រូវដំណើរការដោយនិយ័តករគណនេយ្យនិងសវនកម្ម ដោយទទួលបានការជួយគាំទ្រពីអគ្គនាយកដ្ឋានរតនាគារជាតិ។ ការងារនេះក៏នឹងអាចទទួលបានជំនួយពីដៃគូអភិវឌ្ឍន៍នានាផងដែរ។

ការអនុវត្តស្តង់ដា ត្រូវការជាចាំបាច់នូវការរៀបចំផែនការមួយប្រកបដោយការប្រុងប្រយ័ត្នខ្ពស់ និងវិធីសាស្ត្រដែលបានកំណត់ច្បាស់លាស់មួយ ដើម្បីគ្រប់គ្រងរយៈពេលអន្តរកាលសម្រាប់មន្ត្រីរាជរដ្ឋាភិបាលនិងភាគីពាក់ព័ន្ធខាងក្រៅ។ រាជរដ្ឋាភិបាលកម្ពុជាអាចដោះស្រាយបញ្ហានេះបានតាមរយៈការចូលរួមពីមន្ត្រី ការកសាងសមត្ថភាព និងការទំនាក់ទំនងឱ្យបានសមស្រប។ អន្តរាគមន៍ទាំងនេះនឹងផ្តល់ការទទួលយកចាំបាច់ពីសំណាក់ភាគីពាក់ព័ន្ធពីគ្រប់មជ្ឈដ្ឋាន និងគួររៀបចំមន្ត្រីដើម្បីត្រៀមខ្លួនឱ្យបានរួចជាស្រេច សម្រាប់ដំណើរផ្លាស់ប្តូរទៅកាន់បរិយាកាសស្តង់ដាថ្មី។

## ៦.២. ធាតុចំណាយនៃកំណែទម្រង់

១. ប្រព័ន្ធ FMIS ត្រូវបានរៀបចំផែនការថវិកានិងកំពុងដាក់ឱ្យអនុវត្ត – មិនគួរមានចំណាយបន្ថែមគួរឱ្យកត់សម្គាល់។

២. កំណែទម្រង់ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ កំពុងស្ថិតក្រោមការរៀបចំ និងទទួលបានជំនួយពីទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ – មិនគួរមានចំណាយបន្ថែមគួរឱ្យកត់-សម្គាល់។

៣. ការរៀបចំសៀវភៅណែនាំ និងឯកសារបណ្តុះបណ្តាល ការបណ្តុះបណ្តាលមន្ត្រីហិរញ្ញវត្ថុ និងមន្ត្រីប្រតិបត្តិការ អ្នកនយោបាយ ភាគីពាក់ព័ន្ធផ្សេងទៀត នៅក្នុងទស្សនាទានប្រព័ន្ធគណនេយ្យ នីតិវិធីការងារ ការគ្រប់គ្រងផ្ទៃក្នុង វិធីសាស្ត្រគណនេយ្យថ្មី – នេះគឺជាការងារមួយដែលត្រូវការពេលវេលានិងត្រូវចំណាយច្រើន និងគួរទទួលបានការវិចារណាយ៉ាងយកចិត្តទុកដាក់ មុននឹងដាក់ឱ្យអនុវត្តស្តង់ដាមូលដ្ឋានបង្គរណាមួយ ឬស្តង់ដាមូលដ្ឋានបង្គរទាំងអស់។ ស្តង់ដានីមួយៗនឹងមានលទ្ធផលចំណាយ ហើយត្រូវបានវាយតម្លៃផ្សេងៗពីគ្នាផងដែរ។

៤. ការបណ្តុះបណ្តាលក្រុមគ្រូបង្គោល និងតុជំនួយ – ដូចចំណុចទាំងបីខាងលើ

៥. ការគ្រប់គ្រងការផ្លាស់ប្តូរ – ដូចចំណុចទាំងបីខាងលើ

៦. កម្រៃសេវាប្រឹក្សាយោបល់ – ដូចចំណុចទាំងបីខាងលើ។ កម្រៃសេវាប្រឹក្សាយោបល់ទាំងអស់ទំនងជាមិនទទួលបានការរ៉ាប់រងពីដៃគូអន្តរជាតិនោះទេ ដូច្នេះរាជរដ្ឋាភិបាលត្រូវពិចារណាលើការចូលរួមវិភាគទានដល់ខ្ទង់ចំណាយនេះ និងរួមបញ្ចូលផែនការថវិកាមួយទៅក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី៤។

ឯកសារនេះនឹងមិនមានការរៀបចំនូវការប៉ាន់ស្មានចំណាយ សម្រាប់ការណែនាំស្ដីពីស្តង់ដាគណនេយ្យមូលដ្ឋានបង្គរនោះទេ។ ខណៈការអនុវត្តទំនងជាមិនអាចចាប់ផ្ដើមបានក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ដូច្នេះ ការប៉ាន់ស្មានចំណាយនឹងមានភាពខុសគ្នា ចាប់ពីពេលនេះរហូតដល់ពេលវេលាដាក់ឱ្យអនុវត្ត។ ការពិចារណាគួរត្រូវបានធ្វើឡើងដើម្បីធានាថា ផែនការសកម្មភាពរួម ដំណាក់-កាលទី៤ នឹងរួមបញ្ចូលឯកសារយោងចំពោះគំនិតផ្ដួចផ្ដើមនេះ។

ស្រដៀងគ្នានេះដែរ ដោយសារតែស្តង់ដានីមួយៗមានដំណើរការនៃការអនុវត្តនិងលទ្ធផលចំណាយរៀងៗខ្លួន ដូច្នេះ រាជរដ្ឋាភិបាលចាំបាច់ត្រូវប៉ាន់ស្មានអំពីចំណាយ នៅពេលធ្វើការអភិវឌ្ឍស្តង់ដា។

## ជំពូកទី៧
## សកម្មភាពសង្ខេប

តារាងខាងក្រោមបង្ហាញពីសកម្មភាពសង្ខេបដែលត្រូវអនុវត្តនៅក្នុងយុទ្ធសាស្ត្រនេះ ក្នុងដំណើរឆ្ពោះទៅកាន់ការអនុវត្តស្តង់ដាគណនេយ្យមូលដ្ឋានបង្គរ ស្របតាមបន្ទាត់ពេលវេលាដែលរាជរដ្ឋាភិបាលបានកំណត់សម្រាប់ការអនុវត្តពេញលេញត្រឹមឆ្នាំ២០៣១។ បន្ទាត់ពេលវេលានេះអាចនឹងមានការប្រែប្រួល ដើម្បីសម្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

| ល.រ | សកម្មភាព | ស្ថាប័ន | ពេលវេលា |
|---|---|---|---|
| ១. | យល់ព្រម និងបញ្ចប់យុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានបង្គរ តាមរយៈដំណើរការពិគ្រោះយោបល់ និងកិច្ចពិភាក្សាជាមួយភាគីពាក់ព័ន្ធទាំងអស់។ | ន.គ.ស ជាមួយភាគីពាក់ព័ន្ធ | ៣១ ធ្នូ ២០២១ |
| ២. | ធានាថា គំនិតផ្តួចផ្តើមត្រូវបានបញ្ចូលទៅក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី៤ ជាផ្នែកមួយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ | ន.គ.ស | ធ្នូ ២០២១ |
| ៣. | ធានាថា ការផ្លាស់ប្តូរទៅកាន់គណនេយ្យមូលដ្ឋានបង្គរ ត្រូវបានរៀបចំនៅក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី។ | ន.គ.ស និង អគ្គ.រតនាគារជាតិ | ធ្នូ ២០២១ |
| ៤. | បញ្ចប់ការដាក់ឱ្យដំណើរការ និងការអនុវត្តពេញលេញនៃប្រព័ន្ធ FMIS។ | អគ្គ.ថវិកា និង អគ្គ.រតនាគារជាតិ | ចុងឆ្នាំ ២០២១ |
| ៥. | បញ្ចប់ការអនុវត្តពេញលេញនៃ គណនីទោលរតនាគារជាមួយវិសាលភាពគ្របដណ្តប់ពេញលេញទៅលើរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ | អគ្គ.រតនាគារជាតិ | ចុងឆ្នាំ ២០២១ |
| ៦. | បញ្ចប់ការអនុវត្តពេញលេញនៃស្តង់ដាគណនេយ្យសាធារណៈកម្ពុជា – ដំណាក់កាលទី១ | អគ្គ.រតនាគារជាតិ និង ន.គ.ស | ចុងឆ្នាំ ២០២២ |

| | | | |
|---|---|---|---|
| ៧. | រៀបចំ និងផ្សព្វផ្សាយសៀវភៅណែនាំ ដើម្បីគាំទ្រដល់ការកាន់បញ្ជីកាគណនេយ្យ និងការអនុវត្តគណនេយ្យឱ្យបានត្រឹមត្រូវ អនុលោមតាមច្បាប់និងឧត្តមានុវត្តន៍។ | អគ្គ.រតនាគារជាតិ ជាមួយក្រសួង-ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល | ចុងឆ្នាំ ២០២១ |
| ៨. | បង្កើតក្រុមការងារគ្រប់គ្រងគម្រោង ដោយអនុញ្ញាតឱ្យមានពេលវេលាសមស្របដើម្បីរៀបចំផែនការ និងជ្រើសរើសធនធានចាំបាច់ សម្រាប់ការផ្លាស់ប្តូរទៅកាន់គណនេយ្យមូលដ្ឋានបង្គរ ប្រកបដោយភាពរលូន។ | ន.គ.ស | ពាក់កណ្តាលឆ្នាំ ២០២៣ |
| ៩. | ធានាផែនការថវិកា សម្រាប់ការអនុវត្តគំនិតផ្តួចផ្តើម និងសកម្មភាព។ | ន.គ.ស និង អគ្គ.ថវិកា | ជារៀងរាល់ឆ្នាំ |
| ១០. | ឯកភាពលើការផ្តល់ជំនួយបច្ចេកទេស ជាមួយដៃគូម្ចាស់ជំនួយអន្តរជាតិ។ | ន.គ.ស | បន្ត |
| ១១. | អភិវឌ្ឍ និងអនុវត្តកម្មវិធីកសាងសមត្ថភាព និងគ្រប់គ្រងការផ្លាស់ប្តូរ – សម្រាប់គណនេយ្យមូលដ្ឋានសាច់ប្រាក់ និងគណនេយ្យមូលដ្ឋានបង្គរ។ | ន.គ.ស និង អគ្គ.រតនាគារជាតិ | ចាប់ពី ០១ មករា ២០២២ តទៅ |
| ១២. | ចរចាជាមួយគ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ដើម្បីធានាថា គណនីតារាងតុល្យការដើមគ្រា ត្រូវបានរៀបចំនៅក្នុងពេលវេលាដ៏ល្អ ជាពិសេសចំពោះអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ និងអគ្គ-នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល។ | ន.គ.ស និង អគ្គ.រតនាគារជាតិ | បន្ត |
| ១៣. | ពិនិត្យឡើងវិញលើប្លង់គណនេយ្យ ដើម្បីធានាថា ប្លង់គណនេយ្យគាំទ្រដល់គណនេយ្យមូលដ្ឋានបង្គរ។ | អគ្គ.រតនាគារជាតិ និង អគ្គ.ថវិកា | ២០២២ |
| ១៤. | អនុវត្តដំណាក់កាលទី២ – គណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល | ន.គ.ស និង អគ្គ.រតនាគារជាតិ | ២០២៥-២០២៧ |

| | | | |
|---|---|---|---|
| ១៥. | អនុវត្តដំណាក់កាលទី៣ – គណនេយ្យមូលដ្ឋានបង្គរកែសម្រួល | ន.គ.ស និង អគ្គ.រតនាគារជាតិ | ២០២៨-២០៣០ |
| ១៦. | អនុវត្តដំណាក់កាលទី៤ – គណនេយ្យមូលដ្ឋានបង្គរ | ន.គ.ស និង អគ្គ.រតនាគារជាតិ | ២០៣១-២០៣៣ |
| ១៧. | តាមដានវឌ្ឍនភាព និងចាត់វិធានការដ៏ត្រឹមត្រូវ | ន.គ.ស និង អគ្គ.រតនាគារជាតិ | បន្ត |

និយ័តករគណនេយ្យនិងសវនកម្ម ត្រូវសម្របសម្រួលជាមួយភាគីពាក់ព័ន្ធក្នុងការរៀបចំផែនការអនុវត្តសកម្មភាពលម្អិត ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រនេះឱ្យទទួលបានជោគជ័យ។ ការរៀបចំផែនការសកម្មភាពលម្អិតនេះត្រូវរៀបចំសម្រាប់មួយដំណាក់កាលម្តង។ ចំពោះមុខ និយ័តករគណនេយ្យនិងសវនកម្មត្រូវសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ ដើម្បីរៀបចំផែនការសកម្មភាពលម្អិតសម្រាប់ដំណាក់កាលទី២÷ គណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល។

## ឧបសម្ព័ន្ធទី ១÷ ការពិពណ៌នាអំពីស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈមូលដ្ឋានបង្គរ

សម្រាប់គោលបំណងជាការផ្ទៀងផ្ទាត់ និងសម្រួលដល់ការយល់ដឹងឱ្យបានកាន់តែទូលំទូលាយអំពីគោលបំណងនៃស្តង់ដាមូលដ្ឋានបង្គរ តារាងខាងក្រោមនេះបង្ហាញអំពីគោលបំណង និងវិសាលភាពសង្ខេបនៃស្តង់ដាគណនេយ្យអន្តរជាតិសម្រាប់វិស័យសាធារណៈនាពេលបច្ចុប្បន្នទាំងអស់ គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។

| | |
|---|---|
| ១. | **ការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ**<br>*គោលបំណង÷* ដើម្បីកំណត់មធ្យោបាយដែលរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅគួរត្រូវបានដាក់បង្ហាញ ក្នុងគោលដៅធានានូវភាពដែលអាចប្រៀបធៀបគ្នាបាន ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុនៃការិយបរិច្ឆេទមុនៗរបស់ស្ថាប័ន និងជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នផ្សេងទៀត។ ដើម្បីសម្រេចបានគោលបំណងនេះ ស្តង់ដាបានកំណត់ការពិចារណាទូទៅសម្រាប់ការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ ការណែនាំអំពីរចនាសម្ព័ន្ធនៃរបាយការណ៍ហិរញ្ញវត្ថុ និងលក្ខខណ្ឌចាំបាច់អប្បបរមាសម្រាប់ខ្លឹមសារដែលត្រូវបានរៀបចំតាមមូលដ្ឋានគណនេយ្យបង្គរ។<br>*វិសាលភាព÷* អនុវត្តចំពោះរបាយការណ៍ហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅទាំងអស់ដែលត្រូវបានរៀបចំ និងដាក់បង្ហាញតាមមូលដ្ឋានគណនេយ្យបង្គរ ដោយអនុលោមតាមស្តង់ដា IPSAS។ |
| ២. | **របាយការណ៍លំហូរសាច់ប្រាក់**<br>*គោលបំណង÷* ដើម្បីតម្រូវឱ្យមានការផ្តល់ព័ត៌មានស្តីពីការផ្លាស់ប្តូរសាច់ប្រាក់ជាប្រវត្តិសាស្ត្រ និងសាច់ប្រាក់សមមូលរបស់ស្ថាប័ន តាមរយៈរបាយការណ៍លំហូរសាច់ប្រាក់ដែលធ្វើចំណាត់ថ្នាក់លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ សកម្មភាពវិនិយោគ និងសកម្មភាពហិរញ្ញប្បទាន ក្នុងអំឡុងការិយបរិច្ឆេទ។ ព័ត៌មាននេះមានសារៈសំខាន់ចំពោះអ្នកប្រើប្រាស់ តាមរយៈការផ្តល់នូវព័ត៌មានសម្រាប់គោលបំណងគណនេយ្យភាព និងការធ្វើសេចក្តីសម្រេចចិត្ត។<br>របាយការណ៍លំហូរសាច់ប្រាក់ កំណត់÷<br>ក) ប្រភពនៃលំហូរចូលសាច់ប្រាក់<br>ខ) គណនីដែលសាច់ប្រាក់ត្រូវបានចំណាយនៅក្នុងអំឡុងការិយបរិច្ឆេទរាយការណ៍ និង |

| | |
|---|---|
| | គ) សមតុល្យសាច់ប្រាក់ នាកាលបរិច្ឆេទរាយការណ៍។<br>*វិសាលភាព÷* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន តាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវរៀបចំរបាយការណ៍លំហូរសាច់ប្រាក់មួយ ដោយអនុលោមតាមលក្ខខណ្ឌចាំបាច់នៃស្តង់ដា និងត្រូវដាក់បង្ហាញរបាយការណ៍លំហូរសាច់ប្រាក់នេះ ជាផ្នែកដ៏សំខាន់មួយនៃរបាយការណ៍ សម្រាប់ការិយបរិច្ឆេទនីមួយៗដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានដាក់បង្ហាញ។ |
| ៣. | **គោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង**<br>*គោលបំណង÷* ដើម្បីកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើស និងការផ្លាស់ប្តូរគោល-នយោបាយគណនេយ្យ ជាមួយគ្នានឹង÷<br>ក) ប្រព្រឹត្តកម្មគណនេយ្យ និងការលាតត្រដាងអំពីការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ<br>ខ) ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ និង<br>គ) ការកែតម្រូវកំហុសឆ្គង។<br>ស្តង់ដាមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវភាពពាក់ព័ន្ធ និងការបង្ហាញដ៏ស្មោះត្រង់នៃរបាយ-ការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នមួយ និងភាពដែលអាចប្រៀបធៀបគ្នាបាននៃរបាយការណ៍ហិរញ្ញវត្ថុទាំងនោះ នាឆ្នាំបន្តបន្ទាប់ និងជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នផ្សេងទៀត។<br>*វិសាលភាព÷* អនុវត្តចំពោះការជ្រើសរើស និងការអនុវត្តគោលនយោបាយគណនេយ្យ និងការអនុវត្តគណនេយ្យសម្រាប់ការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ និងការកែតម្រូវកំហុសឆ្គងដែលបានកើតឡើងនាការិយបរិច្ឆេទមុន។ |
| ៤. | **ឥទ្ធិពលនៃការផ្លាស់ប្តូរអត្រាប្តូរប្រាក់បរទេស**<br>*គោលបំណង÷* ដើម្បីកំណត់របៀបបញ្ចូលប្រតិបត្តិការជារូបិយបណ្ណបរទេស និងប្រតិបត្តិការបរទេសទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នមួយ និងរបៀបបកប្រែរបាយការណ៍ហិរញ្ញវត្ថុទៅជារូបិយបណ្ណសម្រាប់បង្ហាញ។<br>បញ្ហាចម្បង គឺថាតើអត្រាប្តូរប្រាក់អ្វីដែលត្រូវយកមកប្រើ និងរបៀបរាយការណ៍អំពីឥទ្ធិពលដែលកើតមានលើការផ្លាស់ប្តូរអត្រាប្តូរប្រាក់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ |

| | |
|---|---|
| | *វិសាលភាព÷* ស្ថាប័នមួយដែលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដា ក្នុងការ÷<br>ក) អនុវត្តគណនេយ្យសម្រាប់ប្រតិបត្តិការនិងសមតុល្យជារូបិយបណ្ណបរទេស (លើកលែងតែប្រតិបត្តិការដេរីវេទីវ និងសមតុល្យទាំងឡាយណាដែលស្ថិតក្រោមវិសាលភាពនៃស្តង់ដា IPSAS – ឧបករណ៍ហិរញ្ញវត្ថុ)<br>ខ) បកប្រែលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពហិរញ្ញវត្ថុនៃប្រតិបត្តិការបរទេសដែលត្រូវបានបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័ន តាមរយៈការរួមបញ្ចូល ឬវិធីសាស្ត្រមូលធន និង<br>គ) បកប្រែលទ្ធផលហិរញ្ញវត្ថុនិងស្ថានភាពហិរញ្ញវត្ថុរបស់ស្ថាប័ន ទៅជារូបិយបណ្ណសម្រាប់បង្ហាញ។ |
| ៥. | **បន្ទុកលើប្រាក់កម្ចី**<br>*គោលបំណង÷* ដើម្បីកំណត់ប្រព្រឹត្តិកម្មគណនេយ្យសម្រាប់បន្ទុកលើប្រាក់កម្ចី។ ជាទូទៅ វាតម្រូវឱ្យមានការចំណាយភ្លាមៗនៃបន្ទុកលើប្រាក់កម្ចី ប៉ុន្តែក៏អនុញ្ញាតឱ្យមានមូលធនភាវូបនីយកម្មនៃបន្ទុកលើប្រាក់កម្ចីដែលកើតឡើងដោយផ្ទាល់ពីការទិញ ការសាងសង់ ឬ ការផលិតទ្រព្យសកម្មមួយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ – ឧទាហរណ៍ ទ្រព្យសកម្មមួយដែលត្រូវការពេលវេលាច្រើន ដើម្បីរួចរាល់សម្រាប់ការប្រើប្រាស់ ឬការលក់ ទៅតាមការគ្រោងទុក។<br>*វិសាលភាព÷* អនុវត្តចំពោះការអនុវត្តគណនេយ្យសម្រាប់បន្ទុកលើប្រាក់កម្ចី។ |
| ៦. | ត្រូវបានជំនួសដោយ IPSAS 35 |
| ៧. | ត្រូវបានជំនួសដោយ IPSAS 36 |
| ៨. | ត្រូវបានជំនួសដោយ IPSAS 36 |
| ៩. | **ចំណូលពីប្រតិបត្តិការដោះដូរ**<br>*គោលបំណង÷* ដើម្បីកំណត់ប្រព្រឹត្តិកម្មគណនេយ្យសម្រាប់ចំណូលដែលកើតឡើងពីប្រតិបត្តិការនិងព្រឹត្តិការណ៍ដោះដូរ។ |

| | |
|---|---|
| | ប្រតិបត្តិការដោះដូរមួយ គឺជាប្រតិបត្តិការដែលស្ថាប័នមួយទទួលបានទ្រព្យសកម្ម ឬ សេវា ឬ មានបំណុលដែលត្រូវបានលុបបំបាត់ ហើយស្ទើរតែផ្តល់នូវតម្លៃស្មើដោយផ្ទាល់ (ក្នុងទម្រង់ជាសាច់ប្រាក់ ទំនិញ សេវា ឬការប្រើប្រាស់ទ្រព្យសកម្ម ទៅកាន់ស្ថាប័នផ្សេងទៀត ជាការដោះដូរ។<br>*វិសាលភាព÷* ស្ថាប័នមួយដែលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការអនុវត្តគណនេយ្យសម្រាប់ចំណូលដែលកើតឡើងពីប្រតិបត្តិការ ឬ ព្រឹត្តិការណ៍ដោះដូរ ដូចខាងក្រោម÷<br>ក) ការផ្តល់សេវា<br>ខ) ការលក់ទំនិញ និង<br>គ) ការប្រើប្រាស់ទ្រព្យសកម្មរបស់ស្ថាប័ន ដោយស្ថាប័នផ្សេងទៀត ដែលនាំឱ្យកើតមានការប្រាក់ សួយសារ និងភាគលាភ ឬ ការបែងចែកប្រហាក់ប្រហែល។<br>សូមកត់សម្គាល់ថា គណនីជាក់លាក់ត្រូវបានបរិយាយនៅក្នុងស្តង់ដាផ្សេងទៀត (ឧទាហរណ៍ចំណេញដែលកើតឡើងពីការលក់ទ្រព្យ រោងចក្រ និងបរិក្ខារ) និងជាលទ្ធផល ត្រូវបានដកចេញពីស្តង់ដានេះ។ |
| ១០. | **ការរាយការណ៍ហិរញ្ញវត្ថុនៅក្នុងប្រទេសដែលមានអតិផរណាខ្ពស់**<br>*គោលបំណង÷* ដើម្បីកំណត់ប្រព្រឹត្តិកម្មគណនេយ្យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម និងរបាយ-ការណ៍ហិរញ្ញវត្ថុដាច់ដោយឡែករបស់ស្ថាប័នមួយ ដែលរូបិយបណ្ណមុខងាររបស់ខ្លួនប្រឈមនឹងអតិផរណាខ្ពស់ និងនៅពេលដែលសេដ្ឋកិច្ចឈប់ប្រឈមនឹងអតិផរណាខ្ពស់។<br>*វិសាលភាព÷* ស្ថាប័នមួយដែលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនតាមស្តង់ដាមូលដ្ឋានបង្គរ ត្រូវអនុវត្តស្តង់ដាចំពោះរបាយការណ៍ហិរញ្ញវត្ថុសំខាន់ៗ រាប់បញ្ចូលទាំងរបាយការណ៍រួមរបស់ស្ថាប័នដែលរូបិយបណ្ណមុខងាររបស់ខ្លួនគឺជារូបិយបណ្ណរបស់ប្រទេសដែលមានអតិផរណាខ្ពស់។ |
| ១១. | **កិច្ចសន្យាសាងសង់**<br>*គោលបំណង÷* ដើម្បីកំណត់ប្រព្រឹត្តិកម្មគណនេយ្យសម្រាប់ថ្លៃដើម និងចំណូលដែលពាក់ព័ន្ធនឹងកិច្ចសន្យាសាងសង់។ ស្តង់ដា÷<br>ក) កំណត់កិច្ចព្រមព្រៀងដែលនឹងត្រូវធ្វើចំណាត់ថ្នាក់ជាកិច្ចសន្យាសាងសង់ |

| | |
|---|---|
| | ខ) ផ្តល់ការណែនាំស្តីពីប្រភេទកិច្ចសន្យាសាងសង់ដែលអាចកើតឡើងក្នុងវិស័យសាធារណៈ និង<br>គ) បញ្ជាក់មូលដ្ឋានសម្រាប់ការទទួលស្គាល់និងការលាតត្រដាងអំពីចំណាយកិច្ចសន្យា និង ចំណូលកិច្ចសន្យា បើមានភាពពាក់ព័ន្ធ។<br>បញ្ហាចម្បងក្នុងការអនុវត្តគណនេយ្យសម្រាប់កិច្ចសន្យាសាងសង់ គឺការបែងចែកថ្លៃដើមនៃការសាងសង់ ទៅកាន់ការិយបរិច្ឆេទរាយការណ៍ដែលការងារត្រូវបានអនុវត្ត និងការទទួលស្គាល់ចំណាយពាក់ព័ន្ធ។<br>*វិសាលភាព÷* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ តាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការអនុវត្តគណនេយ្យសម្រាប់កិច្ចសន្យាសាងសង់។ |
| ១២. | **សន្និធិ**<br>*គោលបំណង÷* ដើម្បីកំណត់ប្រព្រឹត្តិកម្មគណនេយ្យត្រឹមត្រូវសម្រាប់សន្និធិ– ចំនួនថ្លៃដើមដែលត្រូវទទួលស្គាល់ជាទ្រព្យសកម្មមួយ និងយោងទៅពេលខាងមុខ រហូតចំណូលពាក់ព័ន្ធត្រូវបានទទួលស្គាល់។ ស្តង់ដាផ្តល់ការណែនាំអំពីការកំណត់ថ្លៃដើម និងការទទួលស្គាល់បន្ត ជាចំណាយរួមបញ្ចូលទាំងការធ្លាក់ចុះតម្លៃទ្រព្យសកម្ម ទៅជាតម្លៃទទួលស្គាល់ពិត។<br>*វិសាលភាព÷* ស្ថាប័នមួយដែលអនុវត្តស្តង់ដាមូលដ្ឋានបង្គរ ត្រូវអនុវត្តស្តង់ដាសម្រាប់សន្និធិទាំងអស់ លើកលែងតែការងារកំពុងដំណើរការលើកិច្ចសន្យាសាងសង់ (IPSAS), ឧបករណ៍ហិរញ្ញវត្ថុ (IPSAS និង 41), ទ្រព្យសកម្មជីវសាស្ត្រពាក់ព័ន្ធនឹងសកម្មភាពកសិកម្ម និងកសិផល (IPSAS) និងការងារកំពុងដំណើរការសម្រាប់សេវា ដោយគ្មាន ឬ មានតម្លៃពិត។ |
| ១៣. | **ភតិសន្យា**<br>*គោលបំណង÷* ដើម្បីកំណត់គោលនយោបាយគណនេយ្យ និងការលាតត្រដាងសមស្រប ពាក់ព័ន្ធនឹងភតិសន្យាហិរញ្ញវត្ថុ និងភតិសន្យាកិច្ចប្រតិបត្តិការ ទាំងសម្រាប់ភតិបតី និងភតិកៈ។<br>*វិសាលភាព÷* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការអនុវត្តគណនេយ្យសម្រាប់ភតិសន្យាទាំងអស់ជាជាង÷<br>ក) ភតិសន្យាដើម្បីស្វែងរក ឬ ប្រើប្រាស់រ៉ែ ប្រេង ឧស្ម័ន និងធនធានប្រហាក់ប្រហែល និង |

| | |
|---|---|
| | ខ) កិច្ចព្រមព្រៀងផ្តល់អាជ្ញាបណ្ណសម្រាប់ខ្សែភាពយន្ត, ទស្សនីយភាព, ការថតខ្សែភាពយន្ត, ខ្សែភាពយន្ត, អត្ថបទសរសេរ, ប៉ាតង់ និងកម្មសិទ្ធិបញ្ញា។<br>គ) ទ្រព្យវិនិយោគ និងទ្រព្យសកម្មជីវសាស្ត្រដែលត្រូវបានរក្សាទុកដោយភតិបតី និងភតិកៈ។ |
| ១៤. | **ព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍**<br>*គោលបំណង៖* ដើម្បីកំណត់ពេលវេលាដែលស្ថាប័នមួយគួរកែតម្រូវរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនសម្រាប់ព្រឹត្តិការណ៍ដែលកើតឡើងបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ និងការលាតត្រដាងដែលស្ថាប័នមួយគួរធ្វើ សម្រាប់កាលបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានផ្តល់សិទ្ធិក្នុងការចេញផ្សាយ និងសម្រាប់ព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។ នៅពេលដែលការសន្មតអំពីនិរន្តរភាព មិនមានភាពសមស្រប ស្ថាប័នមិនត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ផ្អែកលើមូលដ្ឋាននិរន្តរភាពទេ។<br>ព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ គឺជាព្រឹត្តិការណ៍ទាំងឡាយណាដែលសមប្រកប និងមិនសមប្រកប ដែលកើតឡើងរវាងកាលបរិច្ឆេទរាយការណ៍និងកាលបរិច្ឆេទដែលរបាយ-ការណ៍ហិរញ្ញវត្ថុត្រូវបានផ្តល់សិទ្ធិក្នុងការចេញផ្សាយ។<br>*វិសាលភាព៖* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការអនុវត្តគណនេយ្យ និងការលាតត្រដាងអំពីព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។ |
| ១៥. | ត្រូវបានជំនួសដោយ IPSAS 28 & 30 |
| ១៦. | **ទ្រព្យវិនិយោគ**<br>*គោលបំណង៖* ដើម្បីកំណត់ប្រព្រឹត្តិកម្មគណនេយ្យនិងលក្ខខណ្ឌចាំបាច់នៃការលាតត្រដាងសម្រាប់ទ្រព្យវិនិយោគ។ ទ្រព្យវិនិយោគ គឺជាទ្រព្យដែលត្រូវបានរក្សាទុក ដើម្បីទទួលបានកម្រៃពីការជួល ឬសម្រាប់ការកើនឡើងតម្លៃមូលធន ជាជាងសម្រាប់ការប្រើប្រាស់ក្នុងការផ្តល់ការលក់ ឬសេវា ឬសម្រាប់គោលបំណងរដ្ឋបាល ឬសម្រាប់ការលក់ជាសកម្មភាពប្រតិបត្តិការធម្មតា។<br>*វិសាលភាព៖* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការអនុវត្តគណនេយ្យសម្រាប់ទ្រព្យវិនិយោគ។ |

| | |
|---|---|
| ១៧. | **ទ្រព្យ រោងចក្រ និងបរិក្ខារ**<br>*គោលបំណង÷* ដើម្បីកំណត់ប្រព្រឹត្តិកម្មគណនេយ្យសម្រាប់ទ្រព្យ រោងចក្រ និងបរិក្ខារ ដូច្នេះ អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ អាចស្វែងយល់ព័ត៌មានអំពីការវិនិយោគរបស់ស្ថាប័នមួយទៅលើទ្រព្យសកម្ម និងការផ្លាស់ប្ដូរការវិនិយោគទាំងនេះ។ បញ្ហាគណនេយ្យចម្បងគឺការទទួលស្គាល់ទ្រព្យសកម្ម ការកំណត់តម្លៃទីផ្សារ និងចំណាយរំលស់ និងការខាតបង់លើការធ្លាក់ចុះតម្លៃដែលត្រូវអនុវត្តគណនេយ្យ។<br>*វិសាលភាព÷* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការអនុវត្តគណនេយ្យសម្រាប់ទ្រព្យ រោងចក្រ និងបរិក្ខារ លើកលែងតែនៅពេលដែលស្តង់ដា IPSAS ផ្សេងទៀត តម្រូវឱ្យមានប្រព្រឹត្តកម្មគណនេយ្យផ្សេងពីនេះ និងពាក់ព័ន្ធនឹងទ្រព្យសកម្មបេតិកភណ្ឌដែលមិនស្ថិតក្រោមវិសាលភាពនៃស្តង់ដា។ |
| ១៨. | **ការរាយការណ៍តាមផ្នែក**<br>*គោលបំណង÷* ដើម្បីបង្កើតគោលការណ៍ សម្រាប់រាយការណ៍ព័ត៌មានហិរញ្ញវត្ថុសម្រាប់ផ្នែកនៃអាជីវកម្ម។ ផ្នែកនៃអាជីវកម្ម គឺជាសកម្មភាព ឬក្រុមសកម្មភាពដាច់ដោយឡែកមួយរបស់ស្ថាប័នមួយ ដែលវាមានភាពសមស្របដើម្បីរាយការណ៍ដាច់ដោយឡែកអំពីព័ត៌មានហិរញ្ញវត្ថុ ក្នុងគោលបំណងដើម្បីវាយតម្លៃពីសមិទ្ធកម្មការងារនាពេលកន្លងមករបស់ស្ថាប័ន ក្នុងការសម្រេចបាននូវគោលបំណង និងការធ្វើសេចក្ដីសម្រេចចិត្តរបស់ខ្លួនអំពីការបែងចែកធនធាននាពេលអនាគត។<br>*វិសាលភាព÷* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការដាក់បង្ហាញព័ត៌មានតាមផ្នែក។ |
| ១៩. | **សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ**<br>*គោលបំណង÷* ដើម្បីកំណត់និយមន័យអំពីសំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ និងកំណត់ស្ថានភាពដែលសំវិធានធនគួរត្រូវបានទទួលស្គាល់និងវាស់វែង និងរបៀបដែលសំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ ត្រូវបានលាតត្រដាង។ ស្តង់ដាក៏បានតម្រូវឱ្យមានការលាតត្រដាងព័ត៌មានជាក់លាក់អំពីយថាហេតុនៅក្នុងកំណត់សម្គាល់ |

| | |
|---|---|
| | លើរបាយការណ៍ហិរញ្ញវត្ថុផងដែរ ដើម្បីអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចយល់ពីចរិកលក្ខណៈ, ពេលវេលា និងចំនួននៃយថាហេតុទាំងនោះ។<br>*វិសាលភាព÷* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការអនុវត្តគណនេយ្យសម្រាប់សំវិធានធន, បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ លើកលែងតែស្ថិតក្រោមកាតព្វកិច្ចសុខុមាលភាពសង្គម, កិច្ចសន្យាប្រតិបត្តិ, កិច្ចសន្យាធានារ៉ាប់រង ដែលពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល ឬពន្ធសមមូល, អត្ថប្រយោជន៍និយោជិត ឬ ស្ថិតក្រោមវិសាលភាពនៃស្តង់ដា IPSAS ផ្សេងទៀត។ |
| ២០. | **ការលាតត្រដាងអំពីភាគីពាក់ព័ន្ធ**<br>*គោលបំណង÷* ដើម្បីតម្រូវឱ្យមានការលាតត្រដាងអំពីការកើតឡើងនូវទំនាក់ទំនងរបស់ភាគីពាក់ព័ន្ធ នៅពេលមានការគ្រប់គ្រង និងការលាតត្រដាងព័ត៌មានអំពីប្រតិបត្តិការរវាងស្ថាប័ននិងភាគីពាក់ព័ន្ធរបស់ខ្លួនក្នុងស្ថានភាពជាក់លាក់។ ជាការតម្រូវសម្រាប់គោលបំណងគណនេយ្យភាពបញ្ហាចម្បង គឺការកំណត់ថាតើភាគីមួយណាជាអ្នកគ្រប់គ្រង ឬមានឥទ្ធិពលជាសារវ័ន្តលើស្ថាប័នរាយការណ៍ និងការកំណត់ថាតើព័ត៌មានអ្វីដែលគួរត្រូវបានលាតត្រដាងអំពីប្រតិបត្តិការជាមួយភាគីទាំងនោះ។<br>*វិសាលភាព÷* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការលាតត្រដាងព័ត៌មានអំពីប្រតិបត្តិការរបស់ភាគីពាក់ព័ន្ធ និងប្រតិបត្តិការជាក់លាក់ជាមួយភាគីពាក់ព័ន្ធ។ |
| ២១. | **ការធ្លាក់ចុះតម្លៃទ្រព្យសកម្មដែលមិនបង្កើតសាច់ប្រាក់**<br>*គោលបំណង÷* ដើម្បីកំណត់នីតិវិធីក្នុងការកំណត់ថាតើទ្រព្យសកម្មមួយដែលមិនបង្កើតសាច់-ប្រាក់ ត្រូវបានធ្លាក់ចុះតម្លៃ ឬក៏អត់ និងដើម្បីធានាថា ការខាតបង់លើការធ្លាក់ចុះតម្លៃ ត្រូវបានទទួលស្គាល់។ ស្តង់ដាក៏បានកំណត់ថាតើនៅពេលណាដែលស្ថាប័នមួយត្រូវបង្វិលត្រលប់មកវិញនូវការខាតបង់លើការធ្លាក់ចុះតម្លៃ និងកំណត់ការលាតត្រដាង។ ទ្រព្យសកម្មដែលបង្កើតសាច់ប្រាក់ គឺជាទ្រព្យសកម្មទាំងឡាយណាដែលត្រូវបានរក្សាទុក ក្នុងគោលបំណងសំខាន់ដើម្បីទទួលបានផលចំណេញ។ |

| | |
|---|---|
| | *វិសាលភាព៖* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ តាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការអនុវត្តគណនេយ្យសម្រាប់ការធ្លាក់ចុះតម្លៃទ្រព្យសកម្មដែលមិនបង្កើតសាច់ប្រាក់ លើកលែងតែសន្និធិ (IPSAS), ទ្រព្យសកម្មពីកិច្ចសន្យាសាងសង់ (IPSAS), ទ្រព្យសកម្មហិរញ្ញវត្ថុតាមស្តង់ដា IPSAS, ទ្រព្យវិនិយោគ (IPSAS) ឬ ស្តង់ដា IPSAS ផ្សេងទៀត។ |
| ២២. | **ការលាតត្រដាងអំពីព័ត៌មានហិរញ្ញវត្ថុ - វិស័យរដ្ឋាភិបាលទូទៅ**<br>*គោលបំណង៖* ដើម្បីកំណត់លក្ខខណ្ឌចាំបាច់នៃការលាតត្រដាង នៅពេលដែលរាជរដ្ឋាភិបាលជ្រើសរើសក្នុងការដាក់បង្ហាញព័ត៌មានអំពីវិស័យរដ្ឋាភិបាលទូទៅ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ខ្លួន។ វាពាក់ព័ន្ធនឹងតម្លាភាពនៃរបាយការណ៍ហិរញ្ញវត្ថុ និងផ្តល់ការយល់ដឹងកាន់តែប្រសើរអំពីទំនាក់ទំនងរវាងសកម្មភាពទីផ្សារ និងសកម្មភាពមិនមែនទីផ្សាររបស់រាជរដ្ឋាភិបាល និងរវាងរបាយការណ៍ហិរញ្ញវត្ថុជាមួយនឹងមូលដ្ឋានស្ថិតិនៃការរាយការណ៍ហិរញ្ញវត្ថុ។<br>*វិសាលភាព៖* នៅពេលដែលរាជរដ្ឋាភិបាលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួមតាមមូលដ្ឋានគណនេយ្យបង្គរ ហើយជ្រើសរើសក្នុងការលាតត្រដាងព័ត៌មានហិរញ្ញវត្ថុអំពីវិស័យរដ្ឋាភិបាលទូទៅ នោះរាជរដ្ឋាភិបាលត្រូវអនុវត្តបែបនេះ ដោយអនុលោមតាមស្តង់ដានេះ។ |
| ២៣. | **ចំណូលពីប្រតិបត្តិការដែលមិនមែនជាការដោះដូរ (ពន្ធ និងការផ្ទេរ)**<br>*គោលបំណង៖* ដើម្បីកំណត់លក្ខខណ្ឌចាំបាច់សម្រាប់ការរាយការណ៍ហិរញ្ញវត្ថុអំពីចំណូលពីប្រតិបត្តិការដែលមិនមែនជាការដោះដូរ ជាជាងប្រតិបត្តិការដែលនាំឱ្យកើតមានការរួមបញ្ចូលចំណាយសាធារណៈ។ ស្តង់ដាដោះស្រាយបញ្ហាដែលត្រូវយកមកពិចារណាក្នុងការទទួលស្គាល់ និងការវាស់វែងចំណូលពីប្រតិបត្តិការដែលមិនមែនជាការដោះដូរ រួមបញ្ចូលទាំងការកំណត់អត្តសញ្ញាណនៃការចូលរួមវិភាគទានពីម្ចាស់ផងដែរ។ ប្រតិបត្តិការដែលមិនមែនជាការដោះដូរ គឺជាប្រតិបត្តិការទាំងឡាយណាដែលគ្មានការដោះដូរណាមួយដែលមានតម្លៃស្មើឡើយ។<br>*វិសាលភាព៖* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការអនុវត្តគណនេយ្យសម្រាប់ចំណូលពីប្រតិបត្តិការដែលមិនមែនជាការដោះដូរ។ |

| | |
|---|---|
| ២៤. | **ការដាក់បង្ហាញព័ត៌មានអំពីផែនការថវិកានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ**<br>*គោលបំណង៖* ដើម្បីធានាថា របាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលនូវការប្រៀបធៀបផែនការថវិកា និងចំនួនទឹកប្រាក់ជាក់ស្តែងដែលកើតឡើងពីការអនុវត្តផែនការថវិការបស់ស្ថាប័នដែលត្រូវបានតម្រូវ ឬ ជ្រើសរើសក្នុងការផ្សព្វផ្សាយផែនការថវិកាដែលបានអនុម័តរបស់ខ្លួនជាសាធារណៈ។ ស្តង់ដាក៏បានតម្រូវឱ្យមានការលាតត្រដាងអំពីភាពខុសគ្នាជាសារវន្តរវាងផែនការថវិកានិងចំនួនទឹកប្រាក់ជាក់ស្តែងផងដែរ។ គោលបំណងនៃការលាតត្រដាងនេះគឺដើម្បីធានាថាស្ថាប័នមានការទទួលខុសត្រូវលើកាតព្វកិច្ចគណនេយ្យភាព និងតម្លាភាពរបស់ខ្លួន។<br>*វិសាលភាព៖* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដា។ ស្តង់ដាអនុវត្តចំពោះស្ថាប័នសាធារណៈដែលត្រូវបានតម្រូវ ឬ ជ្រើសរើសក្នុងការផ្សព្វផ្សាយផែនការថវិកាដែលបានអនុម័តរបស់ខ្លួនជាសាធារណៈ។ |
| ២៥. | ត្រូវបានជំនួសដោយ IPSAS 39 |
| ២៦. | **ការធ្លាក់ចុះតម្លៃទ្រព្យសកម្មដែលបង្កើតសាច់ប្រាក់**<br>*គោលបំណង៖* ដើម្បីកំណត់នីតិវិធីដែលស្ថាប័នមួយអនុវត្ត ក្នុងការកំណត់ថាតើទ្រព្យសកម្មមួយដែលបង្កើតសាច់ប្រាក់ ត្រូវបានធ្លាក់ចុះតម្លៃ ឬក៏អត់ និងដើម្បីធានាថា ការខាតបង់លើការធ្លាក់ចុះតម្លៃ ត្រូវបានទទួលស្គាល់។ ស្តង់ដាក៏អនុវត្តនៅពេលដែលការខាតបង់ ត្រូវបានបង្វិលត្រលប់មកវិញ និងកំណត់ការលាតត្រដាង។<br>*វិសាលភាព៖* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការអនុវត្តគណនេយ្យសម្រាប់ការធ្លាក់ចុះតម្លៃទ្រព្យសកម្មដែលបង្កើតសាច់ប្រាក់ លើកលែងតែសន្និធិ (IPSAS), ទ្រព្យសកម្មពីកិច្ចសន្យាសាងសង់ (IPSAS), ទ្រព្យសកម្មហិរញ្ញវត្ថុតាមស្តង់ដា IPSAS, ទ្រព្យវិនិយោគ (IPSAS), ទ្រព្យសកម្មជីវសាស្ត្រក្រោមវិសាលភាពនៃវិស័យកសិកម្ម (IPSAS), ទ្រព្យសកម្មដែលកើតឡើងពីអត្ថប្រយោជន៍និយោជិត (IPSAS 9) ឬ ស្តង់ដា IPSAS ផ្សេងទៀត។ គណនីផ្សេងទៀតដែលមិនស្ថិតក្រោមវិសាលភាព រួមមាន ទ្រព្យសកម្មពន្ធពន្យារ, ថ្លៃដើមនៃការទិញពន្យារ និងទ្រព្យសកម្មអរូបី ដែលកើតឡើងពីសិទ្ធិកិច្ចសន្យារបស់អ្នកធានា។ |

| | |
|---|---|
| ២៧. | **វិស័យកសិកម្ម**<br>*គោលបំណង÷* ដើម្បីកំណត់ប្រព្រឹត្តិកម្មគណនេយ្យនិងការលាតត្រដាងសម្រាប់សកម្មភាពកសិកម្មដែលស្ថាប័នបានអនុវត្ត។ សកម្មភាពទាំងនេះជាទូទៅមិនមែនជាការធ្វើអាជីវកម្មឡើយ។<br>*វិសាលភាព÷* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការអនុវត្តគណនេយ្យសម្រាប់គណនីខាងក្រោម នៅពេលគណនីទាំងនេះជាប់ពាក់ព័ន្ធនឹងសកម្មភាពកសិកម្ម ដូចជា ទ្រព្យសកម្មជីវសាស្ត្រ (លើកលែងតែរុក្ខជាតិដែលផ្តល់ទិន្នផលលើសពីមួយការិយបរិច្ឆេទ) និងផលិតផលកសិកម្មនាពេលប្រមូលផល។ |
| ២៨. | **ឧបករណ៍ហិរញ្ញវត្ថុ÷ ការដាក់បង្ហាញ**<br>*គោលបំណង÷* ដើម្បីបង្កើតគោលការណ៍សម្រាប់ការធ្វើចំណាត់ថ្នាក់ និងការដាក់បង្ហាញឧបករណ៍ហិរញ្ញវត្ថុ ជាបំណុល ឬ ទ្រព្យសកម្ម/ មូលធនសុទ្ធ និងសម្រាប់ការកាត់កងទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ។ ការអនុវត្តចំពោះឧបករណ៍ហិរញ្ញវត្ថុ វាក៏គ្របដណ្តប់ផងដែរលើការធ្វើចំណាត់ថ្នាក់ការប្រាក់, ភាគលាភ ឬ ការចូលរួមវិភាគទានប្រហាក់ប្រហែល, ការខាតបង់ និងចំណេញ និងស្ថានភាពដែលទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុ គួរត្រូវបានកាត់កង។<br>គោលការណ៍នៃស្តង់ដានេះ បំពេញបន្ថែមឱ្យស្តង់ដា IPSAS÷ ឧបករណ៍ហិរញ្ញវត្ថុ÷ ការទទួលស្គាល់ និងការវាស់វែង និងស្តង់ដា IPSAS÷ ឧបករណ៍ហិរញ្ញវត្ថុ÷ ការលាតត្រដាង។<br>*វិសាលភាព÷* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាចំពោះឧបករណ៍ហិរញ្ញវត្ថុគ្រប់ប្រភេទទាំងអស់ លើកលែងតែទិដ្ឋភាពជាក់លាក់មួយចំនួនសម្រាប់ស្ថាប័នដែលស្ថិតក្រោមវិសាលភាពនៃស្តង់ដា IPSAS÷ របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក, ស្តង់ដា IPSAS÷ របាយការណ៍ហិរញ្ញវត្ថុរួម និងស្តង់ដា IPSAS 6÷ ការវិនិយោគនៅក្នុងញាតិសម្ព័ន្ធ និងក្រុមហ៊ុនរួមទុន ក៏ដូចជាស្តង់ដា IPSAS 9÷ អត្ថប្រយោជន៍សង្គម និងកាតព្វកិច្ចជាក់លាក់ដែលកើតឡើងពីកិច្ចសន្យាធានារ៉ាប់រង។ |
| ២៩. | ត្រូវបានជំនួសដោយ IPSAS 41 |
| ៣០. | **ឧបករណ៍ហិរញ្ញវត្ថុ÷ ការលាតត្រដាង** |

| | |
|---|---|
| | *គោលបំណង÷* ដើម្បីតម្រូវឱ្យស្ថាប័នផ្តល់ការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចវាយតម្លៃពី÷<br>ក) ភាពជាសារវ័ន្តនៃឧបករណ៍ហិរញ្ញវត្ថុសម្រាប់ស្ថានភាពហិរញ្ញវត្ថុនិងលទ្ធផលហិរញ្ញវត្ថុរបស់ស្ថាប័ន និង<br>ខ) ចរិតលក្ខណៈ និងវិសាលភាពនៃហានិភ័យដែលកើតឡើងពីឧបករណ៍ហិរញ្ញវត្ថុដែលស្ថាប័នប្រឈមនៅក្នុងអំឡុងការិយបរិច្ឆេទនិងចុងការិយបរិច្ឆេទរាយការណ៍ ជាមួយនឹងរបៀបដែលស្ថាប័នគ្រប់គ្រងហានិភ័យទាំងនោះ។<br>គោលការណ៍នៃស្តង់ដានេះ បំពេញបន្ថែមឱ្យស្តង់ដា IPSAS÷ ឧបករណ៍ហិរញ្ញវត្ថុ÷ ការដាក់បង្ហាញ និងស្តង់ដា IPSAS÷ ឧបករណ៍ហិរញ្ញវត្ថុ÷ ការទទួលស្គាល់ និងការវាស់វែង។<br>*វិសាលភាព÷* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាសម្រាប់ឧបករណ៍ហិរញ្ញវត្ថុគ្រប់ប្រភេទទាំងអស់ លើកលែងតែទិដ្ឋភាពជាក់លាក់មួយចំនួនសម្រាប់ស្ថាប័នដែលស្ថិតក្រោមវិសាលភាពនៃស្តង់ដា IPSAS÷ របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក, ស្តង់ដា IPSAS÷ របាយការណ៍ហិរញ្ញវត្ថុរួម និងស្តង់ដា IPSAS 6÷ ការវិនិយោគនៅក្នុងញាតិសម្ព័ន្ធ និងក្រុមហ៊ុនរួមទុន ក៏ដូចជាស្តង់ដា IPSAS 9÷ អត្ថប្រយោជន៍សង្គម និងកាតព្វកិច្ចជាក់លាក់ដែលកើតឡើងពីកិច្ចសន្យាធានារ៉ាប់រង។ |
| ៣១. | **ទ្រព្យសកម្មអរូបិយ**<br>*គោលបំណង÷* ដើម្បីកំណត់ប្រព្រឹត្តិកម្មគណនេយ្យសម្រាប់ទ្រព្យសកម្មអរូបិយ ដែលមិនត្រូវបានបង្ហាញជាពិសេសនៅក្នុងស្តង់ដាផ្សេងទៀត។ លក្ខណៈវិនិច្ឆ័យជាក់លាក់ត្រូវបំពេញឱ្យបាន។ ស្តង់ដា ក៏បានកំណត់របៀបវាស់វែងតម្លៃទីផ្សារនៃទ្រព្យសកម្មអរូបិយ និងតម្រូវឱ្យមានការលាតត្រដាងជាក់លាក់អំពីទ្រព្យសកម្មអរូបិយ។<br>ទ្រព្យសកម្មអរូបិយមួយ គឺជាទ្រព្យសកម្មមិនមែនរូបិយវត្ថុដែលអាចកំណត់បានមួយ ដែលគ្មានរូបរាង។<br>*វិសាលភាព÷* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការអនុវត្តគណនេយ្យសម្រាប់ទ្រព្យសកម្មអរូបិយ (ដូចជា |

| | |
|---|---|
| | កម្មសិទ្ធិបញ្ញា ប៉ាតង់ កម្មវិធី ទ្រព្យសកម្មបេតិកភណ្ឌអរូបិយ និងកិច្ចព្រមព្រៀងផ្តល់អាជ្ញាបណ្ណ ជាដើម)។ |
| ៣២. | **កិច្ចព្រមព្រៀងសម្បទានសេវា**<br>*គោលបំណង÷* ដើម្បីកំណត់ប្រព្រឹត្តិកម្មគណនេយ្យសម្រាប់កិច្ចព្រមព្រៀងសម្បទានសេវាដែលធ្វើឡើងដោយអនុប្បទាយី ដែលជាស្ថាប័នសាធារណៈមួយ។<br>កិច្ចព្រមព្រៀងសម្បទានសេវា សំដៅដល់កិច្ចព្រមព្រៀងដែលត្រូវប្រតិបត្តិតាម រវាងអនុប្បទាយី និងប្រតិបត្តិករមួយ នៅពេលដែលប្រតិបត្តិករប្រើប្រាស់ទ្រព្យសកម្មរបស់អនុប្បទាយីក្នុងការផ្តល់សេវាសាធារណៈជំនួសឱ្យអនុប្បទាយី ក្នុងរយៈពេលកំណត់ជាក់លាក់មួយ ហើយប្រតិបត្តិករត្រូវបានផ្តល់សំណងសម្រាប់សេវារបស់ខ្លួននៅក្នុងអំឡុងពេលនោះ (ឧទាហរណ៍ ភាពជាដៃគូ រវាងវិស័យសាធារណៈ និងវិស័យឯកជន ឬ ផ្លូវបង់ប្រាក់ ជាដើម)។<br>*វិសាលភាព÷* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការអនុវត្តគណនេយ្យសម្រាប់កិច្ចព្រមព្រៀងសម្បទានសេវា។ |
| ៣៣. | **ការអនុវត្តមូលដ្ឋានបង្គរជាលើកដំបូង**<br>*គោលបំណង÷* ដើម្បីផ្តល់ការណែនាំដល់អ្នកអនុវត្តជាលើកដំបូង ដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុវត្តតាមស្តង់ដា Accrual Basis IPSAS ដើម្បីដាក់បង្ហាញព័ត៌មានដែលមានគុណភាពខ្ពស់ ដែល÷<br>ក) ផ្តល់ការរាយការណ៍ប្រកបដោយតម្លាភាពអំពីការផ្លាស់ប្តូរទៅកាន់ស្តង់ដា Accrual Basis IPSAS របស់អ្នកអនុវត្តជាលើកដំបូង<br>ខ) ផ្តល់ចំណុចចាប់ផ្តើមដ៏សមស្របមួយ សម្រាប់ការអនុវត្តគណនេយ្យ ដោយអនុលោមតាមស្តង់ដា Accrual Basis IPSAS ដោយមិនគិតពីមូលដ្ឋានគណនេយ្យដែលអ្នកអនុវត្តជាលើកដំបូងបានប្រើប្រាស់ មុនកាលបរិច្ឆេទនៃការអនុវត្ត និង<br>គ) នៅពេលដែលអត្ថប្រយោជន៍ត្រូវបានរំពឹងថានឹងលើសថ្លៃដើម។ |

| | |
|---|---|
| | *វិសាលភាព៖* ស្ថាប័នមួយត្រូវអនុវត្តស្តង់ដា IPSAS នេះ នៅពេលដែលស្ថាប័នរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួន នៅពេលអនុវត្ត និងនៅក្នុងអំឡុងពេលនៃការផ្លាស់ប្តូរទៅកាន់មូលដ្ឋានគណនេយ្យបង្គរ។ |
| ៣៤. | **របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក**<br><br>*គោលបំណង៖* ដើម្បីកំណត់ការអនុវត្តគណនេយ្យ និងលក្ខខណ្ឌចាំបាច់នៃការលាតត្រដាងសម្រាប់ការវិនិយោគនៅក្នុងស្ថាប័នក្រោមការគ្រប់គ្រង, ក្រុមហ៊ុនរួមទុន និងញាតិសម្ព័ន្ធ នៅពេលដែលស្ថាប័នមួយរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន។<br><br>*វិសាលភាព:* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការអនុវត្តគណនេយ្យសម្រាប់ការវិនិយោគនៅក្នុងស្ថាប័នក្រោមការគ្រប់គ្រង, ក្រុមហ៊ុនរួមទុន និងញាតិសម្ព័ន្ធ នៅពេលដែលស្ថាប័នជ្រើសរើស ឬ ត្រូវបានតម្រូវដោយបទប្បញ្ញត្តិ ដើម្បីដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក។ |
| ៣៥. | **របាយការណ៍ហិរញ្ញវត្ថុរួម**<br><br>*គោលបំណង៖* ដើម្បីបង្កើតគោលការណ៍សម្រាប់ការរៀបចំនិងការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម នៅពេលដែលស្ថាប័ន គ្រប់គ្រងស្ថាប័នផ្សេងទៀតមួយ ឬ ច្រើន។<br><br>ដើម្បីសម្រេចបានគោលបំណងនេះ ស្តង់ដា៖<br>ក) តម្រូវឱ្យស្ថាប័នគ្រប់គ្រង ដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម ដែលរួមបញ្ចូលនូវស្ថាប័នក្រោមការគ្រប់គ្រង<br>ខ) កំណត់និយមន័យអំពីគោលការណ៍នៃការគ្រប់គ្រង និងបង្កើតការគ្រប់គ្រង ជាមូលដ្ឋានសម្រាប់ការរួមបញ្ចូល<br>គ) កំណត់របៀបអនុវត្តគោលការណ៍នៃការគ្រប់គ្រង ដើម្បីកំណត់នៅពេលមានការគ្រប់គ្រងកើតឡើង និងជាលទ្ធផល ថាតើការរួមបញ្ចូលមានភាពចាំបាច់ដែរឬទេ<br>ឃ) កំណត់លក្ខខណ្ឌចាំបាច់នៃការអនុវត្តគណនេយ្យ សម្រាប់ការរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរួម និង |

| | |
|---|---|
| | ង) កំណត់និយមន័យអំពីស្ថាប័នវិនិយោគមួយ និងកំណត់ករណីលើកលែងចំពោះការរួមបញ្ចូលស្ថាប័នក្រោមការគ្រប់គ្រងជាក់លាក់របស់ស្ថាប័នវិនិយោគ។<br>*វិសាលភាព៖* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការរៀបចំ និងការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួមសម្រាប់ស្ថាប័នសេដ្ឋកិច្ច។ |
| ៣៦. | **ការវិនិយោគនៅក្នុងញាតិសម្ព័ន្ធ និងក្រុមហ៊ុនរួមទុន**<br>*គោលបំណង៖* ដើម្បីកំណត់វិធានគណនេយ្យ សម្រាប់ការអនុវត្តគណនេយ្យលើការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ និងក្រុមហ៊ុនរួមទុន និងដើម្បីកំណត់លក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តវិធីសាស្ត្រមូលធន នៅពេលអនុវត្តគណនេយ្យលើការវិនិយោគទាំងនោះ។<br>*វិសាលភាព៖* ស្ថាប័នមួយដែលរៀបចំនិងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការអនុវត្តគណនេយ្យសម្រាប់ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ និងក្រុមហ៊ុនរួមទុន។ ស្តង់ដានឹងត្រូវបានអនុវត្តដោយស្ថាប័នទាំងអស់ដែលជាវិនិយោគិន ដែលមានឥទ្ធិពល ឬ ការគ្រប់គ្រងរួមទៅលើអង្គភាពរងការវិនិយោគ នៅពេលការវិនិយោគនាំទៅរកការកាន់កាប់បរធនបាលកម្មសិទ្ធិដែលអាចកំណត់បាន។ |
| ៣៧. | **កិច្ចព្រមព្រៀងរួម**<br>*គោលបំណង៖* ដើម្បីបង្កើតគោលការណ៍សម្រាប់ការរាយការណ៍ហិរញ្ញវត្ថុដោយស្ថាប័នដែលមានអត្ថប្រយោជន៍នៅក្នុងកិច្ចព្រមព្រៀងគ្រប់គ្រងរួម។ ដើម្បីសម្រេចបាននូវគោលបំណងនេះ ស្តង់ដាកំណត់និយមន័យអំពីការគ្រប់គ្រងរួម និងតម្រូវឱ្យស្ថាប័នដែលជាភាគីនៃកិច្ចព្រមព្រៀងរួមធ្វើការកំណត់ចរិតលក្ខណៈនៃកិច្ចព្រមព្រៀងឱ្យបានច្បាស់លាស់ តាមរយៈការវាយតម្លៃពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន និងដើម្បីទទួលខុសត្រូវចំពោះសិទ្ធិនិងកាតព្វកិច្ចទាំងនោះដោយអនុលោមតាមប្រភេទកិច្ចព្រមព្រៀងរួម។<br>*វិសាលភាព៖* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការកំណត់ប្រភេទកិច្ចព្រមព្រៀងរួម ដែលស្ថាប័នបានចូលរួម និងក្នុងការទទួលខុសត្រូវចំពោះសិទ្ធិ និងកាតព្វកិច្ចនៃកិច្ចព្រមព្រៀងរួមទាំងនោះ។ |

| | |
|---|---|
| ៣៨. | **ការលាតត្រដាងអំពីអត្ថប្រយោជន៍នៅក្នុងស្ថាប័នផ្សេងទៀត**<br><br>*គោលបំណង÷* ដើម្បីតម្រូវឱ្យស្ថាប័នមួយលាតត្រដាងព័ត៌មានដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ អាចវាយតម្លៃពី÷<br>ក) ចរិតលក្ខណៈ និងហានិភ័យដែលជាប់ពាក់ព័ន្ធនឹងអត្ថប្រយោជន៍របស់ស្ថាប័នក្នុងស្ថាប័នក្រោមការគ្រប់គ្រង, ស្ថាប័នក្រោមការគ្រប់គ្រងដែលមិនរួមបញ្ចូល, កិច្ចព្រមព្រៀងរួម និងញាតិសម្ព័ន្ធ និងស្ថាប័នដែលមានរចនាសម្ព័ន្ធដែលមិនត្រូវបានរួមបញ្ចូល និង<br>ខ) ឥទ្ធិពលនៃអត្ថប្រយោជន៍ទាំងនោះមកលើស្ថានភាពហិរញ្ញវត្ថុ, លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ស្ថាប័ន។<br><br>*វិសាលភាព÷* ស្ថាប័នមួយដែលរៀបចំនិងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការលាតត្រដាងព័ត៌មានអំពីអត្ថប្រយោជន៍របស់ខ្លួននៅក្នុងស្ថាប័នក្រោមការគ្រប់គ្រង, ស្ថាប័នក្រោមការគ្រប់គ្រងដែលមិនរួមបញ្ចូល, កិច្ចព្រមព្រៀងរួម និងញាតិសម្ព័ន្ធ និងស្ថាប័នដែលមានរចនាសម្ព័ន្ធដែលមិនត្រូវបានរួមបញ្ចូល លើកលែងតែនៅពេលដែលស្តង់ដា IPSAS ផ្សេងទៀតត្រូវបានអនុវត្ត។ |
| ៣៩. | **អត្ថប្រយោជន៍និយោជិត**<br><br>*គោលបំណង÷* ដើម្បីកំណត់ការអនុវត្តគណនេយ្យ និងលក្ខខណ្ឌចាំបាច់នៃការលាតត្រដាងសម្រាប់អត្ថប្រយោជន៍និយោជិត ដែលតម្រូវឱ្យស្ថាប័នមួយទទួលស្គាល់÷<br>ក) បំណុលមួយ នៅពេលដែលនិយោជិតបានផ្តល់សេវា ជាការដោះដូរនឹងអត្ថប្រយោជន៍និយោជិតដែលត្រូវទូទាត់នាពេលអនាគត និង<br>ខ) ចំណាយមួយ នៅពេលដែលស្ថាប័នប្រើប្រាស់អត្ថប្រយោជន៍សេដ្ឋកិច្ច ឬសក្តានុពលសេវាដែលកើតឡើងពីសេវាដែលនិយោជិតបានផ្តល់ ជាការដោះដូរនឹងអត្ថប្រយោជន៍និយោជិត។<br><br>*វិសាលភាព÷* ស្តង់ដាត្រូវអនុវត្តដោយនិយោជកក្នុងការអនុវត្តគណនេយ្យសម្រាប់អត្ថប្រយោជន៍និយោជិតទាំងអស់ លើកលែងតែប្រតិបត្តិការដែលផ្អែកលើសន្លឹកហ៊ុន។ វាមិនអនុវត្តចំពោះផែនការអត្ថប្រយោជន៍ចូលនិវត្តន៍របស់និយោជិតឡើយ។ |

| | |
|---|---|
| ៤០. | **ការរួមបញ្ចូលវិស័យសាធារណៈ**<br>*គោលបំណង÷* ដើម្បីធ្វើឱ្យប្រសើរឡើងនូវភាពជាប់ពាក់ព័ន្ធ ការបង្ហាញដ៏ស្មោះត្រង់ និងភាពដែលអាចប្រៀបធៀបគ្នាបាននៃព័ត៌មានដែលស្ថាប័នរាយការណ៍មួយផ្តល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន អំពីការរួមបញ្ចូលវិស័យសាធារណៈនិងឥទ្ធិពលនៃការរួមបញ្ចូលវិស័យសាធារណៈនោះ។ ស្តង់ដាកំណត់គោលការណ៍អំពីរបៀបដែល÷<br>ក) ស្ថាប័នរាយការណ៍មួយ ធ្វើចំណាត់ថ្នាក់ការរួមបញ្ចូលវិស័យសាធារណៈ ជាការរួមបញ្ចូលគ្នា ឬ ការលក់<br>ខ) អង្គភាពរួមបញ្ចូលរួចមួយ ទទួលស្គាល់ និងវាស់វែងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន នូវទ្រព្យសកម្មដែលទទួលបានដែលអាចកំណត់អត្តសញ្ញាណបាន, បំណុលដែលបានសន្មត និងអត្ថប្រយោជន៍ដែលមិនទទួលបានពីការគ្រប់គ្រងក្នុងការរួមបញ្ចូលគ្នា<br>គ) អង្គភាពរួមបញ្ចូលរួចមួយ ទទួលស្គាល់ និងវាស់វែងសមាសធាតុនៃទ្រព្យសកម្ម ឬ មូលធនសុទ្ធ និងការកែតម្រូវផ្សេងទៀតដែលត្រូវបានទទួលស្គាល់ក្នុងការរួមបញ្ចូលគ្នា<br>ឃ) អ្នកទិញមួយរូប ទទួលស្គាល់ និងវាស់វែងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន នូវទ្រព្យសកម្មដែលទទួលបានដែលអាចកំណត់អត្តសញ្ញាណបាន, បំណុលដែលបានសន្មត និងអត្ថប្រយោជន៍ដែលមិនទទួលបានពីការគ្រប់គ្រងក្នុងប្រតិបត្តិការដែលត្រូវបានទិញ<br>ង) អ្នកទិញមួយរូប ទទួលស្គាល់ និងវាស់វែងមូលនិធិពាណិជ្ជកម្មដែលបានទិញ ឬ ការកើនឡើង ឬ ការខាតបង់ដែលកើតឡើងពីការទិញ និង<br>ច) ស្ថាប័នរាយការណ៍មួយ កំណត់ថាតើព័ត៌មានអ្វីដែលត្រូវលាតត្រដាង ដើម្បីអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចវាយតម្លៃពីចរិតលក្ខណៈនិងឥទ្ធិពលផ្នែកហិរញ្ញវត្ថុនៃការរួមបញ្ចូលវិស័យសាធារណៈមួយ។<br>ការរួមបញ្ចូលវិស័យសាធារណៈមួយ គឺជាការរួមបញ្ចូលគ្នានៃរាល់ប្រតិបត្តិការដាច់ដោយឡែកឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័នសាធារណៈមួយ។<br>*វិសាលភាព÷* ស្ថាប័នមួយដែលរៀបចំនិងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដាក្នុងការអនុវត្តគណនេយ្យសម្រាប់ការរួមបញ្ចូលវិស័យសាធារណៈ |

| | |
|---|---|
| | នៅពេលដែលនិយមន័យនៃការរួមបញ្ចូលវិស័យសាធារណៈមួយ អនុវត្តចំពោះប្រតិបត្តិការ ឬព្រឹត្តិការណ៍។ |
| ៤១. | **ឧបករណ៍ហិរញ្ញវត្ថុ**<br>*គោលបំណង÷* ដើម្បីបង្កើតគោលការណ៍សម្រាប់ការរាយការណ៍ហិរញ្ញវត្ថុអំពីទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដែលនឹងដាក់បង្ហាញអំពីព័ត៌មានពាក់ព័ន្ធនិងមានសារៈសំខាន់ចំពោះអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ដើម្បីវាយតម្លៃពីចំនួន ពេលវេលា និងភាពមិនច្បាស់លាស់នៃលំហូរសាច់ប្រាក់នាពេលអនាគតរបស់ស្ថាប័ន។<br>*វិសាលភាព÷* ស្តង់ដាត្រូវអនុវត្តចំពោះស្ថាប័នទាំងអស់និងឧបករណ៍ហិរញ្ញវត្ថុគ្រប់ប្រភេទទាំងអស់ លើកលែងតែឧបករណ៍ហិរញ្ញវត្ថុទាំងឡាយណាដែលស្ថិតក្រោមវិសាលភាពនៃស្តង់ដា IPSAS ផ្សេងទៀត (ឧទាហរណ៍ ស្តង់ដា IPSAS 13, 34, 35, 36 និង 39), សិទ្ធិ និងកាតព្វកិច្ចដែលកើតឡើងពីកិច្ចសន្យាធានារ៉ាប់រង, កិច្ចសន្យាដែលនឹងមកដល់ រវាងអ្នកទិញ និងម្ចាស់ភាគហ៊ុនដែលជាអ្នកលក់ ជាដើម។ |
| ៤២. | **អត្ថប្រយោជន៍សង្គម**<br>*គោលបំណង÷* ដើម្បីធ្វើឱ្យប្រសើរឡើងនូវភាពពាក់ព័ន្ធ ការតំណាងដ៏ស្មោះត្រង់ និងភាពដែលអាចប្រៀបធៀបគ្នាបាននៃព័ត៌មានដែលស្ថាប័នរាយការណ៍មួយផ្តល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនអំពីអត្ថប្រយោជន៍សង្គម ដូចបានកំណត់និយមន័យនៅក្នុងស្តង់ដានេះ។ ព័ត៌មានគួរជួយឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍ផ្សេងទៀត អាចវាយតម្លៃពី÷<br>(ក) ចរិតលក្ខណៈនៃអត្ថប្រយោជន៍សង្គមដែលផ្តល់ដោយស្ថាប័ន<br>(ខ) លក្ខណៈសម្បត្តិសំខាន់ៗនៃដំណើរការយន្តការអត្ថប្រយោជន៍សង្គមទាំងនោះ និង<br>(គ) ឥទ្ធិពលនៃអត្ថប្រយោជន៍សង្គមទាំងនោះ មកលើលទ្ធផលហិរញ្ញវត្ថុ ស្ថានភាពហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ស្ថាប័ន។<br>*វិសាលភាព÷* ស្ថាប័នមួយដែលរៀបចំ និងដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុតាមមូលដ្ឋានគណនេយ្យបង្គរ ត្រូវអនុវត្តស្តង់ដានេះក្នុងការអនុវត្តគណនេយ្យសម្រាប់អត្ថប្រយោជន៍សង្គម។ ស្តង់ដាមិនអនុវត្តចំពោះការផ្ទេរសាច់ប្រាក់ដែលត្រូវបានអនុវត្តគណនេយ្យតាមស្តង់ដាផ្សេងឡើយ (ឧទាហរណ៍ ស្តង់ដា IPSAS 9 ÷ អត្ថប្រយោជន៍និយោជិត) ឬ កិច្ចសន្យាធានារ៉ាប់រង។ |

## ឧបសម្ព័ន្ធទី ២៖ ឯកសារយោងនានាដែលបានបោះពុម្ពផ្សាយ


IPSAS – First Time Adoption of Accrual Basis IPSAS

Implementing Accrual Accounting in the Public Sector – IMF Technical Notes and Manuals, Joe Cavanagh, Suzanne Flynn and Delphine Moretti, 2016

Chart of Accounts: A Critical Element of the PFM Framework – IMF Technical Notes and Manuals, Julie Cooper and Sailendra Pattanayak, 2011

International Public Sector Accounting Standards Board Due Process and Working Procedures – IPSASB & IFAC, June 2016

Case Study – Adoption of IPSAS in the Philippines: IFAC May 2019

Transition to the Accrual Basis of Accounting: Guidance for Public Sector Entities – IPSASB & IFAC 2011

Stepping Stones on the Transition from Cash to Accrual Accounting – CIPFA, 2011

IPSAS implementation: current status and challenges – ACCA Global, December 2017

Accrual Practices and Reform Experiences in OECD Countries – OECD Publishing, OECD/IFAC (2017)

## សេចក្តីព្រាងផែនការសកម្មភាពសម្រាប់ឆ្ពោះទៅគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល (១២ មេសា ២០២១)

| លរ. | គោលបំណង/ សកម្មភាព | ពេលវេលា | | ស្ថាប័នដឹកនាំ | ស្ថាប័នគាំទ្រ | សូចនាករ | សូចនាករគន្លឹះ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចាប់ផ្តើម | បញ្ចប់ | | | | ដំណាក់កាលទី១- មូលដ្ឋានសាច់ប្រាក់ | | | ដំណាក់កាលទី២- មូលដ្ឋានសាច់ប្រាក់កែសម្រួល | | |
| | | | | | | | 2022 | 2023 | 2024 | 2025 | 2026 | 2027 |
| **I. បទប្បញ្ញត្តិស្តង់ដា និងគោលនយោបាយ** | | | | | | | | | | | | |
| **I.1. ស្តង់ដាគណនេយ្យ** | | | | | | | | | | | | |
| I.1.1 | -អភិវឌ្ឍស្តង់ដាគណនេយ្យសាធារណៈកម្ពុជា ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីព្រាងស្តង់ដាលេខ ៧០ (សមមូលនឹង ស្តង់ដា IFRS 15: ផលរបរពីប្រតិបត្តិការដោះដូរ), សេចក្តីព្រាងស្តង់ដាលេខ ៧១ (ផលរបរពីប្រតិបត្តិការមិនមែនដោះដូរ) និងសេចក្តីព្រាងស្តង់ដាលេខ ៧២ (ចំណាយប្រតិបត្តិការមិនមែនដោះដូរ) | 2021 | 2022 | ACAR | GDNT | -បានអភិវឌ្ឍស្តង់ដាគណនេយ្យសាធារណៈកម្ពុជា ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីព្រាងស្តង់ដាលេខ ៧០ (សមមូលនឹងស្តង់ដា IFRS 15: ផលរបរពីប្រតិបត្តិការដោះដូរ), សេចក្តីព្រាងស្តង់ដាលេខ ៧១ (ផលរបរពីប្រតិបត្តិការមិនមែនដោះដូរ) និងសេចក្តីព្រាងស្តង់ដាលេខ ៧២ (ចំណាយប្រតិបត្តិការមិនមែនដោះដូរ) | X | | | | | |

## សេចក្តីព្រាងផែនការសកម្មភាពសម្រាប់ឆ្ពោះទៅគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល (១២ មេសា ២០២១)

| ល.រ. | គោលបំណង/ សកម្មភាព | ពេលវេលា | | ស្ថាប័នដឹកនាំ | ស្ថាប័នគាំទ្រ | សូចនាករ | សូចនាករគន្លឹះ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ដំណាក់កាលទី១- មូលដ្ឋានសាច់ប្រាក់ | | | ដំណាក់កាលទី២- មូលដ្ឋានសាច់ប្រាក់កែសម្រួល | | |
| | | ចាប់ផ្តើម | បញ្ចប់ | | | | 2022 | 2023 | 2024 | 2025 | 2026 | 2027 |
| I.1.2 | -ទទួលបានការអនុម័តលើស្តង់ដាគណនេយ្យពីក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>-ទទួលបានការអនុម័តដាក់ឱ្យប្រើស្តង់ដា ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | 2022 | 2022 | ACAR | GDNT | -បានទទួលការអនុម័តលើស្តង់ដាគណនេយ្យពីក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>-បានទទួលការអនុម័តដាក់ឱ្យប្រើស្តង់ដាដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | X | | | | | |
| **I.2. ទម្រង់នៃការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ** | | | | | | | | | | | | |
| I.2.1 | -អភិវឌ្ឍ និងទទួលបានការអនុម័តលើទម្រង់និងមាតិកាដែលបានកែសម្រួលនៃរបាយការណ៍ហិរញ្ញវត្ថុអនុលោមតាមមូលដ្ឋានគណនេយ្យសាច់ប្រាក់កែសម្រួល | 2022 | 2022 | ACAR | GDNT | - បានទទួលការអនុម័តលើទម្រង់និងមាតិកាដែលបានកែសម្រួលនៃរបាយការណ៍ហិរញ្ញវត្ថុ អនុលោមតាមមូលដ្ឋានគណនេយ្យសាច់ប្រាក់កែសម្រួល | X | | | | | |
| I.2.2 | -ពិនិត្យនិងកែលម្អជាបណ្តើរៗនូវការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ នៅពេលមាតិកានិងវិសាលភាពនៃរបាយការណ៍ហិរញ្ញវត្ថុកាន់តែធំជាងមុន | 2021 | 2024 | ACAR | GDNT | -បានទទួលមតិយោបល់និងកែលម្អលើរបាយការណ៍ហិរញ្ញវត្ថុដែលកាន់តែមានវិសាលភាពធំជាងមុន | | | X | | | |

**I.3.ក្របខ័ណ្ឌច្បាប់ និងស្តង់ដា**

## សេចក្ដីព្រាងផែនការសកម្មភាពសម្រាប់ឆ្ពោះទៅគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល (១២ មេសា ២០២១)

| លរ. | គោលបំណង/ សកម្មភាព | ពេលវេលា | | ស្ថាប័នដឹកនាំ | ស្ថាប័នគាំទ្រ | សូចនាករ | សូចនាករគន្លឹះ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ដំណាក់កាលទី១- មូលដ្ឋានសាច់ប្រាក់ | | | ដំណាក់កាលទី២- មូលដ្ឋានសាច់ប្រាក់កែសម្រួល | | |
| | | ចាប់ផ្ដើម | បញ្ចប់ | | | | 2022 | 2023 | 2024 | 2025 | 2026 | 2027 |
| I.3.1 | -កំណត់ និងពង្រាងការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិចាំបាច់ ដើម្បីអនុវត្តគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល និងស្តង់ដា IPSAS | 2021 | 2022 | ACAR | GDNT | -បានបញ្ចប់ការធ្វើវិសោធនកម្មច្បាប់និងបទប្បញ្ញត្តិចាំបាច់ ដើម្បីអនុវត្តគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល និងស្តង់ដា IPSAS | X | | | | | |
| I.3.2 | - រៀបចំប្រកាសដែលតម្រូវឱ្យមានការលាតត្រដាងកំណត់សម្គាល់ និងការទទួលស្គាល់គណនីត្រូវទទួល និងគណនីត្រូវសងពីប្រតិបត្តិការដោះដូរ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ<br>-ទទួលបានការអនុម័តលើប្រកាសពី ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ | 2021 | 2022 | ACAR | GDNT | -បានចេញប្រកាសដែលតម្រូវឱ្យមានការលាតត្រដាងកំណត់សម្គាល់ និងការទទួលស្គាល់គណនីត្រូវទទួល និងគណនីត្រូវសងពីប្រតិបត្តិការដោះដូរ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ<br>- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ បានអនុម័តលើប្រកាស | X | | | | | |
| I.3.3 | -ពិនិត្យ និងកែលម្អបទប្បញ្ញត្តិ និងរៀបចំបទប្បញ្ញត្តិបន្ថែមជាបណ្តើរៗ ដើម្បីគាំទ្រដល់ការកើនឡើងនូវមាតិកា និងវិសាលភាពនៃរបាយការណ៍ហិរញ្ញវត្ថុ | 2024 | 2027 | ACAR | GDNT | -បានបញ្ចប់ការធ្វើវិសោធនកម្មច្បាប់, បទប្បញ្ញត្តិចាំបាច់ និងបានរៀបចំបទប្បញ្ញត្តិបន្ថែមជាបណ្តើរៗដើម្បីគាំទ្រដល់ការកើនឡើងនូវមាតិកា និងវិសាលភាពនៃរបាយការណ៍ហិរញ្ញវត្ថុ | | | X | X | X | X |

### I.4. ការធ្វើសវនកម្ម និងការពិនិត្យ

សេចក្តីព្រាងផែនការសកម្មភាពសម្រាប់ឆ្ពោះទៅគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល (១២ មេសា ២០២១)

| លរ. | គោលបំណង/ សកម្មភាព | ពេលវេលា | | ស្ថាប័នដឹកនាំ | ស្ថាប័នគាំទ្រ | សូចនាករ | សូចនាករគន្លឹះ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចាប់ផ្តើម | បញ្ចប់ | | | | ដំណាក់កាលទី១-មូលដ្ឋានសាច់ប្រាក់ | | | ដំណាក់កាលទី២-មូលដ្ឋានសាច់ប្រាក់កែសម្រួល | | |
| | | | | | | | 2022 | 2023 | 2024 | 2025 | 2026 | 2027 |
| | -ស្នើសុំមតិយោបល់ពីអាជ្ញាធរសវនកម្មជាតិលើសេចក្តីព្រាងគោលនយោបាយគណនេយ្យ, ទម្រង់ និងមាតិកាដែលបានកែសម្រួលនៃរបាយការណ៍ហិរញ្ញវត្ថុ | 2022 | 2022 | ACAR | GDNT,NAA | -បានទទួលមតិយោបល់ពីអាជ្ញាធរសវនកម្មជាតិលើសេចក្តីព្រាងគោលនយោបាយគណនេយ្យ, ទម្រង់ និងមាតិកាដែលបានកែសម្រួលនៃរបាយការណ៍ហិរញ្ញវត្ថុ | X | | | | | |

## II. ការអនុវត្តស្តង់ដា និងគោលនយោបាយ

### II.1. គោលនយោបាយគណនេយ្យ និងនីតិវិធីគណនេយ្យ

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| II.1.1 | -គោលនយោបាយគណនេយ្យ និងនីតិវិធីគណនេយ្យ | 2021 | 2022 | GDNT | ACAR | -បានរៀបចំគោលនយោបាយគណនេយ្យ និងនីតិវិធីគណនេយ្យ | X | | | | | |
| II.1.2 | -ទទួលបានសេចក្តីព្រាងស្តង់ដា, គោលនយោបាយគណនេយ្យ និងនីតិវិធីគណនេយ្យដែលបានផ្តល់អនុសាសន៍ដោយនិយ័តករ ឬ ជំនួយបច្ចេកទេសសម្រាប់រាជរដ្ឋាភិបាលកម្ពុជា | 2021 | 2022 | GDNT | ACAR, TA (IMF) | -បានទទួលសេចក្តីព្រាងស្តង់ដា, គោលនយោបាយគណនេយ្យ និងនីតិវិធីគណនេយ្យដែលបានផ្តល់អនុសាសន៍ដោយនិយ័តករ ឬ ជំនួយបច្ចេកទេសសម្រាប់រាជរដ្ឋាភិបាលកម្ពុជា | X | | | | | |

## សេចក្តីព្រាងផែនការសកម្មភាពសម្រាប់ឆ្ពោះទៅគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល (១២ មេសា ២០២១)

| លរ. | គោលបំណង/ សកម្មភាព | ពេលវេលា | | ស្ថាប័នដឹកនាំ | ស្ថាប័នគាំទ្រ | សូចនាករ | សូចនាករគន្លឹះ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ដំណាក់កាលទី១- មូលដ្ឋានសាច់ប្រាក់ | | | ដំណាក់កាលទី២- មូលដ្ឋានសាច់ប្រាក់កែសម្រួល | | |
| | | ចាប់ផ្តើម | បញ្ចប់ | | | | 2022 | 2023 | 2024 | 2025 | 2026 | 2027 |
| II.1.3 | -ក្រុមការងារបច្ចេកទេសប្រចាំអគ្គនាយកដ្ឋានរតនាគារជាតិ ពិនិត្យ និងប្រៀបធៀបបន្ទាត់គោលស្តង់ដា ជាមួយនឹងការអនុវត្តបច្ចុប្បន្ន ហើយធ្វើការកែសម្រួល។ | 2021 | 2022 | GDNT | ACAR, TA (IMF) | -បានកែសម្រួលបន្ទាត់គោលស្តង់ដា និងកែតម្រូវស្របតាមការអនុវត្តបច្ចុប្បន្ន។ | X | | | | | |
| II.1.4 | -ចេញផ្សាយសេចក្តីព្រាងបឋមគោលនយោបាយគណនេយ្យ និងនីតិវិធីគណនេយ្យ ហើយរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ | 2022 | 2022 | GDNT | ACAR, TA (IMF) | -បានចេញផ្សាយសេចក្តីព្រាងបឋមគោលនយោបាយគណនេយ្យ និងនីតិវិធីគណនេយ្យ ហើយរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ | X | | | | | |
| II.1.5 | -ពិនិត្យ និងកែលម្អស្តង់ដាគណនេយ្យ, គោលនយោបាយគណនេយ្យ និងនីតិវិធីគណនេយ្យ | 2024 | 2027 | GDNT | ACAR, TA (IMF) | -បានបញ្ចប់ការពិនិត្យ, ការកែលម្អ និងការកែសម្រួលស្តង់ដាគណនេយ្យ, គោលនយោបាយគណនេយ្យ និងនីតិវិធីគណនេយ្យ | | | X | X | X | X |

**II.2. ប្លង់គណនេយ្យ**

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | -បន្តពិនិត្យ កំណត់ ក៏ដូចជាដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងប្លង់គណនេយ្យ ដោយផ្អែកលើបទពិសោធន៍ | 2022 | 2027 | GDNT | ACAR | -បានបញ្ចប់ការពិនិត្យ និងកែសម្រួលលើប្លង់គណនេយ្យបច្ចុប្បន្ន ដោយផ្អែកលើបទពិសោធន៍ | X | X | X | X | X | X |

**II.3. ក្របខ័ណ្ឌច្បាប់ស្តីពីការអនុវត្ត និងថវិកា**

## សេចក្តីព្រាងផែនការសកម្មភាពសម្រាប់ឆ្ពោះទៅគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល (១២ មេសា ២០២១)

| លរ. | គោលបំណង/ សកម្មភាព | ពេលវេលា | | ស្ថាប័នដឹកនាំ | ស្ថាប័នគាំទ្រ | សូចនាករ | សូចនាករគន្លឹះ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ដំណាក់កាលទី១- មូលដ្ឋានសាច់ប្រាក់ | | | ដំណាក់កាលទី២- មូលដ្ឋានសាច់ប្រាក់កែសម្រួល | | |
| | | ចាប់ផ្តើម | បញ្ចប់ | | | | 2022 | 2023 | 2024 | 2025 | 2026 | 2027 |
| II.3.1 | -កែសម្រួលក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងការទទួលស្គាល់គណនីត្រូវទទួល | 2021 | 2022 | GDNT | ACAR, GDSPNR, GDT, GDCE | -បានចេញផ្សាយប្រកាសស្តីពីការទទួលស្គាល់គណនីត្រូវទទួល | X | | | | | |
| II.3.2 | -កែសម្រួលក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងការទទួលស្គាល់គណនីត្រូវសង | 2021 | 2023 | GDNT | ACAR, GDB, GDSNAF | -បានចេញផ្សាយប្រកាសស្តីពីការទទួលស្គាល់គណនីត្រូវសង | | X | | | | |
| **II.4. គណនីត្រូវសង** | | | | | | | | | | | | |
| II.4.1 | -បញ្ជាក់ពីគោលនយោបាយគណនេយ្យ និងនីតិវិធីគណនេយ្យ | 2021 | 2022 | GDNT | ACAR, ITD/FMWG | - បានចេញផ្សាយសេចក្តីព្រាងគោលនយោបាយគណនេយ្យ និងនីតិវិធីគណនេយ្យសម្រាប់គណនីត្រូវសង | X | | | | | |
| II.4.2 | -បញ្ចប់ការងាររៀបចំ រួមបញ្ចូលទាំងការស្ទង់មតិចាំបាច់នានាដើម្បីកំណត់ពីឥណទាយក និងសមតុល្យដែលបានជំពាក់ | 2021 | 2022 | GDNT | ACAR, ITD/FMWG | - បានបញ្ចប់ការរៀបចំតារាងឥណទាយករបស់រដ្ឋាភិបាល និងសមតុល្យដែលបានជំពាក់ | X | | | | | |
| II.4.3 | -ពិនិត្យភាពពេញលេញ និងគុណភាពទិន្នន័យដែលមានស្រាប់ | 2021 | 2022 | GDNT | ACAR, ITD/FMWG | - បានបញ្ចប់របាយការណ៍ជាមួយនឹងគុណភាពទិន្នន័យដែលមានស្រាប់ | X | | | | | |
| II.4.4 | -កំណត់ និងគណនាចំនួនសមតុល្យ គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ | 2023 | 2024 | GDNT | ACAR, ITD/FMWG | - បានបញ្ចេញសមតុល្យគណនីត្រូវសង គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ | | | X | | | |

## សេចក្តីព្រាងផែនការសកម្មភាពសម្រាប់ឆ្ពោះទៅគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល (១២ មេសា ២០២១)

| លរ. | គោលបំណង/ សកម្មភាព | ពេលវេលា | | ស្ថាប័នដឹកនាំ | ស្ថាប័នគាំទ្រ | សូចនាករ | សូចនាករគន្លឹះ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចាប់ផ្តើម | បញ្ចប់ | | | | ដំណាក់កាលទី១- មូលដ្ឋានសាច់ប្រាក់ | | | ដំណាក់កាលទី២- មូលដ្ឋានសាច់ប្រាក់កែសម្រួល | | |
| | | | | | | | 2022 | 2023 | 2024 | 2025 | 2026 | 2027 |
| II.4.5 | -ទទួលស្គាល់ គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ ២០២៤ | 2023 | 2024 | GDNT | ACAR, ITD/FMWG | -បានទទួលស្គាល់ គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២៤ | | | X | | | |
| II.4.6 | -បញ្ចូលសមតុល្យដើមគ្រានៅក្នុង ERP | 2023 | 2024 | GDNT | ACAR, ITD/FMWG | -បានបើកសមតុល្យគណនីត្រូវសងនៅក្នុង ERP | | | X | | | |
| II.4.7 | ទទួលស្គាល់គណនីត្រូវសងនៅក្នុង ERP | 2023 | 2024 | GDNT | ACAR, ITD/FMWG | -បានចាប់ផ្តើមបញ្ចូលទិន្នន័យគណនីត្រូវសងនៅក្នុង ERP | | | X | | | |
| II.4.8 | -កែលម្អ និងធ្វើឱ្យប្រសើរឡើងនូវទិន្នន័យ និងការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុនាពេលអនាគត | 2023 | 2024 | GDNT | ACAR, ITD/FMWG | -បានកែលម្អ និងធ្វើឱ្យប្រសើរឡើងនូវទិន្នន័យរបាយការណ៍ហិរញ្ញវត្ថុនាពេលអនាគត | | | X | | | |
| II.4.9 | -រៀបចំទម្រង់សម្រាប់កំណត់សម្គាល់ | 2023 | 2024 | GDNT | ACAR, ITD/FMWG | -បានដាក់ចេញទម្រង់សម្រាប់កំណត់សម្គាល់ | | | X | | | |
| II.4.10 | -កែលម្អ និងធ្វើឱ្យប្រសើរឡើងនូវទិន្នន័យ និងការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុនាពេលអនាគត | 2025 | 2027 | GDNT | ACAR, ITD/FMWG | - បានកែលម្អ និងធ្វើឱ្យប្រសើរឡើងនូវទិន្នន័យ និងការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុនាពេលអនាគត | | | | X | X | X |
| II.4.11 | -បន្តរាយការណ៍គណនីបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ | 2025 | 2027 | GDNT | ACAR, ITD/FMWG | - បានបន្តរាយការណ៍គណនីបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ | | | | X | X | X |

សេចក្តីព្រាងផែនការសកម្មភាពសម្រាប់ឆ្ពោះទៅគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល (១២ មេសា ២០២១)

| លរ. | គោលបំណង/ សកម្មភាព | ពេលវេលា | | ស្ថាប័នដឹកនាំ | ស្ថាប័នគាំទ្រ | សូចនាករ | សូចនាករគន្លឹះ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ដំណាក់កាលទី១- មូលដ្ឋានសាច់ប្រាក់ | | | ដំណាក់កាលទី២- មូលដ្ឋានសាច់ប្រាក់កែសម្រួល | | |
| | | ចាប់ផ្តើម | បញ្ចប់ | | | | 2022 | 2023 | 2024 | 2025 | 2026 | 2027 |
| **II.5. គណនីត្រូវទទួល (ផលរបរពីប្រតិបត្តិការដោះដូរ)** | | | | | | | | | | | | |
| II.5.1 | -បញ្ជាក់គោលនយោបាយគណនេយ្យ និងនីតិវិធីគណនេយ្យ | 2021 | 2022 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | -បានបញ្ចប់ការរៀបចំតារាងគោលនយោបាយគណនេយ្យ និងនីតិវិធីគណនេយ្យ | X | | | | | |
| II.5.2 | -កំណត់ប្រភេទគណនីត្រូវទទួលទាំងអស់ (ឧទាហរណ៍ ប្រាក់ចំណូលពីការជួល, សួយសារ, លិខិតឆ្លងដែន, វីសារ, កម្រៃពីកាស៊ីណូ, កម្រៃពីចំណត) | 2021 | 2022 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | - បានបញ្ចប់ការរៀបចំតារាងនៃប្រភេទគណនីត្រូវទទួលទាំងអស់ (ឧទាហរណ៍ ប្រាក់ចំណូលពីការជួល, សួយសារ, លិខិតឆ្លងដែន, វីសារ, កម្រៃពីកាស៊ីណូ, កម្រៃពីចំណត) | X | | | | | |
| II.5.3 | -ពិគ្រោះយោបល់ជាមួយអង្គភាពប្រមូលចំណូល | 2021 | 2022 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, | - បានទទួលមតិយោបល់ពីអង្គភាពប្រមូលចំណូល | X | | | | | |
| II.5.4 | -ពិគ្រោះយោបល់ជាមួយអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ដែលគ្រប់គ្រងលើការប្រមូលកម្រៃសម្រាប់ភ្នាក់ងារប្រមូលចំណូលផ្សេងទៀត | 2021 | 2022 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | - បានទទួលមតិយោបល់ពីអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ដែលគ្រប់គ្រងលើការប្រមូលកម្រៃសម្រាប់ភ្នាក់ងារប្រមូលចំណូលផ្សេងទៀត | X | | | | | |

# សេចក្តីព្រាងផែនការសកម្មភាពសម្រាប់ឆ្ពោះទៅគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល (១២ មេសា ២០២១)

| ល.រ. | គោលបំណង/ សកម្មភាព | ពេលវេលា | | ស្ថាប័នដឹកនាំ | ស្ថាប័នគាំទ្រ | សូចនាករ | សូចនាករគន្លឹះ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ដំណាក់កាលទី១- មូលដ្ឋានសាច់ប្រាក់ | | | ដំណាក់កាលទី២- មូលដ្ឋានសាច់ប្រាក់កែសម្រួល | | |
| | | ចាប់ផ្តើម | បញ្ចប់ | | | | 2022 | 2023 | 2024 | 2025 | 2026 | 2027 |
| II.5.5 | -ពិនិត្យភាពពេញលេញ និងគុណភាពទិន្នន័យដែលមានស្រាប់ | 2021 | 2022 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | -បានបញ្ចប់ការរៀបចំតារាងជាមួយនឹងគុណភាពទិន្នន័យដែលមានស្រាប់ | X | | | | | |
| II.5.6 | -គណនាគណនីត្រូវទទួល គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ | 2023 | 2023 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | - បានគណនាគណនីត្រូវទទួល គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ | | X | | | | |
| II.5.7 | -បញ្ចូលសមតុល្យដើមគ្រានៅក្នុង ERP គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ | 2023 | 2023 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | - បានបញ្ចូលសមតុល្យដើមគ្រានៅក្នុង ERP គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ | | X | | | | |
| II.5.8 | -ទទួលស្គាល់គណនីត្រូវទទួល គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ | 2023 | 2023 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | - បានទទួលស្គាល់គណនីត្រូវទទួល គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ | | X | | | | |
| II.5.9 | -រៀបចំទម្រង់សម្រាប់កំណត់សម្គាល់ | 2023 | 2023 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | - បានរៀបចំទម្រង់សម្រាប់កំណត់សម្គាល់ | | X | | | | |
| II.5.10 | -កែលម្អទិន្នន័យនៃគណនីត្រូវទទួល និងការដាក់បង្ហាញ (នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២៤ ដែលចាំបាច់សម្រាប់តួលេខប្រៀបធៀបនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២៥) | 2023 | 2024 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | - បានកែលម្អទិន្នន័យនៃគណនីត្រូវទទួល និងការដាក់បង្ហាញ (នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២៤ ដែលចាំបាច់សម្រាប់តួលេខប្រៀបធៀបនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២៥) | | | X | | | |

## សេចក្តីព្រាងផែនការសកម្មភាពសម្រាប់ឆ្ពោះទៅគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល (១២ មេសា ២០២១)

| លរ. | គោលបំណង/ សកម្មភាព | ពេលវេលា | | ស្ថាប័នដឹកនាំ | ស្ថាប័នគាំទ្រ | សូចនាករ | សូចនាករគន្លឹះ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ដំណាក់កាលទី១-មូលដ្ឋានសាច់ប្រាក់ | | | ដំណាក់កាលទី២-មូលដ្ឋានសាច់ប្រាក់កែសម្រួល | | |
| | | ចាប់ផ្តើម | បញ្ចប់ | | | | 2022 | 2023 | 2024 | 2025 | 2026 | 2027 |
| II.5.11 | -កែលម្អទិន្នន័យនៃគណនីត្រូវទទួល និងការដាក់បង្ហាញ | 2025 | 2027 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | -បានកែលម្អទិន្នន័យនៃគណនីត្រូវទទួល និងការដាក់បង្ហាញ | | | | X | X | X |
| II.5.12 | -បន្តរាយការណ៍គណនីត្រូវទទួលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ | 2025 | 2027 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | - បានបន្តរាយការណ៍គណនីត្រូវទទួលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ | | | | X | X | X |
| **II.6. គណនីត្រូវទទួល (ផលរបរពីប្រតិបត្តិការមិនមែនដោះដូរ រួមបញ្ចូលទាំងពន្ធ)** | | | | | | | | | | | | |
| II.6.1 | -ពិគ្រោះយោបល់ជាមួយអង្គភាពប្រមូលចំណូល ដូចជា អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល | 2021 | 2022 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | -បានពិគ្រោះយោបល់ជាមួយអង្គភាពប្រមូលចំណូល ដូចជា អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល | X | | | | | |
| II.6.2 | -កំណត់គោលនយោបាយគណនេយ្យ និងនីតិវិធីគណនេយ្យ រួមបញ្ចូលទាំងព្រឹត្តិការណ៍ជាប់ពន្ធ (IPSAS 23) | 2021 | 2022 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | - បានកំណត់គោលនយោបាយគណនេយ្យ និងនីតិវិធីគណនេយ្យ រួមបញ្ចូលទាំងព្រឹត្តិការណ៍ជាប់ពន្ធ (IPSAS 23) | X | | | | | |

## សេចក្តីព្រាងផែនការសកម្មភាពសម្រាប់ឆ្ពោះទៅគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល (១២ មេសា ២០២១)

| ល.រ | គោលបំណង/ សកម្មភាព | ពេលវេលា | | ស្ថាប័នដឹកនាំ | ស្ថាប័នគាំទ្រ | សូចនាករ | សូចនាករគន្លឹះ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ដំណាក់កាលទី១-មូលដ្ឋានសាច់ប្រាក់ | | | ដំណាក់កាលទី២-មូលដ្ឋានសាច់ប្រាក់កែសម្រួល | | |
| | | ចាប់ផ្តើម | បញ្ចប់ | | | | 2022 | 2023 | 2024 | 2025 | 2026 | 2027 |
| II.6.3 | -កំណត់ប្រភេទគណនីត្រូវទទួលទាំងអស់ រួមបញ្ចូលទាំង ពន្ធក្នុងស្រុក, អាករលើតម្លៃបន្ថែម, ពន្ធគយ (customs), អាករពិសេស (excise), ការទូទាត់មុននៃពន្ធលើប្រាក់ចំណេញ,ពន្ធលើប្រាក់ចំណេញ (corporate tax) | 2022 | 2022 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | -បានកំណត់ប្រភេទគណនីត្រូវទទួលទាំងអស់ រួមបញ្ចូលទាំង ពន្ធក្នុងស្រុក, អាករលើតម្លៃបន្ថែម, ពន្ធគយ (customs), អាករពិសេស (excise), ការទូទាត់មុននៃពន្ធលើប្រាក់ចំណេញ,ពន្ធលើប្រាក់ចំណេញ (corporate tax) | X | | | | | |
| II.6.4 | -ពិនិត្យភាពពេញលេញ និងគុណភាពទិន្នន័យដែលមានស្រាប់ | 2022 | 2022 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | -បានពិនិត្យភាពពេញលេញ និងគុណភាពទិន្នន័យដែលមានស្រាប់ | X | | | | | |
| II.6.5 | -គណនាចំនួនគណនីត្រូវទទួល គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ ២០២៣ | 2023 | 2023 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | -បានគណនាចំនួនគណនីត្រូវទទួល គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ | | X | | | | |
| II.6.6 | -បញ្ចូលសមតុល្យដើមគ្រានៅក្នុង ERP គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ | 2023 | 2023 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | - បានបញ្ចូលសមតុល្យដើមគ្រានៅក្នុង ERP គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ | | X | | | | |
| II.6.7 | -ទទួលស្គាល់គណនីត្រូវទទួល គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ ២០២៣ | 2023 | 2023 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | -បានទទួលស្គាល់គណនីត្រូវទទួល គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០២៣ | | X | | | | |

សេចក្តីព្រាងផែនការសកម្មភាពសម្រាប់ឆ្ពោះទៅគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល (១២ មេសា ២០២១)

| ល.រ. | គោលបំណង/ សកម្មភាព | ពេលវេលា | | ស្ថាប័នដឹកនាំ | ស្ថាប័នគាំទ្រ | សូចនាករ | សូចនាករគន្លឹះ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចាប់ផ្តើម | បញ្ចប់ | | | | ដំណាក់កាលទី១- មូលដ្ឋានសាច់ប្រាក់ | | | ដំណាក់កាលទី២- មូលដ្ឋានសាច់ប្រាក់កែសម្រួល | | |
| | | | | | | | 2022 | 2023 | 2024 | 2025 | 2026 | 2027 |
| II.6.8 | - កែលម្អទិន្នន័យគណនីត្រូវទទួល និងការដាក់បង្ហាញ (នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២៤ ដែលចាំបាច់សម្រាប់តួលេខប្រៀបធៀបនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២៥) | 2024 | 2024 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | - បានកែលម្អទិន្នន័យគណនីត្រូវទទួល និងការដាក់បង្ហាញ (នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២៤ ដែលចាំបាច់សម្រាប់តួលេខប្រៀបធៀបនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២៥) | | | X | | | |
| II.6.9 | -កែលម្អទិន្នន័យគណនីត្រូវទទួល និងការដាក់បង្ហាញ | 2025 | 2027 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | - បានកែលម្អទិន្នន័យគណនីត្រូវទទួល និងការដាក់បង្ហាញ | | | | X | X | X |
| II.6.10 | -បន្តរាយការណ៍គណនីត្រូវទទួលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ | 2025 | 2027 | GDNT | ITD/FMWG, GDSPNR, GDT, GDCE, ACAR | - បានបន្តរាយការណ៍គណនីត្រូវទទួលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ | | | | X | X | X |
| **II.7. ការអនុលោមតាមមូលដ្ឋានសាច់ប្រាក់** | | | | | | | | | | | | |
| II.7.1 | -រួមបញ្ចូលគណនីធនាគារដែលគ្រប់គ្រងដោយរដ្ឋាភិបាលទាំងអស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងគណនីធនាគារដែលគ្រប់គ្រងដោយក្រសួងនានាផងដែរ | 2021 | 2022 | GDNT | GDNT | - បានរួមបញ្ចូលសាច់ប្រាក់ទាំងអស់របស់រដ្ឋាភិបាលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងសាច់ប្រាក់ដែលគ្រប់គ្រងដោយក្រសួងនានាផងដែរ | X | | | | | |

## សេចក្ដីព្រាងផែនការសកម្មភាពសម្រាប់ឆ្ពោះទៅគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល (១២ មេសា ២០២១)

| លរ. | គោលបំណង/ សកម្មភាព | ពេលវេលា | | ស្ថាប័នដឹកនាំ | ស្ថាប័នគាំទ្រ | សូចនាករ | សូចនាករគន្លឹះ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ដំណាក់កាលទី១- មូលដ្ឋានសាច់ប្រាក់ | | | ដំណាក់កាលទី២- មូលដ្ឋានសាច់ប្រាក់កែសម្រួល | | |
| | | ចាប់ផ្ដើម | បញ្ចប់ | | | | 2022 | 2023 | 2024 | 2025 | 2026 | 2027 |
| II.7.2 | -ពុំរាយការណ៍ចំនួនទឹកប្រាក់ដែលត្រូវបានផ្ទេរទៅកាន់គណនីធនាគារដាច់ដោយឡែកដែលគ្រប់គ្រងដោយក្រសួងនានា (បុរេប្រទាន) ជាចំណាយឡើយ ប្រសិនបើចំនួនទឹកប្រាក់ទាំងនេះ នៅតែមាននៅក្នុងគណនីធនាគារដែលគ្រប់គ្រងដោយក្រសួងនានា | 2021 | 2022 | GDNT | GDNT | - សាច់ប្រាក់ដែលមាននៅក្នុងគណនីធនាគារដែលគ្រប់គ្រងដោយក្រសួងនានា នឹងត្រូវកត់ត្រាជាសាច់ប្រាក់។ | X | | | | | |
| **II.8. ការធ្វើសវនកម្ម និងការពិនិត្យ** | | | | | | | | | | | | |
| II.8.1 | -រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអាជ្ញាធរសវនកម្មជាតិពាក់ព័ន្ធនឹងការពិនិត្យ និងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ | 2022 | 2022 | GDNT | ACAR, NAA | -បានពិគ្រោះយោបល់ជាមួយអាជ្ញាធរសវនកម្មជាតិ | X | | | | | |
| II.8.2 | - រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយសវនករផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | 2022 | 2022 | GDNT | ACAR, NAA | -បានពិគ្រោះយោបល់ជាមួយសវនករផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | X | | | | | |
| II.8.3 | -ដាក់របាយការណ៍ហិរញ្ញវត្ថុដើម្បីពិនិត្យ | 2024 | 2024 | GDNT | NAA | -បានដាក់របាយការណ៍ហិរញ្ញវត្ថុដើម្បីពិនិត្យ | | | X | | | |

## សេចក្តីព្រាងផែនការសកម្មភាពសម្រាប់ឆ្ពោះទៅគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល (១២ មេសា ២០២១)

| លរ. | គោលបំណង/ សកម្មភាព | ពេលវេលា | | ស្ថាប័នដឹកនាំ | ស្ថាប័នគាំទ្រ | សូចនាករ | សូចនាករគន្លឹះ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ដំណាក់កាលទី១- មូលដ្ឋានសាច់ប្រាក់ | | | ដំណាក់កាលទី២- មូលដ្ឋានសាច់ប្រាក់កែសម្រួល | | |
| | | ចាប់ផ្តើម | បញ្ចប់ | | | | 2022 | 2023 | 2024 | 2025 | 2026 | 2027 |
| II.8.4 | -ពិនិត្យមតិយោបល់ដែលទទួលបានពីសវនករនិងអនុវត្តការកែលម្អចាំបាច់ | 2025 | 2027 | GDNT | NAA | - បានពិនិត្យមតិយោបល់ដែលទទួលបានពីសវនករនិងអនុវត្តការកែលម្អចាំបាច់ | | | | X | X | X |
| II.8.5 | -ដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្ម | 2025 | 2027 | GDNT | NAA | -បានដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្ម | | | | X | X | X |
| **II.9. ERP ដំណើរការតាមគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល** | | | | | | | | | | | | |
| II.9.1 | -នាយកដ្ឋានព័ត៌មានវិទ្យា ត្រូវផ្តល់មុខងារដើម្បីដំណើរការមូលដ្ឋានសាច់ប្រាក់កែសម្រួល | 2021 | 2022 | ITD/FMWG | GDNT, ACAR | -នាយកដ្ឋានព័ត៌មានវិទ្យាបានផ្តល់មុខងារដំណើរការមូលដ្ឋានសាច់ប្រាក់កែសម្រួល | X | | | | | |
| II.9.2 | -ធ្វើតេស្តសាកល្បង និងទទួលយកដោយផ្លូវការ (ផ្អែកលើលទ្ធផលនៃការធ្វើតេស្តដែលបានចងក្រងជាឯកសារ) | 2021 | 2022 | GDNT | ITD/FMWG, ACAR | - បានធ្វើតេស្តសាកល្បងនិងទទួលយកដោយផ្លូវការ (ផ្អែកលើលទ្ធផលនៃការធ្វើតេស្តដែលបានចងក្រងជាឯកសារ) | X | | | | | |
| II.9.3 | -ចាប់ផ្តើមដាក់ឱ្យដំណើរការ ERP តាមមូលដ្ឋានសាច់ប្រាក់កែសម្រួល | 2023 | 2023 | ITD/FMWG | GDNT, ACAR | - ដាក់ឱ្យដំណើរការ ERP តាមមូលដ្ឋានសាច់ប្រាក់កែសម្រួល | | X | | | | |
| II.9.4 | -ពិនិត្យសមតុល្យបណ្តោះអាសន្ននិងរបាយការណ៍ដែលបង្កើតចេញពី ERP ជាទៀងទាត់ និងដោះស្រាយបញ្ហាប្រឈមនានា | 2023 | 2023 | GDNT | ITD/FMWG, ACAR | - បានពិនិត្យសមតុល្យបណ្តោះអាសន្ននិងរបាយការណ៍ដែលបង្កើតចេញពី ERP ជាទៀងទាត់ និងដោះស្រាយបញ្ហាប្រឈមនានា | | X | | | | |

## សេចក្តីព្រាងផែនការសកម្មភាពសម្រាប់ឆ្ពោះទៅគណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល (១២ មេសា ២០២១)

| លរ. | គោលបំណង/ សកម្មភាព | ពេលវេលា | | ស្ថាប័នដឹកនាំ | ស្ថាប័នគាំទ្រ | សូចនាករ | សូចនាករគន្លឹះ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ដំណាក់កាលទី១- មូលដ្ឋានសាច់ប្រាក់ | | | ដំណាក់កាលទី២- មូលដ្ឋានសាច់ប្រាក់កែសម្រួល | | |
| | | ចាប់ផ្តើម | បញ្ចប់ | | | | 2022 | 2023 | 2024 | 2025 | 2026 | 2027 |
| II.9.5 | -បង្កើតរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រាចេញពី ERP ព្រមទាំងពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនានា | 2023 | 2023 | GDNT | ITD/FMWG, ACAR | - បានបង្កើតរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រាចេញពី ERP ព្រមទាំងពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនានា | | X | | | | |
| II.9.6 | -ប្រើប្រាស់ទិន្នន័យពី ERP ដើម្បីបង្កើតរបាយការណ៍ហិរញ្ញវត្ថុ មូលដ្ឋានសាច់ប្រាក់កែសម្រួល | 2024 | 2027 | GDNT | ITD/FMWG, ACAR | - ប្រព័ន្ធ FMIS អាចបង្កើតរបាយការណ៍ហិរញ្ញវត្ថុមូលដ្ឋានសាច់ប្រាក់កែសម្រួល | | | X | X | X | X |
| **II.10. ការបណ្តុះបណ្តាល** | | | | | | | | | | | | |
| II.10.1 | -រៀបចំផែនការបណ្តុះបណ្តាលសម្រាប់ភាគីពាក់ព័ន្ធផ្សេងៗ | 2022 | 2023 | EFI | GDNT, ACAR, IMF | - បានរៀបចំផែនការបណ្តុះបណ្តាលសម្រាប់ភាគីពាក់ព័ន្ធផ្សេងៗ | | X | | | | |
| II.10.2 | -បន្តវាយតម្លៃពីតម្រូវការសម្រាប់ការបណ្តុះបណ្តាល និងផ្តល់ការបណ្តុះបណ្តាល | 2024 | 2027 | EFI | GDNT, ACAR, IMF | - បានបន្តវាយតម្លៃពីតម្រូវការសម្រាប់ការបណ្តុះបណ្តាល និងផ្តល់ការបណ្តុះបណ្តាល | | | X | X | X | X |